**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# របបនៃការប្រកាសទោស

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ហ៊ុនហេង សុខវណ្ណស័ក្តិ**

លោក **សុខ យ៉ានី**

ណែនាំដោយ៖

លោក **ហោ សុភ័ណ្ឌ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# របបនៃការប្រកាសទោស

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ហ៊ុនហេង សុខវណ្ណស័ក្តិ**

លោក **សុខ យ៉ានី**

ណែនាំដោយៈ

លោក **ហោ សុភ័ណ្ឌ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ហ៊ុនហេង សុខវណ្ណស័ក្តិ** និង **សុខ យ៉ានី** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី ២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២០-២០២៤។

**សូមគោរពលំឱនកាយវាចាចិត្ត សម្តែងនូវមហាកតញ្ញូតាធម៌ដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះ ៖**

លោកឪពុក **ហ៊ុន រិន** និងអ្នកម្តាយ **សម ដានី**

លោកឪពុក **សុក សុខ** និងអ្នកម្តាយ **ហៀក ហុន**

ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅ ជួយទំនុកបម្រុងទាំងថវិការ ស្មារតី និងសម្ភារៈគ្រប់បែបយ៉ាងដល់រូបកូនចាប់តាំងពីពេលកូននៅជាកុមារភាពរហូតដល់កូនធំពេញវ័យ និងឱ្យកូនបានទទួលការបណ្តុះបណ្តាលតាំងពីថ្នាក់បឋមសិក្សារហូតដល់ថ្នាក់ឧត្តមសិក្សា។ លោកទាំងពីរបានខំប្រឹងប្រែងអស់ពីកំលាំងកាយចិត្តរបស់ខ្លួនក្នុងការជួយទំនុកបម្រុង តម្រង់ទិសឱ្យកូនៗមានអនាគតភ្លឺស្វាងរីកចម្រើន និងអភិវឌ្ឍន៍ខ្លួនឱ្យក្លាយជាពលរដ្ឋល្អនៅក្នុងសង្គមជាតិ។

**ឯកឧត្តមសាកលវិទ្យាធិការ សកលវិទ្យាធិការរង ព្រឹទ្ធិបុរស** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតនិងផ្តល់លទ្ធភាពឱ្យយើងខ្ញុំទាំងពីរទទួលបាននូវឱកាសក្នុងការចូលសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ** គ្រប់រូបនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលក្នុងអំឡុងពេល ៤ ឆ្នាំ កន្លងមកនេះ យើងខ្ញុំបានទទួលនូវការអប់រំណែនាំដែលពួកគាត់បានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយ កម្លាំងចិត្តក្នុងការបង្ហាត់បង្រៀន ផ្តល់ដំបូន្មានល្អៗ ព្រមទាំងផ្ទេរនូវចំណេះដឹងដល់ពួកយើងខ្ញុំ និងសិស្សដទៃទៀតតាំងពីថ្នាក់មូលដ្ឋានរហូតដល់បញ្ចប់បរិញ្ញាបត្រពិតជាពុំអាចកាត់ថ្លៃបាន។

យើងខ្ញុំទាំងពីរនាក់សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះលោក **ហោ សុវណ្ណា** ដែលបានដឹកនាំក្នុងការសេរសេរសារណាមួយនេះ ព្រមទាំងជួយណែនាំ ចង្អុលបង្ហាញផ្តល់មតិយោបល់ដំបូន្មានល្អៗ ទាំងផ្នែកស្មារតី និងឯកសារ ព្រមទាំងជួយត្រួតពិនិត្យកែតម្រូវចំណុចខ្វះខាត ដោយលោកបានលះបង់ពេលវេលាដ៏មានតម្លៃរបស់លោកនៅក្នុងកិច្ចការស្រាវជ្រាវមួយនេះ ចាប់តាំងពីចំណុចចាប់ផ្តើមរហូត ដល់សារណាមួយនេះបានបញ្ចប់ដោយជោគជ័យ។

ជាទីបញ្ចប់ យើងខ្ញុំទាំងពីរនាក់ សូមសម្តែងសេចក្តីដឹងគុណ និងចងចាំជានិច្ច ចំពោះគុណដ៏ ជ្រាលជ្រៅរបស់អ្នកទាំងអស់គ្នា ហើយយើងខ្ញុំសូមជូនពរនិងដឹងគុណលោកអ្នកមានគុណទាំងអស់ សូមបានប្រកបតែនឹងពុទ្ធពរទាំង៤ប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីបានសិក្សានៅថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ចអស់រយៈពេល ០៤ ឆ្នាំកន្លងមកនេះ យើងខ្ញុំទាំងពីរនាក់មានសេចក្ដីសោមនស្សរីករាយយ៉ាងខ្លាំងដែលទទួលបានឱកាសក្នុងការសរសេរសារណាបញ្ចប់ការសិក្សា។ ចំពោះការសរសេរសារណាបញ្ចប់ការសិក្សានេះ យើងខ្ញុំទាំងពីរនាក់មានគោលបំណងរួមមួយ គឺដើម្បីអភិវឌ្ឍចំណេះដឹងបន្ថែមទៅលើអ្វីដែលបានសិក្សាកន្លងមក ព្រមទាំងដើម្បីចងក្រងជាស្នាដៃមួយទុកសម្រាប់ឱ្យនិស្សិតជំនាន់ក្រោយសិក្សាស្វែងយល់ និងស្រាវជ្រាវបន្ថែម។ ហេតុនេះហើយទើបយើងខ្ញុំទាំងពីរនាក់បានពិភាក្សាគ្នា និងសម្រេចជ្រើសរើសយកប្រធានបទ "**របបនៃការប្រកាសទោស**" នេះដើម្បីរៀបចំតាក់តែងចងក្រងជាសារណាបញ្ចប់ការសិក្សាឡើង។ យើងខ្ញុំទាំងពីរនាក់បានខិតខំប្រឹងប្រែងក្នុងការស្វែងរកឯកសារដែលពាក់ព័ន្ធពីគ្រប់មជ្ឈដ្ឋានដើម្បីធ្វើជាមូលដ្ឋានក្នុងការសរសេរ ប្រធានបទនេះ តាមរយៈការសិក្សាស្រាវជ្រាវលើប្រធានបទសារណានេះយើងខ្ញុំធានាថាការសិក្សាស្រាវជ្រាវមួយនេះ វាមានភាពល្អប្រសើរក្នុងការសិក្សាស្វែងយល់បន្ថែមសម្រាប់អ្នកសិក្សាស្រាវជ្រាវ។ ទោះបីជាជួបការលំបាកយ៉ាងណាក៏ដោយ យើងខ្ញុំប្ដេជ្ញាចិត្តនឹងខិតខំប្រឹងប្រែងអស់ពីសមត្ថភាព ដោយមានការណែនាំបង្ហាត់បង្ហាញពីសំណាក់លោក **ហោ សុផ័ល្លា** ថែមទៀតនោះ ជាលទ្ធផលសារណាបញ្ចប់ការសិក្សានេះ នឹងមានខ្លឹមសារល្អប្រសើរដែលអាចទុកជាគុណសម្បត្តិសម្រាប់អ្នកសិក្សា។

ជាចុងក្រោយ យើងខ្ញុំទាំងពីរនាក់ សង្ឃឹមជឿជាក់ថា ស្នាដៃមួយនេះនឹងទទួលបានលទ្ធផលល្អ ហើយអាចក្លាយជាឯកសារជំនួយស្មារតីដល់ការស្រាវជ្រាវបន្ថែម របស់មិត្តនិស្សិត និងអ្នកសិក្សាស្រាវជ្រាវ។ ទន្ទឹមនឹងនេះ ចំពោះរាល់កំហុសខុសឆ្គងពាក់ព័ន្ធនឹងអក្ខរាវិរុទ្ធ ពាក្យពេចន៍ ឃ្លាប្រយោគ វេយ្យាករណ៍ និងខ្លឹមសារទាំងឡាយ។ យើងខ្ញុំនឹងរងចាំទទួលនូវរាល់ការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់សាស្ត្រាចារ្យ សិស្សនិស្សិត ក៏ដូចជាអ្នកសិក្សាស្រាវជ្រាវទាំងអស់ដោយក្ដីសោមនស្សរីករាយ និងការគោរពរាប់អានដ៏ជ្រាលជ្រៅពីយើងខ្ញុំទាំងពីរនាក់គ្រប់ពេលវេលា។

ជាទីបញ្ចប់យើងខ្ញុំសូមជូនពរដល់មិត្តអ្នកអានអ្នកស្រាវជ្រាវ លោកគ្រូ សាស្ត្រាចារ្យ និងមិត្តនិស្សិតទាំងអស់ទទួលបាននូវពរទាំងឡាយបួន សម្បត្តិបី អរិយទ្រព្យប្រាំពីរ និងមានសេក្ដីសុខ សំណាងល្អគ្រប់ពេលវេលា ជោគជ័យលើការសិក្សា សុខភាពល្អ និងជោគជ័យនូវគោលបំណងដែលបានប៉ងប្រាថ្នាគ្រប់ៗគ្នាកុំបីខានឡើយ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........................................ ១

## ជំពូកទី១

## របបទូទៅនៃការប្រកាសទោស

**ផ្នែកទី១ គោលការណ៍រួមនៅក្នុងរបបនៃការប្រកាសទោស** ........................................ ៤

១. គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ........................................ ៤

២. គោលការណ៍ឯកត្តកម្មនៃទោស ........................................ ៥

**ផ្នែកទី២ របបនៃការប្រកាសទោសចំពោះទោសនីមួយៗ** ........................................ ៦

១. ការប្រកាសមូលទោស ........................................ ៦

១.១. ការប្រកាសមូលទោស ចំពោះនីតិជន ........................................ ៨

១.២. ការប្រកាសមូលទោសចំពោះអនីតិជន ........................................ ៩

១.៣. ការប្រកាសមូលទោសចំពោះនីតិបុគ្គល ........................................ ១២

២. ការប្រកាសទោសបន្ថែម........................................១៣

២.១. ការប្រកាសទោសបន្ថែមចំពោះនីតិជន........................................១៤

២.២. ការប្រកាសទោសបន្ថែមចំពោះអនីតិជន........................................១៦

២.៣. ការប្រកាសទោសបន្ថែមចំពោះនីតិបុគ្គល........................................ ១៧

៣. ការប្រកាសទោសជំនួស ........................................ ១៨

៣.១. ទោសការងារសហគមន៍........................................១៨

៣.២. ទោសស្តីបន្ទោស ........................................ ២០

## ជំពូកទី២

## របបនៃការព្យួរទោស

**ផ្នែកទី១ ការព្យួរទោសធម្មតា**........................................ ២២

១. លក្ខខណ្ឌនៃការព្យួរទោសធម្មតា ........................................ ២២

១.១. ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម ........................................២២

១.២. ចំពោះបទលហុ ........................................................................ ២៤
២. ការដកហូត និងការមិនដកហូតការព្យួរទោសធម្មតា ........................................... ២៤
២.១. ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម ........................................................ ២៤
២.២. ចំពោះបទលហុ ........................................................................ ២៥
៣. ការទុកជាអសារបង់នូវការផ្តន្ទាទោស ........................................................ ២៥
៣.១. ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម ........................................................ ២៥
៣.២. ចំពោះបទលហុ ........................................................................ ២៦
**ផ្នែកទី២ ការព្យួរទោសសាកល្បង** ........................................................ ២៦
១. លក្ខខណ្ឌ នៃការព្យួរទោសសាកល្បង ........................................................ ២៦
២. វិធានការត្រួតពិនិត្យ និងកាតព្វកិច្ចដោយឡែក ............................................ ២៧
២.១. វិធានការត្រួតពិនិត្យ ................................................................ ២៧
២.២. កាតព្វកិច្ចដោយឡែក ................................................................ ២៨
៣. ការកែប្រែកាតព្វកិច្ចដោយឡែកដោយយុត្តាធិការ .............................................. ៣០
៤. ការដកហូតការព្យួរទោសសាកល្បង ........................................................ ៣០

## ជំពូកទី៣

## របបដោយឡែកនៃការប្រកាសទោស

**ផ្នែកទី១ របបនៃការផ្អាកការប្រកាសទោស** ................................................ ៣២
១. លក្ខខណ្ឌនៃការផ្អាកការប្រកាសទោស ........................................................ ៣២
១.១. បទល្មើសដែលត្រូវចោតប្រកាន់ ........................................................ ៣២
១.២. ជនជាប់ចោទត្រូវតែមានវត្តមាននៅពេលសវនាការ ........................................ ៣៣
២. សវនាការពិនិត្យរឿងដែលបង្អង់ ........................................................ ៣៤
**ផ្នែកទី២ របបពាក់កណ្តាលសេរីភាព** ........................................................ ៣៤
១. លក្ខខណ្ឌនៃរបបពាក់កណ្តាលសេរីភាព ........................................................ ៣៤
២. បែបបទនៃរបបពាក់កណ្តាលសេរីភាព ........................................................ ៣៥
៣. ការគិតបញ្ចូលរយៈពេលនៃរបបពាក់កណ្តាលសេរីភាពទៅក្នុងទោស ................................ ៣៥

៤. ការរៀបចំ និងការលុបចោលនៃរបបពាក់កណ្តាលសេរីភាព....................................................៣៦
៥. ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត..................................................................................៣៦
**ផ្នែកទី៣ របបនៃការបែងចែកទោសជាប្រភាគ** ............................................................... ៣៦
១. លក្ខខណ្ឌនៃការបែងចែកទោសជាប្រភាគ.............................................................................៣៧
២. បែបបទនៃការបែងចែកទោសជាប្រភាគ................................................................................៣៧
៣. ការកែប្រែរបបនៃការបែងចែកទោសជាប្រភាគ......................................................................៣៨
៤. ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត.......................................................................................៣៨
**សេចក្តីសន្និដ្ឋាន** ..........................................................................................................៤០
**អនុសាសន៍** ................................................................................................................ ៤២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងសង្គមបច្ចុប្បន្ននេះ យើងឃើញមានបទល្មើសផ្សេងៗតែងកើតមានឡើងជារាងរាល់ថ្ងៃមិនថាបទល្មើសនោះជាប្រភេទបទល្មើសអ្វីនោះទេ គឺសុទ្ធសឹងតែជាការបង្កឱ្យមានផលប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ក៏ដូចជាធ្វើឱ្យប៉ះពាល់ដល់អ្នកដទៃ។ សង្គមនីមួយៗតែងតែមានការរៀបចំនូវរបៀបទំនាក់ទំនងរវាងមនុស្សក្នុងសង្គមដោយបង្កើតជាវិធានផ្សេងៗ ក៏ប៉ុន្តែជានិច្ចកាលគេរមែងឃើញមានការរំលោភបំពាន ទៅលើវិធានច្បាប់ជារឿយៗ។ ហេតុនេះហើយសង្គមត្រូវតែឆ្លើយតបទៅនឹងការរំលោភបំពានទាំងនេះវិញ ដោយធ្វើការដាក់ទណ្ឌកម្មទៅលើអ្នកដែលរំលោភបំពានទាំងអស់។ ដូច្នេះហើយបានជានៅក្នុងប្រទេសនីមួយៗ តែងមានច្បាប់សម្រាប់គ្រប់គ្រងការពារសង្គមប្រឆាំងនឹងអំពើ ឬ អាកប្បកិរិយាដែលផ្ទុយនឹងច្បាប់ ក្នុងគោលដៅការពារសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ។ ជាក់ស្តែងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលបានប្រកាសឱ្យនៅថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ បានកំណត់អំពីទោសសម្រាប់ អនុវត្តលើបុគ្គលដែលប្រព្រឹត្តអំពើល្មើសផ្ទុយទៅពីបញ្ញត្តិច្បាប់ នឹងត្រូវផ្តន្ទាទោសជាធរមានទៅតាមអំពើដែលខ្លួនប្រព្រឹត្ត ហើយនឹងត្រូវធ្វើការប្រកាសដោយតុលាការ ប្រសិនបើគ្មានការប្រកាសទោសទេ ទោសនោះមិនអាចអនុវត្តបានឡើយ។ ក្រមព្រហ្មទណ្ឌបានកំណត់អំពី របបនៃការប្រកាសទោស ដើម្បីជារូបមន្តសម្រាប់តុលាការយកអនុវត្តឱ្យត្រូវទៅតាមចរិកលក្ខណៈនៃបទល្មើសនីមួយៗ ដើម្បីឱ្យការប្រកាសទោសទៅលើជនល្មើសកាន់តែមានភាពយុត្តិធម៌។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយសារតែការប្រកាសទោសព្រហ្មទណ្ឌមានសារៈសំខាន់ទៅដល់ការសម្រេចនៃជោគវាសនារបស់បុគ្គលម្នាក់ៗ ដូច្នេះហើយមុននឹងឈានដល់ការប្រកាសទោសព្រហ្មទណ្ឌទៅលើបុគ្គលដែលបានប្រព្រឹត្តបទល្មើសនោះ តើតុលាការពិចារណាទៅលើមូលដ្ឋានអ្វីខ្លះ? តើមានរបបពិសេសអ្វីខ្លះដែលផ្តល់លទ្ធភាពដល់ទណ្ឌិតដើម្បីកែខ្លួន?

## ៣. គោលបំណងនៃកិច្ចការស្រាវជ្រាវ

គោលបំណងដែលយើងខ្ញុំទាំងពីរនាក់សម្រេចចិត្ត និងចាប់ផ្តើមតាក់តែងនូវសារណានេះឡើង គឺដើម្បីស្វែងយល់អោយបានកាន់តែស៊ីជម្រៅទៅលើប្រធានបទមួយនេះ ក៏ដូចជាបានបន្ថែមនូវចំណេះដឹងផ្ទាល់ខ្លួនអំពីរបបនីមួយៗដែលទាក់ទងនឹងរបបការប្រកាសទោសនេះថែមមួយកម្រិតទៀត។ ម្យ៉ាងវិញទៀតសារណានេះជាឯកសារមួយសម្រាប់តម្កល់ទុកនៅក្នុងសាកលវិទ្យាល័យ ដើម្បីឱ្យសិស្សនិស្សិតជំនាន់ក្រោយបានសិក្សាស្វែង

យល់បន្ថែមទៀតផងដែរ។ ការធ្វើបែបនេះគឺដើម្បីជាការចូលរួមចំណែកផងដែរក្នុងការលើកស្ទួយវិស័យច្បាប់នៅក្នុងប្រទេសកម្ពុជាក្នុងនាមយើងខ្ញុំទាំងពីរនាក់ជានិស្សិតផ្នែកនីតិសាស្ត្រនេះផ្ទាល់។

## ៤. សារៈសំខាន់នៃកិច្ចការស្រាវជ្រាវ

សារៈសំខាន់បន្ទាប់ពីការសិក្សាស្រាវជ្រាវនេះ ត្រូវបានបញ្ចប់ឯកសារដែលជាសារណាមួយនេះអាចផ្តល់ជាប្រយោជន៍ដល់សិស្សនិស្សិត ក៏ដូចជាអ្នកសិក្សាស្រាវជ្រាវ ជាពិសេសអ្នកដែលសិក្សាផ្នែកនីតិសាស្ត្រគ្រប់មជ្ឈដ្ឋានទាំងអស់ដែលមានបំណងចង់សិក្សាស្វែងយល់បន្ថែមលើប្រធានបទនេះ និងបានបង្កើននូវចំណេះដឹងផ្ទាល់ខ្លួន ក៏ដូចជានាំអោយយើងខ្ញុំទាំងពីរនាក់បានយល់កាន់តែច្បាស់ និងស៊ីជម្រៅទៅលើមូលដ្ឋានច្បាប់ដែលទាក់ទងនឹងរបបនៃការប្រកាសទោសនេះផងដែរ។

## ៥. ទំហំ និងដែនកំណត់នៃកិច្ចការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះដែរយើងខ្ញុំសូមផ្តោតតែទៅលើច្បាប់ដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។ ចំពោះដែនកំណត់នៃការស្រាវជ្រាវ នៃប្រធានបទនេះយើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវ និងស្វែងរកឯកសារណាដែលទាក់ទងទៅនឹងប្រធានបទ **«របបនៃការប្រកាសទោស»** នេះតែប៉ុណ្ណោះដើម្បីយកមកសិក្សា និងវិភាគ។ ក្នុងនោះរួមមានដូចជា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦ និងឯកសារពាក់ព័ន្ធមួយចំនួនទៀតដូចដែលបានលើកឡើងនៅក្នុងឯកសារយោង។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវមួយនេះ យើងខ្ញុំមានការពន្យល់បកស្រាយទ្រឹស្តី លើកទល្បីករណ៍មកបញ្ជាក់តាមរយៈការប្រមូលទិន្នន័យពីការបកស្រាយពន្យល់ណែនាំពីសាស្ត្រាចារ្យ អ្នកវិជ្ជាជីវៈផ្នែកច្បាប់ ជាពិសេសលោកគ្រូសាស្ត្រាចារ្យណែនាំប្រធានបទសារណាយើងខ្ញុំផ្ទាល់។ ចំពោះការប្រមូលទិន្នន័យ និងឯកសារនានា ដែលទាក់ទងនឹងការសិក្សាស្រាវជ្រាវនៃប្រធានបទនេះ យើងខ្ញុំបានស្វែងរកពត៌មាន និងដកស្រង់ចេញនូវគោលគំនិតពីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦ ឯកសារពាក់ព័ន្ធនានាមួយចំនួនទៀតពីបណ្ណាល័យ ពីសៀវភៅរបស់សាស្ត្រាចារ្យ និងអ្នកនិពន្ធជាច្រើនផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សៀវភៅសារណានេះបែងចែកនិងផ្តោតសំខាន់លើ ៣ ជំពូកដូចខាងក្រោម ៖

- **ជំពូកទី១ របបទូទៅនៃការប្រកាសទោស ៖** ជំពូកនេះយើងខ្ញុំបកស្រាយអំពី គោលការណ៍រួមនៅក្នុងរបបនៃការប្រកាសទោស និង របបនៃការប្រកាសទោសចំពោះទោសនីមួយៗ។
- **ជំពូកទី២ របបនៃការព្យួរទោស ៖** ជំពូកនេះយើងខ្ញុំបកស្រាយអំពី ការព្យួរទោសធម្មតា និងការព្យួរទោសសាកល្បង។
- **ជំពូកទី៣ របបដោយឡែកនៃការប្រកាសទោស ៖** ជំពូកនេះយើងខ្ញុំបកស្រាយអំពី ការផ្អាកការប្រកាសទោស របបពាក់កណ្តាលសេរីភាព និង ការបែងចែកទោសជាប្រភាគ។

# ជំពូកទី១

# របបទូទៅនៃការប្រកាសទោស

# ជំពូកទី១
# របបទូទៅនៃការប្រកាសទោស

ការប្រកាសទោស ជាដំណាក់កាលចុងក្រោយទាក់ទងជាមួយសំណុំរឿងក្តីព្រហ្មទណ្ឌ ហើយជាដំណាក់កាលដែលមានសារៈសំខាន់ខ្លាំងណាស់ ដោយតម្រូវឱ្យតុលាការធ្វើការពិចារណាយ៉ាងល្អិតល្អន់មុននឹងធ្វើការប្រកាសដាក់ទោសទណ្ឌទៅលើជនល្មើសដើម្បីឱ្យសមស្របទៅតាមបទល្មើសដែលខ្លួនបានប្រព្រឹត្ត ហើយគាត់ត្រូវបែងចែកទោសនេះដើម្បីជាប្រយោជន៍សាធារណៈផងដែរ។ គ្មានទោសណាមួយដែលអាចត្រូវយកមកអនុវត្តបានឡើយ ប្រសិនបើទោសនោះ មិនត្រូវបានប្រកាសដោយតុលាការទេ[1] មានន័យថាទោសត្រូវតែប្រកាសដោយតុលាការទើបអាចអនុវត្តបាន។ ដូច្នេះហើយក្រមព្រហ្មទណ្ឌយើងបានចែងពីរបបនៃការប្រកាសទោសនេះដើម្បីឱ្យមានភាពងាយស្រួលទៅដល់ចៅក្រមនិងតុលាការក្នុងការសម្រេចសេចក្តីឱ្យស្របទៅតាមស្ថានភាពរបស់បុគ្គលម្នាក់ៗ។

## ផ្នែកទី១ គោលការណ៍រួមនៅក្នុងរបបនៃការប្រកាសទោស

ទាក់ទងនឹងរបបនៃការប្រកាសទោសនេះ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានចែងនូវគោលការណ៍សំខាន់ៗចំនួន ០២ គឺគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលមានចែងនៅក្នុងមាត្រា ២៤ និង គោលការណ៍ឯកត្តកម្មនៃទោស មានចែងនៅក្នុងមាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌ។ គោលការណ៍ទាំងពីរនេះ គឺជាគោលការណ៍សំខាន់ណាស់សម្រាប់តុលាការយកទៅប្រើប្រាស់ក្នុងការកំណត់អំពីទោសទៅតាមស្ថានភាពរបស់បុគ្គលម្នាក់ៗ។

### ១. គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ សំដៅដល់ការទទួលខុសត្រូវចំពោះអំពើផ្ទាល់ខ្លួនមានន័យថា បុគ្គលម្នាក់ៗ ទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ[2]។ បើបុគ្គលណាម្នាក់ជាអ្នកប្រព្រឹត្តបទល្មើស ដូច្នេះបុគ្គលនោះជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌ។ ករណីនេះគឺខុសពីរឿងក្តីរដ្ឋប្បវេណីមានន័យថាក្នុងរឿងរដ្ឋប្បវេណី ច្បាប់អនុញ្ញាតឱ្យអ្នកដទៃទទួលខុសត្រូវជំនួសបាន។ ប៉ុន្តែនៅក្នុងរឿងព្រហ្មទណ្ឌអ្នកណាជាអ្នកប្រព្រឹត្តបទល្មើស អ្នកនោះគឺជាអ្នកទទួលខុសត្រូវដែលភាសាខ្មែរយើងនិយាយយ៉ាងសាមញ្ញថា «ក្បាលអ្នកណាសក់អ្នកនោះ អ្នកណាធ្វើអ្នកនោះទទួល» ហេតុនេះមិនអាចឱ្យអ្នកដទៃ ឬសាច់ញាតិរបស់ខ្លួន

[1] មាត្រា ៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[2] មាត្រា ២៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

ទទួលទោសជំនួសឡើយ ទោះបីទោសនោះជាប្រភេទទោសអ្វីក៏ដោយ។ ផ្ទុយទៅវិញបើច្បាប់អនុញ្ញាតឱ្យអ្នកដទៃអាចទទួលទោសជំនួសបាននោះពិតណាស់ច្បាស់ជាបុគ្គលដែលបានប្រព្រឹត្តបទល្មើសនោះមិនមានភាពខ្លាចរអារនឹងច្បាប់ ឬកែខ្លួនមកចូលរស់នៅក្នុងសង្គមវិញនោះទេ គឺនៅតែបន្តប្រព្រឹត្តបទល្មើសម្តងហើយម្តងទៀត ដែលធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសង្គមយ៉ាងខ្លាំង នេះគឺផ្ទុយពីគោលបំណងនៃក្រមព្រហ្មទណ្ឌទាំងស្រុងតែម្តង។ **ឧទាហរណ៍៖** លោក **ក** បានទៅចាក់សម្លាប់លោក **ខ** ដូច្នេះលោក **ក** ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទឃាតកម្ម មិនអាចឱ្យប្រពន្ធកូន បងប្អូន ឬមិត្តភក្តិរបស់លោក **ក** ទៅទទួលខុសត្រូវព្រហ្មទណ្ឌជំនួសលោក **ក** បានទេ។

## ២. គោលការណ៍ឯកត្តកម្មនៃទោស

គោលការណ៍ឯកត្តកម្មនៃទោស មានន័យថាទោសដែលចៅក្រមត្រូវសម្រេចត្រូវប្រកាសឬត្រូវកំណត់សម្រាប់បុគ្គលនីមួយៗ គឺប្រែប្រួលទៅតាមបុគ្គលម្នាក់ៗនិងកាលៈទេសៈដែលបានប្រព្រឹត្តបទល្មើសនោះ។ មាត្រា ៩៦ បានចែងយ៉ាងច្បាស់ថា តុលាការប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាននិងបន្ទុក ទៅលើមូលហេតុ ព្រមទាំងទៅលើកិរិយាមារយាទរបស់ជនល្មើស ក្រោយពេលប្រព្រឹត្តបទល្មើស ជាអាទិ៍ ចំពោះជនរងគ្រោះ[3]។ គោលការណ៍នេះ ជាមូលដ្ឋានគ្រឹះមួយសម្រាប់ចៅក្រមធ្វើការថ្លឹងថ្លែង ពិចារណា និងប្រើប្រាស់អំណាចឆន្ទានុសិទ្ធិ ធ្វើការកំណត់អំពីកម្រិតនៃទោសដើម្បីដាក់ឱ្យត្រូវទៅលើជនដែលបានប្រព្រឹត្តនោះឱ្យសមល្មមទៅនឹងស្ថានភាពរបស់បុគ្គលម្នាក់ៗដើម្បីផ្តល់ភាពត្រឹមត្រូវ និងយុត្តិធម៌។

**ឧទាហរណ៍៖ ក** ជាកូនកំព្រាឪពុកសព្វថ្ងៃរស់នៅជាមួយម្តាយដែលមានជំងឺជាប់ខ្លួន។ ដោយសារជីវភាពទីទាល់ក្រ **ក** បានសម្រេចចិត្តធ្វើសកម្មភាពឆក់កាបូបរបស់នារី **ខ** ខណៈពេលដែលនាងកំពុងតែដើរតាមផ្លូវ។ បទល្មើសបានកើតឡើងដោយ **ក** បានឆក់កាបូប **ខ** បានសម្រេច ដែលបទល្មើសនេះជាប្រភេទបទលួចមានស្ថានទម្ងន់ទោស។ តើ **ក** ត្រូវមានទោសដូចម្តេច? ដូច្នេះក្នុងករណីនេះចៅក្រមអាចវិនិច្ឆ័យទោសដោយពិចារណាទៅលើមូលហេតុដែលបណ្តាលឱ្យ **ក** ឈានទៅដល់ការប្រព្រឹត្តបទល្មើស តើ **ក** ជានីតិជន ឬអនីតិជន? តើ **ក** មានសភាពផ្លូវចិត្តដូចម្តេច? តើ **ក** មានកិរិយាមារយាទបែបណាក្រោយពេលប្រព្រឹត្តបទល្មើសរួច ជាអាទិ៍ នោះសុទ្ធសឹងតែជាមូលដ្ឋានដែលចៅក្រមត្រូវធ្វើពិចារណាដើម្បីធ្វើការសម្រេចថាត្រូវផ្តន្ទាទោសដូចម្តេចនោះវាជាឆន្ទានុសិទ្ធិរបស់ចៅក្រម ប៉ុន្តែឆន្ទានុសិទ្ធិរបស់គាត់គឺផ្អែកទាំងស្រុងទៅលើគោលការណ៍ឯកត្តកម្មនៃទោស

[3]មាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

មានន័យថា គាត់ថ្លឹងបទល្មើស គ្រោះថ្នាក់នៃបទល្មើសដែលកើតឡើងដោយសារអំពើនិងចរិកគ្រោះថ្នាក់របស់បុគ្គលក្នុងការជ្រើសរើសយកទោសណាមួយដាក់ឱ្យសមល្មមទៅតាមកម្រិតដែលជនល្មើសបានប្រព្រឹត្ត។

## ផ្នែកទី២ របបនៃការប្រកាសទោសចំពោះទោសនីមួយៗ

ទោស គឺជាទណ្ឌកម្មដែលត្រូវផ្តន្ទាដោយសង្គមតាមរយៈច្បាប់ទៅលើជន ឬ បុគ្គលទាំងឡាយណាដែលបានប្រព្រឹត្តបទល្មើស។ យោងតាមគោលការណ៍នីត្យានុកូលភាព ដែលបានបញ្ញត្តិក្នុងមាត្រា ៣ បានចែងថា មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន។ មានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន[4]។ ដូច្នេះមានន័យថាទាល់តែទោសដែលប្រព្រឹត្តនោះបានកើតក្នុងអំឡុងពេល ឬ ក្រោយពេលដែលច្បាប់នោះកំពុងនៅជាធរមាន ហើយលុះត្រាតែបទល្មើស ឬ ទោសនោះមានចែងដាក់លាក់ក្នុងច្បាប់ទើបតុលាការអាចប្រកាសបាន។ នៅក្នុងក្រមព្រហ្មទណ្ឌ ទោសមាន ៣ (បី) ប្រភេទសម្រាប់រូបវន្តបុគ្គលគឺមូលទោស ទោសបន្ថែម និងទោសជំនួស ចំណែកឯទោសមាន ០២ (ពីរ) ប្រភេទសម្រាប់នីតិបុគ្គលគឺ មូលទោស និងទោសបន្ថែម តែគ្មានទោសជំនួសទេ។ ការប្រកាស ត្រូវគោរពទៅតាមលក្ខខណ្ឌដែលចែងដោយច្បាប់។

### ១. ការប្រកាសមូលទោស

មូលទោស គឺជាទោសចម្បងដែលតុលាការអាចយកទៅសម្រេចដាច់តែឯងបានដោយមិនចាំបាច់បញ្ចូលនូវទោសបន្ថែម ឬទោសជំនួស ហើយជាទោសដែលសំខាន់ជាងគេ។ គ្រប់បទល្មើសទាំងអស់សុទ្ធតែត្រូវផ្តន្ទាទោសយ៉ាងហោចណាស់ដោយមូលទោសមួយ វាជាទោសដែលភ្ជាប់ជាចាំបាច់ទៅនឹងបទល្មើសមួយ។ នៅក្នុងក្រមព្រហ្មទណ្ឌ មូលទោសចែកចេញជាពីរប្រភេទរួមមាន ទោសដាក់ពន្ធនាគា និងទោសពិន័យ[5]។

ទោសដាក់ពន្ធនាគារ គឺជាទោសគុកដែលបំបាត់សេរីភាពដោយមានកំណត់កាលដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។ ទោសពិន័យ ជាទោសដែលតម្រូវឱ្យទណ្ឌិតបង់ចំនួនប្រាក់កំណត់ដោយច្បាប់ ហើយទឹកប្រាក់នេះត្រូវកំណត់ជាប្រាក់រៀល[6]។ ប្រាក់ជាផលនៃពិន័យត្រូវបង់ចូលថវិការដ្ឋ[7] ដោយត្រូវយកទៅទុកនៅក្នុងរតនាគារជាតិ។ ស្របគ្នានឹងនេះផងដែរ ទាំងទោសដាក់ពន្ធនាគារ និងទោសពិន័យត្រូវបានច្បាប់កំណត់អំពី

[4]មាត្រា ៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[5]មាត្រា ៤៣ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[6]មាត្រា ៤៣ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[7]មាត្រា ៥២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

អប្បបរមា និងអតិបរមានៃទោស[8] ដោយកម្រិតអតិបរមា និងអប្បបរមានៃទោសនេះអាច ត្រូវបានបានបន្ថែម ទម្ងន់ ឬសម្រាលទោសជាយថាហេតុ ស្របតាមបុគ្គលិកលក្ខណៈជនល្មើស កាលៈទេសៈនៃបទល្មើស និង លក្ខខណ្ឌដែលច្បាប់បានកំណត់[9]។ នៅក្នុងក្រមព្រហ្មទណ្ឌមានបញ្ញត្តិអំពីចំណាត់ថ្នាក់នៃបទល្មើស ដែលចែក បទល្មើសជា ៣ ប្រភេទ គឺ បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ហើយដើម្បីកំណត់ថាបទល្មើសណាមួយជា បទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ នោះគេត្រូវពិនិត្យទៅលើអតិបរមានៃទោសដាក់ពន្ធនាគារដែលច្បាប់កំណត់ សម្រាប់បទល្មើសនោះ។ ទោសឧក្រិដ្ឋ គឺជាប្រភេទបទល្មើសដែលកម្រិតទោសអតិបរមា (ធ្ងន់ជាងគេ) នៃការ ជាប់ពន្ធនាគារដែលមានរយៈពេលលើសពី ៥ (ប្រាំ) ឆ្នាំ ដល់ក្រោម ឬស្មើនឹង ៣០ (សាមសិប) ឆ្នាំ ឬ រហូតដល់ មួយជីវិត ហើយទោសឧក្រិដ្ឋនេះអាចត្រូវបន្ថែមនូវទោសពិន័យ ជាប្រាក់ផងដែរ[10]។ ទោសជាប់ពន្ធនាគារមួយ ជីវិតគឺ ជាទោសដែលធ្ងន់ធ្ងរជាងគេដោយប្រហារជីវិតត្រូវបានលុបចោលដោយមាត្រា ៣២ នៃរដ្ឋធម្មនុញ្ញនៃព្រះ រាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣[11]។ បន្ទាប់មកគឺ បទមជ្ឈិម ជាប្រភេទបទល្មើសដែលកម្រិតទោសអតិបរមានៃ ការជាប់ពន្ធនាគារលើសពី ៦ (ប្រាំមួយ)ថ្ងៃ ដល់ក្រោម ឬស្មើ ៥ (ប្រាំ) ឆ្នាំ រួមទាំងអាចបន្ថែមមកជាមួយនឹង ទោសពិន័យជាប្រាក់ផងដែរ[12]។ ចុងក្រោយគឺ បទលហុជា បទល្មើសដែលកម្រិតទោសអតិបរមានៃការជាប់ ពន្ធនាគារមានថិរវេលាស្មើ ឬក្រោម ៦ (ប្រាំមួយ) ថ្ងៃ រួមជាមួយទោសពិន័យជាប្រាក់ ឬអាចត្រឹមតែជាទោស ពិន័យប៉ុណ្ណោះ[13]។ ក្រមព្រហ្មទណ្ឌបានបញ្ញត្តិអំពីការគណនាថិរវេលានៃទោសដាក់ពន្ធនាគាផងដែរ យោងតាម មាត្រា ៤៩ នៃក្រមព្រហ្មទណ្ឌ ទោសដាក់ ពន្ធនាគារត្រូវគណនាថិរវេលានៃទោសដាក់ពន្ធនាគារដូចតទៅ៖

- ទោសដាក់ពន្ធនាគារ ១ (មួយ) ថ្ងៃ ត្រូវគិត ២៤ (ម្ភៃបួន) ម៉ោង។
- ទោសដាក់ពន្ធនាគារ ១ (មួយ) ខែ ត្រូវគិត ៣០ (សាមសិប) ថ្ងៃ។
- ទោសដាក់ពន្ធនាគារលើសពី ១ (មួយ) ខែ ត្រូវគិតតាមចំនួនថ្ងៃជាក់ស្តែងដែលមាននៅក្នុងខែនោះ។
- ទោសដាក់ពន្ធនាគារ ១ (មួយ) ឆ្នាំ ត្រូវគិត ១២ (ដប់ពីរ) ខែ[14]។

ទោសដាក់ពន្ធនាគារត្រូវដកចេញនូវថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន មានន័យថា ថិរវេលានៃការឃុំ ខ្លួនបណ្តោះអាសន្នត្រូវគិតបញ្ចូលទាំងស្រុងនៅក្នុងថិរវេលានៃទោសដាក់ពន្ធនាគារដែលទណ្ឌិតត្រូវទទួល[15]។

---

[8]មាត្រា ៥២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩
[9]មាត្រា ៥២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩
[10]មាត្រា ៥២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩
[11]មាត្រា ៣២ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣
[12] មាត្រា ៤៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩
[13]មាត្រា ៤៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩
[14]មាត្រា ៤៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩
[15]មាត្រា ៥១ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

ទោសដាក់ពន្ធនាគារត្រូវបានបញ្ចប់ទោសដោយផ្អែកតាមលក្ខខណ្ឌដោយឡែកនៃការបញ្ចប់ទោស កាលណាទណ្ឌិតបានបញ្ចប់ទោសចំថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃបុណ្យ ដូច្នេះអាជ្ញាធរមានសមត្ថកិច្ចត្រូវបង្គាប់ដោះលែងទណ្ឌិតទាំងនោះឱ្យមានសេរីភាពឡើងវិញនៅមុនថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃបុណ្យនោះ[16]។ ការប្រកាសមូលទោសគឺតុលាកាត្រូវប្រកាសដោយស្របតាមបម្រែបម្រួលនៃបុគ្គល និងប្រភេទបុគ្គលម្នាក់ៗក្នុងឋានៈជារូបវន្តបុគ្គលដែលក្នុងនោះមាន នីតិជន និងអនីតិជន ឬ ក្នុងឋានៈជានិតិបុគ្គល។

### ១.១. ការប្រកាសមូលទោស ចំពោះនីតិជន

តាមន័យទូទៅ នីតិជន ជាជនដែលគ្រប់អាយុតាមច្បាប់កំណត់ហើយមានសមត្ថភាពឯករាជ្យខាងអំពើមានន័យគ្រប់បុគ្គលជារូបវន្តបុគ្គលទាំងអស់ត្រូវ ទទួលខុសត្រូវព្រហ្មទណ្ឌមានលក្ខណៈពេញលេញ កាលណាជននោះគ្រប់អាយុតាមការកំណត់។ នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់អាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ[17]។ របៀបនៃការប្រកាសមូលទោសនេះ មានចែងយ៉ាងជាក់លាក់ដោយយោងតាមមាត្រា៩៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ គឺបានចែងកំណត់ថា ប្រសិនបើបទល្មើសមួយមានចែងផ្តន្ទាទោសដាក់ពន្ធនាគារផង និងពិន័យជាប្រាក់ផង នោះតុលាការគាត់មានសិទ្ធិអំណាចធ្វើការជ្រើសរើសក្នុងការកំណត់ អំពីទោសដូចតទៅ ៖

- **ទី១** ៖ តុលាការអាចប្រកាស ទោសដាក់ពន្ធនាគារផង និងទោសពិន័យផងរួមជាមួយគ្នា មានន័យថាជនជាប់ចោទត្រូវអនុវត្តទោសក្នុងពន្ធនាគារផង និងទទួលទោសសងជាប្រាក់ផង។
- **ទី២** ៖ តុលាការអាចប្រកាស ត្រឹមតែដាក់ពន្ធនាគារតែមួយ ពោលគឺប្រកាសតែទោសជាប់គុកដោយមិនប្រកាសនូវទោសពិន័យជាប្រាក់ទេ។
- **ទី៣** ៖ តុលាការអាចប្រកាសត្រឹមតែទោសពិន័យជាប្រាក់ដោយមិនប្រកាសនូវទោសដាក់ពន្ធនាគារឡើយ[18]។

បទប្បញ្ញត្តិខាងលើនេះ ផ្តល់សិទ្ធិអំណាចឱ្យតុលាការធ្វើការពិចារណាជ្រើសរើសជម្រើសណាមួយដើម្បីយកទៅដាក់ទាសឱ្យបានត្រឹមត្រូវតាមស្ថានភាពជាក់ស្តែង ហើយបទប្បញ្ញត្តិដែលបានលើកឡើងខាងលើនេះអាចអនុវត្តទៅបានលុះត្រាតែមិនមានបដិប្បញ្ញត្តិពិសេសចែងផ្ទុយពីបទប្បញ្ញត្តិខាងលើនេះ បើមានបទប្បញ្ញត្តិចែងថាត្រូវតែប្រកាសទោសដាក់ពន្ធនាគារផង និងទោសពិន័យជាប្រាក់ផងនោះ តុលាការត្រូវតែប្រកាសទោស

[16]មាត្រា ៥០ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩
[17]មាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩
[18]មាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

ទាំងពីរនោះព្រមគ្នាតែម្តងមានន័យថា គឺអាចមានបទប្បញ្ញត្តិពិសេសចែងអំពីស្ថានភាពនេះច្បាស់លាស់ តែប្រសិនបើជា មានបទប្បញ្ញត្តិពិសេសចែងពីស្ថានភាពនេះច្បាស់លាស់មែន ដូច្នេះចៅក្រមត្រូវតែអនុវត្តទៅតាមបទប្បញ្ញត្តិពិសេសនោះ។ បើពុំមានបទប្បញ្ញត្តិពិសេសចែងពីស្ថានភាពនេះច្បាស់លាស់ទេ តុលាការត្រូវអនុវត្តនូវរបបរួមដូចមានចែងក្នុងមាត្រា ៩៧ នេះ។

### ១.២. ការប្រកាសម្ចូលទោសចំពោះអនីតិជន

អនីតិជន គឺជាជនដែលមិនទាន់គ្រប់អាយុតាមច្បាប់កំណត់ ឬជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស[19]។ អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ត្រូវកំណត់យកអាយុនៅពេលដែល អនីតិជននោះប្រព្រឹត្តបទល្មើស។ ភស្តុតាងនៃអាយុរបស់អនីតិជន ត្រូវបានបញ្ជាក់ដោយសំបុត្រកំណើត ឬឯកសារផ្សេងទៀតដែលអាចបញ្ជាក់បានអំពីកំណើត។ ក្នុងករណីពុំមានឯកសារ ឬមានការសង្ស័យ ឬមិនមានភាព ច្បាស់លាស់ទាក់ទងនឹងយថាភូតនៃឯកសារនោះ ភស្តុតាងនៃអាយុរបស់អនីតិជនអាចផ្តល់តាមគ្រប់ មធ្យោបាយផ្សេងទៀតដែលអាជ្ញាធរតុលាការអាចជឿទុកចិត្តបាន។ អាជ្ញាធរមានសមត្ថកិច្ចត្រូវស្វះស្វែងរកភស្តុតាងដើម្បីកំណត់អាយុរបស់អនីតិជនឲ្យបានឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន។ ក្នុងករណីមានការសង្ស័យអំពីអាយុរបស់អនីតិជន វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ អនីតិជននោះ[20]។

អនីតិជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី)ឆ្នាំ ចែកជាពីរប្រភេទគឺ អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ និងអនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ។

#### ១.២.១. អនីតិជនដែលមានអាយុក្រោម១៤ឆ្នាំ

អនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ត្រូវបានលើកលែងឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ដោយតុលាការមិនអាចសម្រេចផ្តន្ទាទោសទៅលើអនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំឡើយ។ ក្នុងករណីដែលអនីតិជនមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មានជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើសពុំអាចត្រូវបានគេឃាត់ខ្លួនឡើយ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រគល់អនីតិជននោះទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់វិញភ្លាម[21]។ អនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មិនត្រូវបានឃុំខ្លួនបណ្តោះអាសន្នឡើយ។ ក្នុងករណីអនីតិជនដែលកំពុងជាប់ឃុំត្រូវបានរកឃើញថាមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់ និងបង្គាប់ឲ្យដោះលែងអនីតិជននោះជាបន្ទាន់ ទោះបីមាន

[19]មាត្រា ៤ ចំណុចទី៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦
[20]មាត្រា ៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦
[21]មាត្រា ១៤ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦

បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះទៅឱ្យអ្នកតំណាងដែលច្បាប់បានកំណត់[22]។

ទោះអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ការមិនទទួលខុសត្រូវព្រហ្មទណ្ឌដែលរារាំងមិនឲ្យប្រកាសទោស ប៉ុន្តែមិនរារាំងការចូលខ្លួនមកកាន់តុលាការ និងការប្រកាសសេចក្តីសម្រេចអំពីការស្តីបន្ទោស ឬវិធានការអប់រំទេ ព្រោះថាអនីតិជនដែលប្រព្រឹត្តបទល្មើសគឺជាកម្មវត្ថុនៃវិធានការអប់រំ វិធានការការពារ វិធានការតាមដាន និងវិធានការតាមឧបត្ថម្ភ[23]។

### ១.២.២. អនីតិជនដែលមានអាយុចាប់ពី១៤ឆ្នាំ ដល់ក្រោម១៨ឆ្នាំ

ដូចដែលបានរៀបរាប់ជូនរួចមកហើយថា អនីតិជនដែលប្រព្រឹត្តបទល្មើស គឺជាកម្មវត្ថុនៃវិធានការអប់រំ វិធានការការពារ វិធានការតាមដាន និងវិធានការតាមឧបត្ថម្ភហេតុនេះតុលាការអាចមិនប្រកាសអំពីទោសព្រហ្មទណ្ឌទេ មិនថាជាទោសដាក់គុក ឬពិន័យជាប្រាក់នោះទេ ប៉ុន្តែតុលាការអាចដាក់អនីតិជននោះឱ្យស្ថិតនៅក្រោម វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ។

វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភមាន ដូចតទៅ :

១-ការប្រគល់អនីតិជនឱ្យទៅឪពុកម្តាយ អាណាព្យាបាល បុគ្គលដែលថែរក្សា អនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនឹងទំនុកចិត្ត។

២-ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុក អនីតិជន។

៣-ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការ ទទួលអនីតិជន។

៤-ការប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស។

៥-ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ[24]។

ក្នុងករណីដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការនោះ តុលាការចាត់តាំងបុគ្គលមួយរូបដែលទទួលភារៈធ្វើការតាមដានអនីតិជន។ បុគ្គលនេះធ្វើ របាយការណ៍ស្តីពីកិរិយាមារយាទរបស់អនីតិជនឱ្យ បានទៀងទាត់ដល់ព្រះរាជអាជ្ញា។ បុគ្គលនេះផ្តល់ព័ត៌មាន ដល់ព្រះរាជអាជ្ញាអំពីព្រឹត្តិការណ៍ទាំងអស់ដែលអាចនាំឱ្យ

[22]មាត្រា ៣៩ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦
[23]មាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩
[24]មាត្រា ៤០ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

មានការកែប្រែនូវវិធានការនេះ[25]។

មិនមែនគ្រប់អនីតិជនដែលប្រព្រឹត្តបទល្មើសទាំងអស់សុទ្ធតែត្រូវដាក់ឱ្យស្ថិតនៅក្រោម វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភនោះទេ។ តុលាការអាចធ្វើការប្រកាសទណ្ឌកម្មព្រហ្មទណ្ឌចំពោះអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងបានផងដែរ ប្រសិនបើពិនិត្យមើលឃើញថា កាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ[26] មានន័យថា តុលាការធ្វើការប្រកាសទណ្ឌកម្មព្រហ្មទណ្ឌដោយយោងតាម កាលៈទេសៈ បុគ្គលិកលក្ខណៈរបស់ជននោះ ដូចករណីខ្លះបទល្មើសដែលអនីតិជននោះបានប្រព្រឹត្តវាមានលក្ខណៈធ្ងន់ធ្ងរដែលធ្វើប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬ បទល្មើសនោះមានលក្ខណៈសាហាវដែលតុលាការមិនអាចដាក់អនីតិជននោះឱ្យស្ថិតនៅក្រោម វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និង វិធានការឧបត្ថម្ភបានទេ ដូច្នេះជម្រើសល្អបំផុត គឺមានតែការសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌនេះឯង។

កាលណាតុលាការ សម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ មូលទោសលើបទល្មើសដែលចោទប្រកាន់ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចតទៅ :

១-អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល។

២-ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ។

៣-អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានេះលើសពី ១ (មួយ) ថ្ងៃ។

៤-អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល។

ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទប្បញ្ញត្តិនៃមាត្រានេះមានអានុភាព បន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមថិរវេលាមួយស្មើ ឬ តិចជាង ៥ (ប្រាំ) ឆ្នាំ នោះបទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល[27]។ បទប្បញ្ញត្តិស្តីពី ការមិនរាងចាលមិនត្រូវបានយកមកអនុវត្តអនិតិជនឡើយ[28]។

អតិប្បបរមា និងអប្បបរមានៃទោសដាក់ពន្ធនាគារ និងទោសពិន័យ ជាប្រាក់ដែលត្រូវបន្ថយនោះ គឺការបន្ថយដោយធៀបនឹងទោសរបស់នីតិជន ពោលគឺសន្មត់ថាបើនីតិជនត្រូវជាប់ ពន្ធនាគារក្នុងពេលកំណត់ ១០

[25]មាត្រា ៤១ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[26]មាត្រា ៣៩ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[27]មាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[28]មាត្រា ១៦៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

(ដប់) ឆ្នាំ និងទោសពិន័យជាប្រាក់ ២០,០០០,០០០ (ម្ភៃលាន) រៀល ចំពោះអនីតិជននឹងត្រូវទទួលរងទោសពន្ធនាគារ ៥ (ប្រាំ)ឆ្នាំ និងទោសពិន័យជាប្រាក់ ១០,០០០,០០០ (ដប់លាន) រៀល។

**ឧទាហរណ៍៖** អនីតិជន **ក** អាយុ ១៧ (ដប់ប្រាំពីរ) ឆ្នាំ បានទាស់សម្ដីគ្នាជាមួយអនីតិជន **ខ** អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ដែលធ្វើឱ្យ **ក** មានការខឹងគុំគួនជាមួយ **ខ**។ ថ្ងៃមួយ **ក** ក៏បានធ្វើជាបបួល **ខ** ទៅលេងនៅអគារទុកចោលមួយកន្លែង ពេលទៅដល់កន្លែងកើតហេតុ **ក** បានធ្វើសកម្មភាពចាក់សម្លាប់ **ខ** បទល្មើសជាប្រភេទបទល្មើស **ឃាតកម្មគិតទុកជាមុន**។ ដូច្នេះករណីបែបនេះមានលក្ខណៈសាហាវណាស់គឺមិនអាចប្រើប្រាស់វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភបានទេ អញ្ចឹងនៅក្នុងករណីនេះជម្រើសល្អបំផុតការសម្រេចផ្ដន្ទាទោសព្រហ្មទណ្ឌចំពោះអនិតិជននោះដោយអនុលោមតាមបញ្ញត្តិនៃមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

ករណីអនីតិជនដែលជាប់ពន្ធនាគារ ត្រូវឃុំខ្លួននៅទីកន្លែងពិសេស ខណ្ឌដាច់ពីនីតិជន។ អនីតិជនស្ថិតនៅក្រោមរបបដោយឡែកជាឯកត្តបុគ្គល ដែលជាទីកន្លែងសម្រាប់អប់រំ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។ របបឃុំឃាំងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រី ក្រសួងពាក់ព័ន្ធ[29]។

### ១.៣. ការប្រកាសមូលទោសចំពោះនីតិបុគ្គល

នីបុគ្គល គឺជាក្រុមមនុស្ស ឬមូលនិធិដែលមានបុគ្គលភាពគតិយុត្ត ឬដែលត្រូវបានទទួលស្គាល់ដោយច្បាប់ ហើយជាម្ចាស់នៃសិទ្ធិ និងកាតព្វកិច្ច។ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល គឺមានចែងបញ្ញត្តិនៅក្នុងមាត្រា ៤២ ដោយបានចែងកំណត់ថា ក្នុងករណីដែលមានចែងជាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត នីតិបុគ្គលលើកលែងតែរដ្ឋចេញ អាចត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើសដែលប្រព្រឹត្តដោយអង្គភាព ឬអ្នកតំណាងរបស់ខ្លួនដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ។ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល ក្នុងអំពើដដែលនោះទេ[30]។ មានន័យថាការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល លុះត្រាតែមានចែងជាក់លាក់នៅក្នុងច្បាប់ និងបទដ្ឋានគតិយុត្តិផ្សេងៗចែងជាក់លាក់ថានីតិបុគ្គលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ បើសិនជាមិនមានច្បាប់ចែងទេ គឺមិនអាចឱ្យនីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌបានទេដោយស្របទៅតាមគោលការណ៍នីត្យានុកូល។ ចំពោះនីតិបុគ្គលមិនមានការប្រកាសទោសដាក់ពន្ធនាគារនោះទេ គឺមានតែទោសពិន័យជាប្រាក់ក្នុងឋានៈជាមូលទោសប៉ុណ្ណោះ[31]។

[29]មាត្រា ១៦៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩
[30]មាត្រា ៤២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩
[31]មាត្រា ១៦៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

មិនមែនគ្រប់នីតិបុគ្គលសុទ្ធតែត្រូវទទួលខុសត្រូវព្រហ្មទណ្ឌទេ មានតែនីតិបុគ្គលឯកជនប៉ុណ្ណោះដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ដោយឡែកនីតិបុគ្គលសាធារណៈដែលចំណុះរបស់រដ្ឋ ក្រសួង ស្ថាប័ន អង្គភាព ឬការិយាល័យរដ្ឋណាមួយជាអាទិ៍ ដែលបង្កើតដោយអំណាចសាធារណៈក្នុងនាមប្រយោជន៍សាធារណៈពុំទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។

ការទទួលខុសត្រូវព្រហ្មទណ្ឌនេះ គឺទទួលខុសត្រូវចំពោះអំពើដែលប្រព្រឹត្តដោយអង្គភាព ឬអ្នកតំណាងរបស់បុគ្គល ដែលអំពើល្មើសនោះធ្វើឡើងដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ មានន័យថាអង្គភាព ឬអ្នកតំណាងដែលជារូបវន្តបុគ្គលនោះត្រូវទទួលខុសត្រូវព្រហ្មទណ្ឌហើយនីតិបុគ្គលដែលទទួលប្រយោជន៍ពីអង្គភាព ឬ អ្នកតំណាងរបស់ខ្លួននោះក៏ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌផងដែរ។ ប៉ុន្តែនីតិបុគ្គលនោះនឹងមិនទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ប្រសិនបើអំពើដែលអង្គភាព ឬ អ្នកតំណាងប្រព្រឹត្តក្នុងគោលបំណងផលប្រយោជន៍ផ្ទាល់ខ្លួន។ ទោះបីជាច្បាប់ឲ្យនីតិបុគ្គលសាធារណៈរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌក៏ដោយ តែរូបវន្តបុគ្គលដែលជាអង្គភាព ឬ អ្នកតំណាងរបស់នីតិបុគ្គលសាធារណៈដែលបានប្រព្រឹត្តអំពើមិនត្រូវបានលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។

### ២. ការប្រកាសទោសបន្ថែម

ទោសបន្ថែម គឺជាអនុទោស ឬទោសបន្ទាប់បន្សំដែលតុលាការប្រកាសបន្ថែមពីលើមូលទោស ដោយទោសបន្ថែមនេះមិនអាចប្រកាសដាច់តែឯងបានទេ គឺតុលាការត្រូវសម្រេចប្រកាសមូលទោសមួយជាមុនសិនទើបធ្វើការប្រកាសទោសបន្ថែមនេះពីលើមូលទោសនោះតែម្តង។ ទោសបន្ថែមមានគោលដៅបំពេញបន្ថែមឱ្យមូលទោសដើម្បីបង្ការការប្រព្រឹត្តបទល្មើសសាជាថ្មី។

តុលាការមិនអាចយកទោសបន្ថែមទៅសម្រេចតែឯងបានទេ ដោយតុលាការនឹងសម្រេចមូលទោសណាមួយសិន ពីព្រោះទោសបន្ថែមគ្រាន់តែជាកម្មវិបាករបស់មូលទោសតែប៉ុណ្ណោះ។ ដោយផ្អែកតាមលក្ខខណ្ឌនៃការប្រកាសទោសនៃទោសបន្ថែម អាចចែកជា២ ប្រភេទគឺ ទោសបន្ថែម ដែលអាចប្រកាសតាមជម្រើសរបស់តុលាការ និងទោសបន្ថែមដែលត្រូវប្រកាសជាកាតព្វកិច្ច។ ការប្រកាសទោសបន្ថែមត្រូវបានកម្រិតអាស្រ័យទៅតាមប្រភេទនៃបុគ្គលដែលត្រូវទទួលរងនោះ ហើយបន្តទៅនេះយើងខ្ញុំនឹងធ្វើការបកស្រាយអំពីទោសបន្ថែមដែលតុលាការត្រូវប្រកាសចំពោះបុគ្គលម្នាក់ៗ។

### ២.១. ការប្រកាសទោសបន្ថែមចំពោះនីតិជន

មាត្រា ៩៩ នៃក្រមព្រហ្មទណ្ឌយើងបានបញ្ញត្តិអំពីរបៀបប្រកាសទោសបន្ថែមលើមូលទោស ដោយបានចែងថា កាលណាបទល្មើសមួយត្រូវផ្តន្ទាទោសដោយទោសបន្ថែមមួយ ឬ ច្រើន ទោសនេះត្រូវបន្ថែមទៅលើមូលទោស លើកលែងតែបញ្ញត្តិនៃមាត្រា១០០ (ការជំនួសមូលទោសដោយទោសបន្ថែម) នៃក្រមនេះចេញ[32]។

ទោសបន្ថែមមានចំនួន ១៩ ចំណុចដែលតុលាការអាចប្រកាសបន្ថែមពីលើមូលទោសរួមមានៈ

១- ការដកសិទ្ធិខ្លះជាពលរដ្ឋ។

២- ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណា ដែលបទល្មើសនោះបានប្រព្រឹត្ត នៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ។

៣- ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ។

៤- ការព្យួរលិខិតបើកបរ។

៥- ការហាមឃាត់ចំពោះការស្នាក់នៅ។

៦- ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

៧- ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះទណ្ឌិតដែលជាជនបរទេស ។

៨- ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្ត បទល្មើស ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស។

៩- ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស។

១០- ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស។

១១- ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុ ដែលលំអទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត។

១២- ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត។

១៣- ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទ។

---

[32]មាត្រា ៩៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

១៤- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ។

១៥- ការបិទគ្រឹះស្ថានដែលប្រើប្រាស់ ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស។

១៦- ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន។

១៧- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស។

១៨- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន។

១៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍។

បទប្បញ្ញត្តិដោយឡែក អាចបង្កើតទោសបន្ថែមផ្សេងៗទៀត[33]។

ក្នុងចំណោមទោសទាំង១៩ ចំណុច តុលាការនឹងជ្រើសរើសយកទោសបន្ថែមមួយមួយ ឬ ច្រើន ស្របតាមបទល្មើសដែលមានកំណត់មកប្រកាសបន្ថែមលើមូលទោស។ ប៉ុន្តែមិនមែនគ្រប់ករណីទាំងអស់ តុលាការអាចរើសយកទោសបន្ថែមមួយ ឬច្រើនក្នុងចំណោម ១៩ ចំណុចនោះ យកមកប្រកាសដើម្បីបន្ថែមទៅលើមូលទោសបានទេ។ ទោសបន្ថែម នឹងអាចប្រកាសទៅបាន លុះត្រាតែទោសនេះត្រូវបានចែង ដោយជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ដែលត្រូវចោទប្រកាន់។ ទោសបន្ថែមអាចប្រកាសក៏បាន មិនប្រកាសក៏បាន ប៉ុន្តែក្នុងករណីច្បាប់កំណត់ ថាទោសបន្ថែម ត្រូវតែប្រកាសជាកាតព្វកិច្ចតុលាការត្រូវតែប្រកាស ទោសបន្ថែមជាដាច់ខាត[34] មានន័យថា ដើម្បីអាចអាចប្រកាសទោសបន្ថែមបាន លុះត្រាតែទោសបន្ថែមនេះមានចែងយ៉ាងជាក់លាក់ក្នុងច្បាប់ បើសិនជាមិនបានចែងជាក់លាក់ក្នុងច្បាប់ទេតុលាការមិនអាចធ្វើការប្រកាសទោសបន្ថែមនៅលើមូលទោសបានទេ។

**ឧទាហរណ៍៖** បទមនុស្សឃាតដោយអចេតនា មាត្រា ២០៧ ច្បាប់បានកំណត់អំពីមូលទោសដែលត្រូវកំណត់ឲ្យជាប់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ចន្លោះពី២,០០០,០០០ (ពីរលាន) រៀល ទៅ ៦,០០០,០០០ (ប្រាំមួយលាន) រៀល ហើយមាត្រា ២០៨ បានចែងអំពីទោសបន្ថែមនៅក្នុងបទល្មើសនេះចំនួន ៧។ នៅពេលដែលមានចែងយ៉ាងជាក់លាក់ដូច្នេះ ចៅក្រមអាចប្រកាសទោសបន្ថែមមួយ ឬច្រើនក្នុងចំណោម ៧ ចំណុចដែលមានចែងនៅក្នុងបទប្បញ្ញត្តិនៃមាត្រា ២០៨ នេះដើម្បីអនុវត្តបន្ថែមទៅលើមូលទោសដែលគាត់ផ្តន្ទាទោសទាក់ទងជាមួយបទមនុស្សឃាតដោយអចេតនាបាន។

[33]មាត្រា ៥៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[34]មាត្រា ៥៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

យើងដឹងហើយថា ទោសបន្ថែម មិនអាចយកទៅសម្រេចតែឯងបានទេ គឺតុលាការត្រូវធ្វើការប្រកាសមូលទោសណាមួយសិនទើបអាចប្រកាសទោសបន្ថែមបាន ប៉ុន្តែក្នុងករណីពិសេស ទោសបន្ថែមក៏អាចជំនួសឱ្យមូលទោសបានដែរដោយយោងតាមបទប្បញ្ញត្តិមាត្រា ១០០ នៃក្រមព្រហ្មទណ្ឌដែលបានចែងថា តុលាការអាចសម្រេចជំនួសមូលទោសដោយទោសបន្ថែមមួយឬច្រើន នៅក្នុងករណីណាមួយដូចខាងក្រោមៈ

១-កាលណាជនជាប់ចោទទទួលទោសពិន័យក្នុងឋានៈជាមូលទោសតែមួយគត់។

២-កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារដែលអតិបរមាស្មើ ឬ តិចជាង ៣ (បី) ឆ្នាំ។

កាលណាតុលាការសម្រេចជំនួសមូលទោសដោយទោសបន្ថែមមួយ ឬច្រើន តុលាការមិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬទោសពិន័យជាប្រាក់បានទេ [35]។ បទបញ្ញត្តិនេះមានន័យថា តុលាការអាចប្រកាសទោសបន្ថែមជំនួសឱ្យមូលទោសបានដោយមិនចាំបាច់ប្រកាសមូលទោសទេ កាលបើលក្ខខណ្ឌដែលច្បាប់តម្រូវបានបំពេញ។

**ឧទាហរណ៍៖** បទបរិហារកេរ្តិ៍ តុលាការអាចប្រកាសទោសបន្ថែមដែលមានចែងក្នុងមាត្រា ៣១០ ជំនួសឱ្យការប្រកាសមូលទោសដែលមានចែងក្នុងមាត្រា ៣០៥ ជាដើម។

### ២.២. ការប្រកាសទោសបន្ថែមចំពោះអនីតិជន

ដោយសារតែច្បាប់មិនអនុញ្ញាតឱ្យប្រកាសមូលទោសទៅលើអនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ដូច្នេះទោសបន្ថែមក៏ដូចគ្នាដែរ គឺមិនអាចប្រកាសទៅលើគាត់បានទេ។ ពីព្រោះថា ទោសបន្ថែម គឺជាទោសបន្ថែមទៅលើមូលទោស ផ្ទុយទៅវិញបើគ្មានការប្រកាសមូលទោសទេ ស្មើនឹងគ្មានការប្រកាសទោសបន្ថែមដូចគ្នាដែរ។ ដូច្នេះយើងខ្ញុំនឹងធ្វើការបកស្រាយចំពោះតែអនីតិជនដែលមានអាយុ ចាប់ពី១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម១៨ (ដប់ប្រាំបី) ឆ្នាំ តែប៉ុណ្ណោះ។

ក្នុងករណីតុលាការគ្មានជម្រើសណាមួយក្រៅពីសម្រេចផ្តន្ទាទោស ព្រហ្មទណ្ឌទៅលើអនីតិជន អាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅនោះទេ តុលាការក៏អាចសម្រេចប្រើប្រាស់នូវទោសបន្ថែមសម្រាប់អនីតិជនប្រភេទនេះបានផងដែរ។ ការប្រកាសទោសបន្ថែមចំពោះអនីតិជននេះ គឺប្រកាសដូចនឹងវិធីសាស្ត្រក្នុងការប្រកាសទោសបន្ថែមសម្រាប់នីតិជនដែរ ប៉ុន្តែខុសនៅត្រង់ថាទោសបន្ថែមដែលអាចយកទៅអនុវត្តចំពោះអនីតិជននេះមានត្រឹមតែ ៥ ចំណុចតែប៉ុណ្ណោះ។ ទោសបន្ថែមចំពោះអនីតិជននេះមានបញ្ញត្តិនៅក្នុងមាត្រា ១៦១ ដោយបានចែងថា មានតែទោសបន្ថែមដូចតទៅនេះប៉ុណ្ណោះ ដែលអាចអនុវត្តទៅលើអនីតិជនៈ

[35]មាត្រា ១០០ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

១- ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើក្នុងការប្រព្រឹត្ត បទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស។

២- ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។

៣- ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។

៤- ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែល បទល្មើសត្រូវបានប្រព្រឹត្ត។

៥- ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ[36]។

## ២.៣. ការប្រកាសទោសបន្ថែមចំពោះនីតិបុគ្គល

នៅក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល បើទោះបីជាទណ្ឌកម្មក្នុងឋានៈជាមូលទោសមិនមានការប្រកាសទោសដាក់ពន្ធនាគារ និងមានតែទោសពិន័យជាប្រាក់ក៏ដោយ ប៉ុន្តែមិនមានន័យថាគ្មានការប្រកាសទោសបន្ថែមនោះទេ។ នីតិបុគ្គលអាចត្រូវតុលាការប្រកាសទោសបន្ថែម ប្រសិនបើទោសនោះត្រូវបានចែងយ៉ាងជាក់លាក់ចំពោះបទល្មើសដែលចោទប្រកាន់[37]។ ការប្រកាសទោសបន្ថែមរបស់នីតិបុគ្គលក៏មានលក្ខណៈដូចគ្នានឹងការប្រកាសទោសបន្ថែមរបស់រូបវន្តបុគ្គលដែរ។ ដើម្បីអាចអាចប្រកាសទោសបន្ថែមបានលុះត្រាតែទោសបន្ថែមនេះមានចែងយ៉ាងជាក់លាក់ក្នុងច្បាប់ បើសិនជាមិនបានចែងជាក់លាក់ក្នុងច្បាប់ទេតុលាការមិនអាចធ្វើការប្រកាសទោសបន្ថែមនៅលើមូលទោសបានទេ។ ទោសបន្ថែមដែលត្រូវអនុវត្តចំពោះនីតិបុគ្គលមានចំនួន ១៤ ចំណុចដែលមាននៅក្នុងបញ្ញត្តិនៃមាត្រា ១៦៨ ដោយបានចែងថា ទោសបន្ថែមត្រូវអនុវត្តទៅលើនីតិបុគ្គលមានដូចតទៅៈ

១- ការរំលាយចោល។

២- ការដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ។

៣- ការហាមឃាត់ចំពោះការអនុវត្តសកម្មភាពមួយ ឬច្រើន។

៤- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ។

៥- ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃ។

៦- ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន ក្រៅពីឧបករណ៍អាចជួញដូរបាន ដែល

[36]មាត្រា ១៦១ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[37]មាត្រា ១៦៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

កំណត់ដោយធនាគារ។

៧- ការហាមឃាត់ចំពោះការប្រើបណ្ណទូទាត់។

៨- ការបិទគ្រឹះស្ថានដែលប្រើសម្រាប់ធ្វើការរៀបចំ ឬប្រព្រឹត្តបទល្មើស។

៩- ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់សាធារណជន ឬដែលបានប្រើប្រាស់ដោយសាធារណជន។

១០- ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើសម្រាប់ប្រព្រឹត្ត បទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស។

១១- ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។

១២- ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។

១៣- ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែល បទល្មើសបានប្រព្រឹត្ត។

១៤- ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស ការផ្សាយសេចក្ដីសម្រេច ផ្ដន្ទាទោសនៅក្នុងសារព័ត៌មានសរសេរឬការផ្សាយតាមមធ្យោបាយទូរគមនាគមន៍ សោតទស្សន៍។

បទប្បញ្ញត្តិដោយឡែកអាចបង្កើតទោសបន្ថែមដទៃទៀតបាន[38]។

## ៣. ការប្រកាសទោសជំនួស

ទោសជំនួស គឺជាទោសដែលតុលាការយកមកប្រកាសជំនួសឱ្យមូលទោស។ នៅពេលដែលតុលាការធ្វើការប្រកាសជំនួសទៅលើពិរុទ្ធជនរួចហើយ តុលាការមិនអាចប្រកាសការផ្ដន្ទាទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានទេ[39]។ យោងតាមក្រមព្រហ្មទណ្ឌ ទោសជំនួសមានពីរប្រភេទគឺ ការងារសហគមន៍ និងការស្ដីបន្ទោស ហើយទោសទាំងពីរនេះពុំអាចត្រូវបានតុលាការប្រកាសជាមួយគ្នាបានឡើយ។

### ៣.១. ទោសការងារសហគមន៍

ការងារសហគមន៍ គឺជាកាតព្វកិច្ចត្រូវបំពេញក្នុងចិរវេលាចន្លោះពី ៣០ ម៉ោង ទៅ២០០ ម៉ោង នូវការងារគ្មានកម្រៃជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គល នៃនីតិសាធារណៈផ្សេងៗទៀតដល់

[38]មាត្រា ១៦៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[39]មាត្រា ៩៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

សមាគម ឬដល់អង្គការមិនមែនរដ្ឋាភិបាល[40] ហើយការងារសហគមន៍ពុំអាចបំពេញជាប្រយោជន៍ដល់រូបវន្តបុគ្គលបានទេ[41]។ ការងារសហគមន៍ត្រូវតែស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ជាអាទិ៍ ការងារនៅពេលយប់ អនាម័យ សន្តិសុខ ហើយ និងការងាររបស់ស្ត្រី។ ការងារសហគមន៍ អាចត្រួតគ្នាបានជាមួយនឹងការអនុវត្តសកម្មភាពវិជ្ជាជីវៈ[42]។ ចំណែកឯសំណងការខូចខាតទៅលើជនរងគ្រោះដែលបង្កដោយជនជាប់ចោទ រដ្ឋត្រូវតែចេញសោហ៊ុយជួសជុលការខូចខាតដែលបង្កដល់អ្នកដទៃដោយទណ្ឌិតនៅក្នុងពេលដែលកំពុងអនុវត្តការងារសហគមន៍។ រដ្ឋត្រូវធ្វើឧបាទេសកម្មដោយពេញច្បាប់ទៅក្នុងសិទ្ធិជនរងគ្រោះ[43] នៅពេលដែលតុលាការប្រកាសទោសការងារសហគមន៍ទៅលើទណ្ឌិតនោះ រដ្ឋត្រូវចេញសងការខូចខាតដែលទណ្ឌិតនោះបានបង្កឡើងទៅឱ្យជនរងគ្រោះដោយពេញច្បាប់។

### ៣.១.១. ទោសការងារសហគមន៍សម្រាប់នីតិជន

តុលាការអាចប្រកាសទោសការងារសហគមន៍បានកាលណាជនជាប់ចោទត្រូវទទួលការផ្តន្ទាទោសដាក់ពន្ធនាគារដែលអតិបរមាតិចជាង ឬ ស្មើនឹង ៣ ឆ្នាំ។ ទោសការងារសហគមន៍ នឹងអាចប្រកាសបាន លុះត្រាតែជនជាប់ចោទមានវត្តមាននៅពេលសវនាការហើយយល់ព្រមធ្វើការងារនេះផងដែរ។ តុលាការ នៅមុនពេលប្រកាសសាលក្រម ឬ សាលដីកា ត្រូវប្រាប់ជនជាប់ចោទថា សាមីខ្លួន មានសិទ្ធិប្រកែក មិនព្រមធ្វើការងារនេះ។ ចម្លើយរបស់ជនជាប់ចោទ ត្រូវតែមានចុះនៅក្នុងសាលក្រម ឬ សាលដីកា[44]។ ទោសការងារសហគមន៍ ត្រូវកំណត់ចិរវេលានៃការងារ និងរយៈពេល ដែលត្រូវបំពេញ។ រយៈពេលនៃការធ្វើការងារសហគមន៍នេះ មិនអាចលើសពី ១ ឆ្នាំទេ[45]។

**ឧទាហរណ៍៖** លោក **ក** បានប្រព្រឹត្តបទប្រទូស្តកេរខ្មាស ដែលត្រូវផ្តន្ទាទោសតាម មាត្រា ២៤៦ នៃក្រមព្រហ្មទណ្ឌ ឱ្យជាប់ពន្ធនាគារពី ១ ឆ្នាំ ទៅ ៣ ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ លានរៀល ទៅ ៦.០០០.០០០ លានរៀល។ ក្នុងករណីនេះ អតិបរមានៃ ទោសដាក់ពន្ធនាគារ សម្រាប់ជនជាបចោទគឺ ៣ ឆ្នាំ។ ដូចនេះ តុលាការ អាចប្រកាសទោស ការងារសហគមន៍ ជំនួសឱ្យការប្រកាសមូលទោសដែលបានចែងនៅក្នុងមាត្រា ២៤៦ នៃក្រម ព្រហ្មទណ្ឌបាន។ តុលាការអាចសម្រេចឱ្យលោក **ក** ធ្វើការងារសហគមន៍ចំនួន ១៥០ ម៉ោង សម្រាប់អំឡុងពេល ២ ខែ ដោយមិនឱ្យលោក **ក** ទទួលរងនូវការផ្តន្ទាទោសដាក់ពន្ធនាគារ ឬ ទោស

[40]មាត្រា ៧២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩
[41]មាត្រា ៧៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩
[42]មាត្រា ៧៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩
[43]មាត្រា ៧៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩
[44]មាត្រា ១០១ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩
[45]មាត្រា ១០២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

ពិន័យជាប្រាក់ឡើយ ចំពោះបទប្រទូស្តកេរខ្មាសនេះទេ។ ប្រសិនបើតុលាការ ប្រកាសទោសការងារសហគមន៍ដោយមានការយល់ព្រមពីជនជាប់ចោទ នៅក្នុងសវនាការរួចហើយ ទណ្ឌិត ត្រូវតែគោរពកាតព្វកិច្ចធ្វើការងារដែលកើតចេញពីការងារសហគមន៍ដោយខានមិនបាន។ ប្រសិនបើទណ្ឌិតបានធ្វើអំពើបំពានលើកាតព្វកិច្ចដែលជាលទ្ធផលនៃទោសការងារសហគមន៍ នឹងត្រូវ ផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ លានរៀល ទៅ ៤.០០០.០០០ លានរៀល[46]។

### ៣.១.២. ទោសការងារសហគមន៍សម្រាប់អនីតិជន

ទោសដែលជាការងារសហគមន៍ អាចអនុវត្តទៅលើអនីតិជនដែលមានអាយុ យ៉ាងតិច ១៦ (ដប់ប្រាំមួយ) ឆ្នាំ ពោលគឺអនីតិជនដែលមានចន្លោះអាយុចាប់ពីត្រឹម១៦ (ដប់ ប្រាំមួយ) ឆ្នាំដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ហើយថិរវេលានៃការងារមិនអាចលើសពី ១០០ (មួយរយ) ម៉ោងបានឡើយ។

ការងារសហគមន៍ត្រូវតែសម្របសម្រួលទៅលើអនីតិជន ដោយមានលក្ខណៈជាការបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ[47] មានន័យទោសការងារសហគមន៍របស់អនីតិជន ត្រូវគិតគូរតែចំពោះការងារ ទាំងឡាយណាដែលមានលក្ខណៈជាការអប់រំបណ្តុះបណ្តាល ឬ ការងារណាដែលមានប្រយោជន៍ដល់ការលូតលាស់ទាំងផ្នែកបញ្ញា ស្មារតី រាងកាយ ពិសេសផ្តល់នូវចំណេះដឹងដល់អនីតិជននោះទើបអាចប្រកាសបាន។ ចំពោះបែបបទនៃការអនុវត្តទោសការងារសហគមន៍ ត្រូវកំណត់ដោយព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាចង្អុលប្រាប់ឈ្មោះនីតិបុគ្គលដែលត្រូវទទួលអត្ថប្រយោជន៍ពីការងារនេះ។ ទោសនេះត្រូវអនុវត្តនៅក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា[48] ពោលគឺព្រះរាជអាជ្ញាត្រូវណែនាំដល់ទណ្ឌិត អំពីការអនុវត្តការងារសហគមន៍ និងកាតព្វកិច្ចដែលត្រូវអនុវត្ត ក៏ដូចជាណែនាំដល់នីតិបុគ្គល និងត្រូវរៀបចំបែបបទ និងការអនុវត្តទោសនេះដល់នីតិបុគ្គលនោះជាអាទិ៍ផងដែរ។

### ៣.២. ទោសស្តីបន្ទោស

ការស្តីបន្ទោស គឺតុលាការអាចប្រកាសការស្តីបន្ទោស កាលបើពិរុទ្ធជនត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារដែលមានអតិបរមាតិចជាង ឬ ស្មើនឹង ៣ ឆ្នាំ តុលាការអាចប្រកាសស្តីបន្ទោស ប្រសិនបើមានគ្រប់លក្ខខណ្ឌទាំង ៣ ដូចតទៅនេះ ៖

១. ភាពចលាចល ដល់សណ្តាប់ធ្នាប់សាធារណៈ ដែលបណ្តាលមកពីបទល្មើសបានបញ្ចប់។

[46]មាត្រា ៥៨៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩
[47]មាត្រា ១៦២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩
[48]មាត្រា ១០៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

២. ការខូចខាត ត្រូវបានជួសជុលរួចហើយ និង

៣. ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ[49]។

ទោសស្ដីបន្ទោសនេះ គឺប្រើប្រាស់សម្រាប់ស្ថានភាពបទល្មើសដែលមានលក្ខណៈមិនធ្ងន់ធ្ងរ ពេលមានបទល្មើសកើតឡើងមិនមានការប៉ះពាល់ធ្ងន់ធ្ងរដែលបង្ករឱ្យមានចលាចលទៅដល់សណ្ដាប់ធ្នាប់សាធារណៈ មានន័យថា គឺជាបទល្មើសតូចតាច។ ក្រោយពេលប្រព្រឹត្តបទល្មើសរួចហើយ ជនល្មើសបានសំដែងនូវការព្យាយាមជួសជុលនូវព្យសនកម្មសំរាប់ផ្ដល់សោហ៊ុយជំងឺចិត្តដល់ជនរងគ្រោះ ហើយគាត់បង្ហាញពីឆន្ទៈថាគាត់មានវិប្បដិសារី មានការសោកស្ដាយចំពោះកំហុសដែលបានប្រព្រឹត្តបទល្មើសនោះ ហើយទើបតែបានប្រព្រឹត្តនូវបទល្មើសនេះជាលើកទី ១ ដែលជាបទល្មើសលហុជាដើម ហើយគាត់បានធានាអះអាងថាលើកក្រោយគាត់មិនប្រព្រឹត្តបែបនេះទៀតទេ ហើយគាត់សុខចិត្តរៀនសូត្រ អប់រំកែប្រែខ្លួនឯងដើម្បីអាចចូលទៅរួមរស់នៅក្នុងសង្គមរបស់ខ្លួនវិញបាន។ នៅពេលលក្ខខណ្ឌទាំងបីខាងលើត្រូវបានបំពេញ តុលាការអាចពិចារណាប្រកាសដាក់ទោសការស្ដីបន្ទោសនេះ ដោយតុលាការត្រូវពិនិត្យនូវលក្ខខណ្ឌទាំងបីនេះដែលត្រូវតែបំពេញដោយត្រួតគ្នា។ **ឧទាហរណ៍ទី១ ៖** ឈ្មោះ **គ** បានចូលបរិភោគអាហារ នៅក្នុងភោជនីយដ្ឋានមួយ ដោយដឹងថាខ្លួន មិនមានប្រាក់បង់ទេ។ អំពើនេះគឺជាបទបន្លំ។ ជំនួសឱ្យការប្រកាសទោសដាក់ ពន្ធនាគារ និងពិន័យជាប្រាក់ តុលាការ សម្រេចប្រកាសការស្ដីបន្ទោសទៅលើឈ្មោះ **គ** បន្ទាប់ពីឈ្មោះ **គ** បានយល់ព្រមទទួលកំហុសរបស់ខ្លួនហើយគ្រួសាររបស់ឈ្មោះ **គ** បានបង់ថ្លៃអាហារឱ្យម្ចាស់ភោជនីយដ្ឋានរួចហើយ។

[49]មាត្រា ៧៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

# ជំពូកទី២

# របបនៃការព្យួរទោស

# ជំពូកទី២

# របបនៃការព្យួរទោស

ការព្យួរទោស គឺជាកាផ្អាក់ការអនុវត្តមូលទោស (ទោសពន្ធនាគារ និងទោសពិន័យជាប្រាក់)[50] ទៅលើពិរុទ្ធជន។ តុលាការ ប្រើប្រាស់ឆន្ទានុសិទ្ធិរបស់គាត់ដើម្បីធ្វើការសម្រេចដោយប្រុងប្រយ័ត្ន ថាគួរអនុញ្ញាតឱ្យព្យួរ ឬមិនព្យួរដែលត្រូវតែពិនិត្យពិច័យទៅលើលក្ខខណ្ឌនានាដែលមានចែងកំណត់ឱ្យយ៉ាងជាក់លាក់ក្នុងច្បាប់។ ដើម្បីអនុវត្តបទប្បញ្ញត្តិស្ដីពីការព្យួរទោស ត្រូវគិតគូរតែអំពីការផ្តន្ទាទោសជាស្ថាពរខាងបណ្តឹងអាជ្ញាតែប៉ុណ្ណោះ[51] មានន័យថា ទាល់តែទណ្ឌកម្មព្រហ្មទណ្ឌត្រូវបានប្រកាសចូលជាស្ថាពររួចហើយ ទើបអាចអនុវត្តបទប្បញ្ញត្តិស្ដីពីការព្យួរទោសនេះបាន។ នៅក្នុងក្រមព្រហ្មទណ្ឌ បានចែកការព្យួរទោសជាពីរប្រភេទ គឺការព្យួរទោសធម្មតា និងការព្យួរទោសសាកល្បង។

## ផ្នែកទី១ ការព្យួរទោសធម្មតា

ការព្យួរទោសធម្មតា គឺជាការផ្អាក់ការអនុវត្តមូលទោសទៅលើពិរុទ្ធជនដោយមិនមានការអនុវត្តនូវវិធានការត្រួតពិនិត្យ និងកាតព្វកិច្ចដោយឡែក។ ការព្យួរទោសធម្មតាអាចការព្យួរទោសទាំងស្រុង និងមួយផ្នែកបានដោយតុលាការអាចសម្រេចថា ការព្យួរទោសធម្មតានេះអាចនឹងអនុវត្តទៅលើមួយផ្នែកនៃទោសពន្ធនាគារ ដែលតុលាការជាអ្នកកំណត់ចិរវេលា ឬលើមួយផ្នែកនៃប្រាក់ពិន័យដែលតុលាការជាអ្នកកំណត់ចំនួនទឹកប្រាក់[52]។

### ១. លក្ខខណ្ឌនៃការព្យួរទោសធម្មតា

លក្ខខណ្ឌនៃការព្យួរទោសធម្មតានេះ មានការប្រែប្រួលទៅតាមប្រភេទនៃបទល្មើសដែលត្រូវចោទប្រកាន់ថាជា បទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ។

#### ១.១. ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម

ដើម្បីអាចធ្វើការព្យួរទោសធម្មតាចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិមបានពិរុទ្ធជនត្រូវបំពេញលក្ខខណ្ឌពីរ គឺទាក់ទងនឹង ប្រវត្តិទោសពីមុន និងទោសអនុវត្តថ្មី។

- **ប្រវត្តិទោសពីមុន**

ក្នុងករណីដែលមានការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈឹមនោះ ការព្យួរទោសធម្មតាអាចត្រូវផ្តល់ឱ្យ

[50]មាត្រា ១០៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[51]មាត្រា ១០៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[52]មាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

បាន ប្រសិនបើជនជាប់ចោទមិនទាន់មានការផ្តន្ទាទោសជាស្ថាពរជាប់ពន្ធនាគារក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំមុនអំពើល្មើស[53] ក្នុងកំឡុងពេល ៥ ឆ្នាំមុនអំពើល្មើសបានកើតឡើងជនជាប់ចោទមិនដែលត្រូវបានតុលាការផ្តន្ទាទោសណាមួយជាស្ថាពរពីមុនមកទេ។

- **ទោសអនុវត្តថ្មី**

ការព្យួរទោសធម្មតា ត្រូវអនុវត្តទៅលើទោសដូចតទៅ ៖

១-ទោសដាក់ពន្ធនាគារ កាលបើទោសដែលប្រកាសនោះតិចជាង ឬស្មើនឹង ៥ (ប្រាំ) ឆ្នាំ។

២-ទោសពិន័យជាប្រាក់[54]។

មានន័យថា ចំពោះទោសអនុវត្តថ្មីនេះ ការព្យួរទោសធម្មតាអាចត្រូវផ្តល់ឱ្យបាន ប្រសិនបើទោសដែលប្រកាសនោះមិនលើសពី ៥ (ប្រាំ) ឆ្នាំ។ **ឧទាហរណ៍៖** កាលពីថ្ងៃ ០១ ខែមករា ឆ្នាំ២០១៥ លោក **ក** បានប្រព្រឹត្តបទល្មើស **លួច** តុលាការប្រកាសផ្តន្ទាទោសជាស្ថាពរឱ្យជាប់ពន្ធនាគារក្នុងរយៈពេល ២ ឆ្នាំ។ ក្រោយចេញពីពន្ធនាគារវិញ លុះនៅថ្ងៃទី ០១ ខែ មករា ឆ្នាំ២០២១ លោក **ក** បានប្រព្រឹត្តបទល្មើសជាថ្មីម្តងទៀតពីបទ **លួចមានស្ថានទម្ងន់ទោស** ដោយតុលាការប្រកាសផ្តន្ទាទោសជាស្ថាពរឱ្យជាប់ពន្ធនាគារក្នុងរយៈពេល ៤ ឆ្នាំ។

ក្នុងករណីនេះបើយើងពិចារណាអំពីលក្ខខណ្ឌនៃការព្យួរទោសធម្មតាចំពោះបទឧក្រិដ្ឋ ឬ បទមជ្ឈិម យើងឃើញថា ប្រវត្តិទោសពីមុនរបស់ លោក **ក** មិនស្ថិតក្នុងកំឡុងពេល ៥ ឆ្នាំមុនពេលគាត់ប្រព្រឹត្តបទល្មើសថ្មីទេ មានន័យថាពីថ្ងៃ០១ ខែមករា ឆ្នាំ២០១៥ ដល់ថ្ងៃទី ០១ ខែ មករា ឆ្នាំ២០២១ គឺវាមានរយៈពេល ៦ ឆ្នាំ ដូច្នេះលក្ខខណ្ឌទាក់ទងនឹងប្រវត្តិទោសពីមុន លោក **ក** បានបំពេញ។ ចំពោះលក្ខខណ្ឌទាក់ទងនឹងទោសអនុវត្តថ្មីវិញក៏បានបំពេញដូចគ្នាដែរដោយតុលាការប្រកាសផ្តន្ទាទោសជាស្ថាពរឱ្យជាប់ពន្ធនាគារក្នុងរយៈពេល ៤ ឆ្នាំ ពោលគឺ ទោសដែលប្រកាសនោះមិនលើសពី ៥ ឆ្នាំ។ ដោយហេតុថាលក្ខខណ្ឌទាំងពីរបានបំពេញ ដូច្នេះលោក **ក** អាចត្រូវបានតុលាការផ្តល់ការព្យួរទោសធម្មតាឱ្យបាន។ **ឧទាហរណ៍៖** កាលពីថ្ងៃ ០១ ខែមករា ឆ្នាំ២០១៥ លោក **ខ** បានប្រព្រឹត្តបទល្មើស **បង្កឱ្យមានរបួសស្នាមដោយអចេតនា** តុលាការប្រកាសផ្តន្ទាទោសជាស្ថាពរឱ្យជាប់ពន្ធនាគារក្នុងរយៈពេល ១ ឆ្នាំ។ ក្រោយចេញពីពន្ធនាគារវិញ លុះនៅថ្ងៃទី ០១ ខែ មករា ឆ្នាំ២០១៩ លោក **ខ** បានប្រព្រឹត្តបទល្មើសជាថ្មីម្តងទៀតពីបទ **លួច** ដោយតុលាការប្រកាសផ្តន្ទាទោសជាស្ថាពរឱ្យជាប់ពន្ធនាគារក្នុងរយៈពេល ២ ឆ្នាំ។

[53]មាត្រា ១០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[54]មាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

### ១.២. ចំពោះបទលហុ

ដូចគ្នានឹងបទឧក្រិដ្ឋ ឬបទមជ្ឈិមដែរពោល គឺដើម្បីអាចធ្វើការព្យួរទោសធម្មតាចំពោះបទលហុបានពិរុទ្ធជនត្រូវបំពេញលក្ខខណ្ឌ ពីរ គឺទាក់ទងនឹង ប្រវត្តិទោសពីមុន និងទោសអនុវត្តថ្មី។

- **ប្រវត្តិទោសពីមុន**

ក្នុងករណីចោទប្រកាន់ពីបទលហុ ការព្យួរទោសធម្មតាអាចត្រូវបានប្រកាស ប្រសិនបើជនជាប់ចោទ មិនទាន់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារជាស្ថាពរនៅឡើយ នៅក្នុងរយៈពេល ១ (មួយ) ឆ្នាំ មុនបទល្មើសនេះ[55] មានន័យថាក្នុងកំឡុងពេល ១ ឆ្នាំមុនបទល្មើសបានកើតឡើងជនជាប់ចោទមិនដែលត្រូវបានតុលាការផ្តន្ទាទោសណាមួយជាស្ថាពរពីមុនមកទេ។

- **ទោសអនុវត្តថ្មី**

ក្នុងករណីចោទប្រកាន់ពីបទលហុ ការព្យួរទោសធម្មតាត្រូវអនុវត្តទៅលើទោស ដូចតទៅនេះ ៖

១- ទោសដាក់ពន្ធនាគារ។

២- ទោសពិន័យជាប្រាក់[56]។

មានន័យថា ចំពោះទោសអនុវត្តថ្មីនេះការព្យួរទោសធម្មតាអាចត្រូវផ្តល់ឱ្យបាន ប្រសិនបើទោសដែលប្រកាសនោះតិចជាង ឬស្មើនឹង ៦ (ប្រាំមួយ) ថ្ងៃ ពោល គឺមិនលើសពី ៦ (ប្រាំមួយ) ថ្ងៃ។

## ២. ការដកហូត និងការមិនដកហូតការព្យួរទោសធម្មតា

### ២.១. ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម

ប្រសិនបើក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីបទ ឧក្រិដ្ឋ ឬបទមជ្ឈិម ដោយមានការព្យួរទោសធម្មតា ហើយមានការផ្តន្ទាទោសថ្មីជាស្ថាពរមួយទៀតពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ការព្យួរទោសធម្មតានេះ ត្រូវដកហូតចេញដោយពេញច្បាប់។ ទោសទី ១ ត្រូវអនុវត្តដោយគ្មានស្រូបជាមួយទោសទី ២ ឡើយ[57]។ ការព្យួរទោសធម្មតាចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិមនឹងត្រូវបានដកហូត កាលបើជននោះបានប្រព្រឹត្តបទល្មើសបន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរក្នុងកំឡុងពេល ៥ ឆ្នាំពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយទោសទី ១ និងទោសទី ២ ត្រូវអនុវត្តតាមទៅគោលការណ៍បូកទោសដែលបានចែងក្នុងបញ្ញត្តិនៃមាត្រា ១៤០ ពោលគឺត្រូវ

---

[55]មាត្រា ១១២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[56]មាត្រា ១១៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[57]មាត្រា ១០៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

បូកទោសទាំងពីរបញ្ចូលគ្នាតែម្តង។ តុលាការអាចសម្រេចថា ការផ្តន្ទាទោសថ្មីមិននាំឱ្យមានការដកហូតនូវការព្យួរទោសធម្មតាចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលបានសម្រេចពីមុននោះទេ។ សេចក្តីសម្រេចរបស់តុលាការត្រូវតែមាន សំអាងហេតុជាពិសេស[58]។ តុលាការអាចសម្រេចមិនដកហូតការព្យួរទោសមកវិញទេ បើទោះបីជាមានការផ្តន្ទាទោសស្ថាពរថ្មីមួយទៀតក៏ដោយ ហើយតុលាការត្រូវតែសរសេរសំអាងហេតុពិសេសនៅក្នុងសេចក្តីសម្រេច។

### ២.២. ចំពោះបទលហុ

ប្រសិនបើក្នុងរយៈពេល ១ (មួយ) ឆ្នាំ ក្រោយការផ្តន្ទាទោសជាស្ថាពរពី បទលហុដោយមានការព្យួរទោសធម្មតាផង រួចកើតមានការផ្តន្ទាទោសថ្មីជាស្ថាពរ ពីបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ការព្យួរទោសធម្មតានេះត្រូវដកហូតចេញដោយ ពេញច្បាប់។ ទោសទី ១ ត្រូវអនុវត្តដោយគ្មានស្រូបជាមួយទោសទី ២ ឡើយ[59]។ ចំពោះបទលហុនេះក៏មានលក្ខណៈប្រហាក់ប្រហែល នឹងបទឧក្រិដ្ឋ ឬ បទមជ្ឈិមដែរ ការព្យួរទោសធម្មតាចំពោះបទលហុនឹងត្រូវបានដកហូត កាលបើជននោះបានប្រព្រឹត្តបទល្មើសបន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរក្នុងកំឡុងពេល ១ ឆ្នាំពីបទលហុ ហើយទោសទី ១ និងទោសទី ២ ត្រូវអនុវត្តតាមទៅគោលការណ៍បូកទោសដែលបានពោលគឺត្រូវបូកទោសទាំងពីរបញ្ចូលគ្នាតែម្តង។ តុលាការអាចសម្រេចថា ការផ្តន្ទាទោសថ្មីមិននាំឱ្យមានការដកហូតនូវការព្យួរទោសធម្មតាចំពោះបទលហុដែលបានសម្រេចពីមុននោះទេ។ សេចក្តីសម្រេចរបស់តុលាការត្រូវតែមាន សំអាងហេតុជាពិសេស[60]។ តុលាការអាចសម្រេចមិនដកហូតការព្យួរទោសមកវិញទេ បើទោះបីជាមានការផ្តន្ទាទោសស្ថាពរថ្មីមួយទៀតក៏ដោយ ហើយតុលាការត្រូវតែសរសេរសំអាងហេតុពិសេសនៅក្នុងសេចក្តីសម្រេច។

## ៣. ការទុកជាអសារបង់នូវការផ្តន្ទាទោស

### ៣.១. ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម

ប្រសិនបើរយៈពេល ៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដោយមានកាព្យួរទោសធម្មតា ហើយគ្មានការផ្តន្ទាទោសថ្មីជាស្ថាពរមួយទៀត ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះទេ ការផ្តន្ទាទោសដោយមានព្យួរនេះត្រូវ ចាត់ទុកថាជាអសារបង់។ ទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ។

កាលណាបើការព្យួរទោសត្រូវបានប្រកាសទៅលើតែផ្នែកមួយនៃទោសនោះ ការផ្តន្ទាទោសត្រូវចាត់ទុកជា

---

[58]មាត្រា ១១០ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[59]មាត្រា ១១៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[60]មាត្រា ១១៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

អសារបង់ទាំងស្រុង។ ទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ[61]។ បានន័យថា បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដោយមានការព្យួរទោសធម្មតា កាលបើមិនមានការប្រព្រឹត្តបទល្មើសថ្មីបន្ទាប់ពីផ្តន្ទាទោសក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ ការផ្តន្ទាទោសដោយមានព្យួរនេះត្រូវ ចាត់ទុកថាជាអសារបង់ ហើយទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ។ ចំណែកឯការព្យួរទោសដែលត្រូវបានប្រកាសទៅលើតែផ្នែកមួយនៃទោសនោះ ការផ្តន្ទាទោសត្រូវចាត់ទុកជាអសារបង់ទាំងស្រុងតែម្តង ពោលគឺទោសក៏មិនអាចយកមកអនុវត្តបានតទៅទៀតដូចគ្នា។

### ៣.២. ចំពោះបទលហុ

ប្រសិនបើក្នុងរយៈពេល ១ (មួយ) ឆ្នាំ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីបទលហុដែលមានការព្យួរទោសធម្មតា គ្មានការផ្តន្ទាទោសថ្មីណាមួយបានកើត ឡើងពីបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ការផ្តន្ទាទោសដែលព្យួរនោះ ត្រូវទុកជាអសារបង់។ ទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ[62]។ បន្ទាប់ពីការផ្តន្ទាទោស ជាស្ថាពរពីបទលហុដោយមានការព្យួរទោសធម្មតា កាលបើមិនមានការប្រព្រឹត្តបទល្មើសថ្មីបន្ទាប់ពី ផ្តន្ទាទោសក្នុងរយៈពេល ១ (ប្រាំ) ឆ្នាំ ការផ្តន្ទាទោសដោយមានព្យួរនេះត្រូវចាត់ទុកថាជាអសារបង់ ហើយទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ។

## ផ្នែកទី២ ការព្យួរទោសសាកល្បង

ការព្យួរទោសសាកល្បង គឺជាការផ្អាក់ការអនុវត្តមូលទោសទៅលើទណ្ឌិតដោយស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងត្រូវគោរពកាតព្វកិច្ចដោយឡែកមួយឬ ច្រើនក្នុងរយៈពេលនៃការសាកល្បងនេះ។

### ១. លក្ខខណ្ឌ នៃការព្យួរទោសសាកល្បង

តុលាការអាចសម្រេចព្យួរសាកល្បងនូវទោសដែលបានសម្រេចដាក់ពន្ធនាគារ ដែលមានរយៈពេលពី ៦ (ប្រាំមួយ) ខែ ទៅ ៥ (ប្រាំ) ឆ្នាំ ។ ការព្យួរទោសសាកល្បង មានអានុភាពដាក់ឱ្យទណ្ឌិតស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងគោរពនូវកាតព្វកិច្ចដោយឡែកមួយ ឬច្រើនក្នុងរយៈពេលសាកល្បង[63]។ ដើម្បីអាចទទួលបានការព្យួរទោសសាកល្បងទោសដែលតុលាការផ្តន្ទាទោស មិនត្រូវតិចជាង ៦ ខែ និង លើស ៥ ឆ្នាំទេ ហើយត្រូវស្ថិតនៅក្រោមវិធានការ ត្រួតពិនិត្យ និងគោរពនូវកាតព្វកិច្ចដោយឡែកមួយ ឬច្រើន តាមដែលតុលាការដាក់ឱ្យ។ យើងបានដឹងរួចមកហើយថា ការព្យួរទោសធម្មតាអាចការព្យួរទោសទាំងស្រុង និងមួយផ្នែកដោយឡែកការព្យួរ

---

[61]មាត្រា ១១១ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[62]មាត្រា ១១៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[63]មាត្រា ១១៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

ទោសសាកល្បង គឺអាចធ្វើការព្យួរទោសតែតាមរយៈពេលទេ ដោយរយៈពេលនៃការព្យួរទោសសាកល្បង គឺមិនអាចតិចជាង ១ (មួយ) ឆ្នាំ និងមិនលើសពី ៣ (បី) ឆ្នាំទេ[64]។

**ឧទាហរណ៍៖** តុលាការធ្វើការប្រកាសផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ២ ឆ្នាំ ចំពោះលោក **ក** ។ ក៏ប៉ុន្តែទោសនេះ ត្រូវបានតុលាការអនុញ្ញាតឱ្យព្យួរទោសសាកល្បងដោយតុលាការបានកំណត់អំពីវិធានការត្រួតពិនិត្យ និងកាតព្វកិច្ចដោយឡែកឱ្យលោក **ក** អនុវត្ត ដោយរយៈពេលនៃការព្យួរទោសាកល្បង គឺ ១៤ ខែ ដែលតុលាការបានសរសេរនៅក្នុងសេចក្តីសម្រេចរបស់គាត់។ ដូច្នេះហើយប្រសិនបើជាផុតរយៈពេល ១៤ ខែ លោក **ក** បានគោរពវិធានការត្រួតពិនិត្យ ឬ បំពេញ កាតព្វកិច្ចដោយឡែកបានចប់សព្វគ្រប់ហើយ ទោសដែលត្រូវបានតុលាការប្រកាសផ្តន្ទាទោសដាក់ ពន្ធនាគារចំនួន ២ ឆ្នាំ គឺមិនអាចយកអនុវត្តបានទៀតទេ។

## ២. វិធានការត្រួតពិនិត្យ និងកាតព្វកិច្ចដោយឡែក

### ២.១. វិធានការត្រួតពិនិត្យ

វិធានការត្រួតពិនិត្យ ជាវិធានការដែលមានលក្ខណៈបង្ខំឱ្យទណ្ឌិតត្រូវតែគោរពកាតព្វកិច្ចមួយ ឬច្រើនដើម្បីជាប្រយោជន៍របស់ទណ្ឌិតខ្លួននិងសង្គម ដោយមានកំណត់បញ្ជាក់ឱ្យបានត្រឹមត្រូវនូវការផ្លាស់ប្តូរអាស័យដ្ឋាន មុខរបរ ការធ្វើដំណើរ និងការបញ្ជាក់សំណុំឯកសារផ្សេងៗដើម្បីដាក់ជូនព្រះរាជអាជ្ញា ឬបុគ្គលដែលព្រះរាជអាជ្ញាប្រគល់អំណាចឱ្យដើម្បីផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវ នូវស្ថានភាពនៃការអនុវត្តកាតព្វកិច្ចរបស់ទណ្ឌិត។

វិធានការត្រួតពិនិត្យមានចំនួន ៦ (ប្រាំមួយ) ចំណុចដោយចែងនៅក្នុងបញ្ញត្តិនៃមាត្រា ១១៩ បានចែងថា វិធានការត្រួតពិនិត្យដែលតម្រូវទៅលើទណ្ឌិត មានដូចតទៅ ៖

១- ទណ្ឌិតត្រូវតែគោរពតាមដីកាកោះរបស់ព្រះរាជអាជ្ញា ឬរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ។

២- ទណ្ឌិតត្រូវមកទទួលនូវការមកពិនិត្យមើលរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ។

៣- ទណ្ឌិតត្រូវប្រគល់ដល់ព្រះរាជអាជ្ញា ឬដល់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ នូវគ្រប់ឯកសារសម្រាប់ធ្វើការផ្ទៀងផ្ទាត់លើការបញ្ចូលឱ្យទៅ រស់នៅក្នុងសង្គមវិញ។

៤- ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរអាសយដ្ឋានរបស់ខ្លួន។

៥- ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរមុខរបររបស់ខ្លួន។

[64]មាត្រា ១១៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

៦- ទណ្ឌិតត្រូវតែមានការអនុញ្ញាតពីព្រះរាជអាជ្ញា មុនពេលធ្វើដំណើរទៅបរទេស[65]។

វិធានការត្រួតពិនិត្យទាំង ៦ (ប្រាំមួយ) ចំណុចដែលបានលើកឡើងខាងលើនេះ តុលាការនឹងជ្រើសរើសយកវិធានការត្រួតពិនិត្យមួយ ឬ ច្រើនដើម្បីដាក់ឱ្យទណ្ឌិតបំពេញ ហើយទណ្ឌិត ត្រូវតែអនុវត្តតាមដាច់ខាតបើពុំនោះទេនឹងក្លាយជាមូលហេតុដែលបណ្តាលឲ្យការព្យួរទោសសាកល្បងនេះត្រូវបានដកហូត។

## ២.២. កាតព្វកិច្ចដោយឡែក

កាតព្វកិច្ចដោយឡែក គឺជាវិធានបង្ខំឱ្យទណ្ឌិតគោរពនូវកាតព្វកិច្ចមួយ ឬច្រើន ដោយមានចង្អុលប្រាប់កាតព្វកិច្ច នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនដើម្បីជាប្រយោជន៍ដល់ទណ្ឌិត និងសង្គម។ ក្នុងក្រមព្រហ្មទណ្ឌបានកំណត់អំពីកាតព្វកិច្ចដោយឡែករបស់ទណ្ឌិតជាអនីតិជន និងកាតព្វកិច្ចដោយឡែករបស់ទណ្ឌិតជាអនីតិជន។

### ២.២.១. កាតព្វកិច្ចដោយឡែករបស់ទណ្ឌិតជាអនីតិជន

កាតព្វកិច្ចដោយឡែករបស់ទណ្ឌិតដែលជានីតិជនមានចំនួន ១៣ (ដបបី) ចំណុចដោយចែងនៅក្នុងបញ្ញត្តិនៃមាត្រា ១២០ បានចែងថា កាតព្វកិច្ចដោយឡែកដែលអាចតម្រូវទៅលើទណ្ឌិតមានដូចតទៅ ៖

១- បំពេញសកម្មភាពខាងវិជ្ជាជីវៈ។

២- ទទួលការបង្ហាត់បង្រៀន ឬទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ។

៣- រស់នៅក្នុងទីកន្លែងណាមួយជាកំណត់។

៤- ទទួលឱ្យពេទ្យធ្វើការពិនិត្យ ឬការព្យាបាល។

៥- បញ្ជាក់ថាខ្លួនរួមចំណែកក្នុងការចិញ្ចឹមបីបាច់គ្រួសារ។

៦- ធ្វើការជួសជុលការខូចខាតដែលបណ្តាលមកពីបទល្មើស តាមលទ្ធភាពនៃ ធនធានរបស់ខ្លួន។

៧- បញ្ជាក់ថាខ្លួន បានបង់ប្រាក់ជូនរដ្ឋបន្ទាប់ពីការផ្តន្ទាទោស តាមលទ្ធភាព ធនធានរបស់ខ្លួន។

៨- មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈឬសង្គមដែលអនុញ្ញាត ឬសម្រួលដល់ការ ប្រព្រឹត្តបទល្មើស។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីសកម្មភាពដែលហាមឃាត់។

៩- មិនត្រូវមានមុខនៅទីកន្លែងខ្លះ។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីទីកន្លែង ដែលហាមឃាត់។

១០- មិនត្រូវសេពគប់បនល្បែង។

[65] មាត្រា ១១៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

១១- មិនត្រូវសេពគប់គ្រឿងភេសជ្ជៈស្រវឹង។

១២- មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ពិសេស ចារី សហចារី អ្នកផ្ដើមគំនិត អ្នកសមគំនិត ឬ ជនរងគ្រោះនៃបទល្មើស។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពី បុគ្គលដែលមិនត្រូវសេពគប់ជាមួយ។

១៣- មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ ប្រភេទ។

នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនតុលាការត្រូវចែងអំពីកាតព្វកិច្ចដោយឡែក ដែលតម្រូវទៅលើទណ្ឌិត[66]។

ដូចគ្នានឹងវិធានការត្រួតពិនិត្យដែរ ក្នុងចំណោមកាតព្វកិច្ចដោយឡែកចំនួន ១៣ (ដបបី) ចំណុចខាងលើនេះ តុលាការនឹងជ្រើសរើសយកកាតព្វកិច្ចដោយឡែកមួយមួយ ឬ ច្រើន មកដាក់ឱ្យទណ្ឌិតគោរពតាម ហើយនៅក្នុងសេចក្ដីសម្រេចតុលាការត្រូវចែងអំពីកាតព្វកិច្ចដោយឡែកដែលតម្រូវទៅលើទណ្ឌិត។ ទណ្ឌិតត្រូវគោរពតាមសេចក្ដីសម្រេចរបស់តុលាការចំពោះកាតព្វកិច្ចដែលតុលារការបានដាក់ឱ្យនោះ ក្នុងករណីមិនបានគោរពតាម នោះនឹងក្លាយជាកម្មវត្ថុនៃការហូតការព្យួរទោសសាកល្បង។

### ២.២.២. កាតព្វកិច្ចដោយឡែករបស់ទណ្ឌិតជាអនីតិជន

ចំពោះកាតព្វកិច្ចដោយឡែករបស់ទណ្ឌិតជាអនីតិជនមានត្រឹមតែ ៩ (ប្រាំបួន) ចំណុចប៉ុណ្ណោះដែលមានលក្ខណៈខុសគ្នាអំពីកាតព្វកិច្ចដោយឡែកដែលដាក់ចំពោះនីតិជន។ កាតព្វកិច្ចដោយឡែករបស់ទណ្ឌិតជាអនីតិជននេះ បានកំណត់អំពីកាតព្វកិច្ចដោយឡែកដែលតុលាការអាចដាក់ចំពោះអនីតិជន នៅក្នុងករណីដែលអនីតិជនត្រូវបានទទួលនូវការព្យួរទោសសាកល្បងដោយមានចែងនៅក្នុងបញ្ញត្តិនៃមាត្រា ១៦៥ បានចែងថា នៅក្នុងករណីនៃការព្យួរទោសសាកល្បង មានតែកាតព្វកិច្ចដោយឡែកដូចតទៅនេះប៉ុណ្ណោះដែលអាចអនុវត្តទៅលើអនីតិជន ៖

១- ទទួលការបង្ហាត់បង្រៀន ឬការបណ្ដុះបណ្ដាលវិជ្ជាជីវៈ។

២- ស្ថិតនៅទីកន្លែងមួយជាកំណត់។

៣- ដាក់ខ្លួនឱ្យពេទ្យពិនិត្យ ឬព្យាបាល។

៤- ជួសជុលព្យសនកម្មដែលបណ្ដាលមកអំពីបទល្មើស ទៅតាមធនធានរបស់ខ្លួន។

[66]មាត្រា ១២០ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

៥- បង្ហាញភស្តុតាង បញ្ជាក់ថាខ្លួនបង់ទឹកប្រាក់ដែលជំពាក់ជូនរដ្ឋរួចហើយ តាមលទ្ធភាពនៃធនធានរបស់ខ្លួនបន្ទាប់ពីការផ្តន្ទាទោស។

៦- មិនត្រូវបង្ហាញមុខនៅទីកន្លែងខ្លះ។

៧- មិនត្រូវសេពគប់ ទីកន្លែងលក់ភេសជ្ជៈស្រវឹង។

៨- មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ដោយឡែកជាមួយសហចារី អ្នកផ្តើមគំនិតអ្នកសមគំនិត ឬជនរងគ្រោះនៃបទល្មើស។

៩- មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ[67]។

## ៣. ការកែប្រែកាតព្វកិច្ចដោយឡែកដោយយុត្តាធិការ

យុត្តាធិការ គឺជាតុលាការ ឬស្ថាប័នទទួលបន្ទុកចាត់ការរឿងក្តី។ នៅគ្រប់ពេលវេលាតុលាការអាចកែប្រែកាតព្វកិច្ចដោយឡែកដែលតម្រូវលើទណ្ឌិតបាន។ នៅពេលដែលកាតព្វកិច្ចណាមួយលែងសមស្របសម្រាប់ទណ្ឌិតនោះទៀតហើយ តុលាការអាចកែប្រែកាតព្វកិច្ចនោះឱ្យសមស្របទៅតាមស្ថានភាពជាក់ស្តែងចំពោះទណ្ឌិតបានគ្រប់ពេលវេលាទាំងអស់។ តុលាការត្រូវបានទទួលបណ្តឹងនៅក្នុង លក្ខខណ្ឌ ដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ[68]។ តុលាការទទួលបណ្តឹង តាមពាក្យ ប្តឹងរបស់អយ្យការ ឬរបស់ភាគីពាក់ សម្រេចនៅពេលសវនាការសាធារណៈក្រោយពីបាន ស្តាប់អយ្យការ ភាគីពាក់ព័ន្ធ និងមេធាវីរបស់ភាគី។

## ៤. ការដកហូតការព្យួរទោសសាកល្បង

ការព្យួរទោសសាកល្បងអាចត្រូវដកហូតដោយតុលាការ នៅក្នុងករណីដូចខាងក្រោមនេះ ៖

១- ប្រសិនបើក្នុងរយៈពេលសាកល្បង ទណ្ឌិតមិនគោរពតាមវិធានការត្រួតពិនិត្យ ឬកាតព្វកិច្ចដោយឡែកទេ។

២- ប្រសិនបើក្នុងរយៈពេលសាកល្បង ទណ្ឌិតត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាថ្មីទៀត។

តុលាការអាចបង្គាប់ឱ្យដកហូតការព្យួរទោសសាកល្បងនេះទាំងមូល ឬមួយផ្នែក។ នៅក្នុងករណីនេះទោសត្រូវយកមកអនុវត្តទាំងមូល ឬមួយផ្នែក។

[67]មាត្រា ១៦៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[68]មាត្រា ១២១ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

តុលាការត្រូវបានទទួលបណ្តឹងនៅក្នុងលក្ខខណ្ឌដែលមានចែងដោយក្រម នីតិវិធីព្រហ្មទណ្ឌ[69]។

ដូច្នេះក្នុងករណីនេះ តុលាការអាចបង្គាប់ឱ្យដកហូតការព្យួរទោសនេះទាំងស្រុង ឬដកហូតតែមួយផ្នែក ហើយទោសនេះក៏ត្រូវយកមកអនុវត្តទាំងមូល ឬ មួយផ្នែកតាមភាពនៃអំពើ និងបុគ្គលិកលក្ខណៈរបស់ទណ្ឌិត។ ការដកហូតនេះតុលាការត្រូវបានទទួលបណ្តឹងស្របតាមលក្ខខណ្ឌដែលកំណត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌ មានន័យថាបណ្តឹងសុំដកហូតការព្យួរទោសត្រូវបានធ្វើឡើងដោយព្រះរាជអាជ្ញា កាលណាទណ្ឌិតនោះបានគេចវេចមិនប្រតិបត្តិតាមវិធានការ ឬកាតព្វកិច្ចដែលចៅក្រមដាក់ឱ្យនោះ ព្រោះថាស្ថាប័នអយ្យការ គឺជាស្ថាប័នដែលជាអ្នកធានាក្នុងការអនុវត្តសេចក្តីសម្រេចខាងព្រហ្មទណ្ឌ និងម្យ៉ាងទៀតរាល់ទោសទាំងអស់ គឺអយ្យការធ្វើការធានាក្នុងការអនុវត្តកាលណាសេចក្តីសម្រេចអំពីទោសនោះត្រូវបានចូលជាស្ថាពរ។ ប៉ុន្តែបើសិនជាក្នុងរយៈពេលសាកល្បងនេះ បានកន្លងផុតទៅដោយគ្មានការផ្តន្ទាទោសជាថ្មីទៀតទេការផ្តន្ទាទោសដែលព្យួរសាកល្បងនេះត្រូវទុកជាអសារបង់[70]។ ផ្ទុយមកវិញ បើក្នុងរយៈពេលសាកល្បងនោះ មិនទាន់ផុតអស់កាលផង ស្រាប់តែទណ្ឌិតនោះបានប្រព្រឹត្តបទល្មើសជាថ្មីទៀត ទណ្ឌិតដដែលនោះត្រូវទទួលទោសទាំងមូល និងក្រោយរួមគ្នា។ តុលាការអាចធ្វើការដកហូតការព្យួរទោសសាកល្បងទាំងមូល ឬ មួយផ្នែក រីឯការអនុវត្តទោសវិញក៏ដូចគ្នាដែរ ទោសត្រូវយកអនុវត្តទាំងមូល ឬ មួយផ្នែកដូចគ្នា។

[69] មាត្រា ១២២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[70] មាត្រា ១២៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

# ជំពូកទី៣

# របបដោយឡែកនៃការប្រកាសទោស

# ជំពូកទី៣

# របបដោយឡែកនៃការប្រកាសទោស

នៅក្នុងជំពូកនេះយើងនឹងធ្វើការពិភាក្សាលម្អិតទៅលើររបបដោយឡែកចំនួនបីដែលជាយន្តការថ្មី ដែលនីតិនិពន្ធបានដាក់បញ្ចូលមកក្នុងច្បាប់ព្រហ្មទណ្ឌកម្ពុជាយើងនាពេលបច្ចុប្បន្ននេះ គឺរបបនៃការផ្អាកការប្រកាសទោស (ផ្នែកទី១) របបពាក់កណ្តាលសេរីភាព (ផ្នែកទី២) និង របបនៃការបែងចែកជាប្រភាគ (ផ្នែកទី៣)។

## ផ្នែកទី១ របបនៃការផ្អាកការប្រកាសទោស

ការផ្អាកការប្រកាសទោស ជាការផ្អាកបណ្តោះអាសន្ននូវការប្រកាសទោសក្នុងរយៈពេលណាមួយ បន្ទាប់ពីតុលាការបើកកិច្ចពិភាក្សាដេញដោលក្នុងពេលសវនាការ និងកំណត់ពេលក្នុងការប្រកាសជាថ្មីម្តងទៀត ប៉ុន្តែពុំបើកសវនាការជំនុំជម្រះម្តងទៀតនោះទេ។ បន្តទៅនេះយើងនឹងបកស្រាយអំពី លក្ខខណ្ឌនៃការផ្អាកការប្រកាសទោស (១.) និងសវនាការពិនិត្យរឿងដែលបង្អង់ (២.)។

### ១. លក្ខខណ្ឌនៃការផ្អាកការប្រកាសទោស

តុលាការអាចប្រកាសការផ្អាកការប្រកាសទោសចំពោះជនជាប់ចោទបាន ប្រសិនបើលក្ខខណ្ឌទាំងពីរត្រូវបានបំពេញគឺ បទល្មើសដែលត្រូវចោទប្រកាន់ និងវត្តមានជនជាប់ចោទនាពេលសវនាការ។

#### ១.១. បទល្មើសដែលត្រូវចោតប្រកាន់

តុលាការអាចធ្វើការផ្អាកការប្រកាសទោសបានចំពោះតែបទល្មើសដែលជនល្មើសបានប្រព្រឹត្តនោះ ជាបទមជ្ឈិមប៉ុណ្ណោះ។ ក្នុងអំឡុងពេលសវនាការជនត្រូវចោទត្រូវបានតុលារការចោទប្រកាន់អំពីបទមជ្ឈិម និងឈានដល់ការប្រកាសអំពីពិរុទ្ធភាពដោយតុលាការ តែតុលាការគាត់មិនទាន់ធ្វើការប្រកាសទោសនៅពេលនោះភ្លាមៗនោះទេ តុលាការអាចធ្វើការផ្អាកការប្រកាសទោសទៅលើជនត្រូវចោទនោះ ប្រសិនបើលក្ខខណ្ឌទាំងបីនេះត្រូវបានបំពេញផងដែរគឺ ភាពច្របូកច្របល់នៃសណ្តាប់ធ្នាប់សាធារណៈដែលបង្កឡើងដោយបទ ល្មើសត្រូវបានបញ្ចប់ (១.១.១) ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់ក្នុងសង្គមវិញ (១.១.២) និងជនជាប់ចោទសុំរយៈពេលដើម្បីជួសជុលការខូចខាត (១.១.៣)[71]។

[71]មាត្រា ១២៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

### ១.១.១. ភាពច្របូកច្របល់នៃសណ្តាប់ធ្នាប់សាធារណៈដែលបង្កឡើងដោយបទល្មើសត្រូវបានបញ្ឈប់

ភាពច្របូកច្របល់នៃសណ្តាប់ធ្នាប់សាធារណៈដែលបង្កឡើងដោយបទល្មើសត្រូវបានបញ្ឈប់ មានន័យថា បទល្មើសដែលបង្កឱ្យមានភាពភ្ញាក់ផ្អើលដល់សង្គមនោះត្រូវបានស្ងប់ស្ងាត់ទៅវិញ អាចជាបទល្មើសដែលប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់អ្នកដទៃ ឬភាពរឹករវដែលបង្កឡើងដោយបទល្មើសនោះមិនមានលក្ខណៈធ្ងន់ធ្ងរដែលធ្វើឱ្យរន្ធត់ភ័យខ្លាច ឬមានការជិតដាមដក់ជាប់ក្នុងចិត្តរបស់នរណាម្នាក់ ឬអាចនិយាយម្យ៉ាងទៀតថាលែងមានអ្នកនឹកឃើញក៏ដូចជាពុំមានអ្នកចងចាំអំពីហេតុការណ៍ដែលកើតឡើងនោះតទៅទៀតឡើយ។

### ១.១.២. ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ

ក្រោយពីប្រព្រឹត្តបទល្មើសរួចជនជាប់ចោទបានបង្ហាញពីវិប្បដិសារី ការស្តាយក្រោយ ដឹងនូវកំហុសដែលខ្លួនបានប្រព្រឹត្តហើយយល់ព្រម អប់រំ កែប្រែខ្លួនឯង និងបង្ហាញនូវអាកប្បកិរិយាជាវិជ្ជមានឡើងវិញ ដោយសន្យាថាខ្លួននឹងកែប្រែ កសាងខ្លួនដើម្បីក្លាយជាពលរដ្ឋល្អនៅក្នុងសង្គមវិញ ហើយឈប់ប្រព្រឹត្តអំពើទាំងឡាយដែលនាំឱ្យវិនាសដល់អ្នកដទៃ ឬធ្វើឱ្យខូចខាតប្រយោជន៍សង្គមជាតិតទៅទៀត។

### ១.១.៣. ជនជាប់ចោទសុំរយៈពេលដើម្បីជួសជុលការខូចខាត

នៅក្នុងអំឡុងពេលដែលតុលាការសម្រេចផ្តន្ទាទោស ហើយបង្គាប់ឱ្យបង់ប្រាក់ពិន័យ និងសងសំណងការខូចខាតចំពោះអំពើរបស់ខ្លួននោះ តែជនជាប់ចោទគាត់មិនទាន់មានលុយសង ដូច្នេះគាត់សុំឱ្យទុករយៈពេលដើម្បីឱ្យគាត់មានពេលអាចទៅប្រកបកាងារ ឬបររកស៊ីផ្សេងៗក្នុងគោលបំណងរកកម្រៃដើម្បីយកមក ជួសជុលព្យសនកម្ម ក៏ដូចជាសងសំណងការខូចខាត។

## ១.២. ជនជាប់ចោទត្រូវតែមានវត្តមាននៅពេលសវនាការ

ការផ្អាកការប្រកាសទោសអាចត្រូវបង្គាប់បានលុះត្រាតែជនជាប់ចោទមានវត្តមានក្នុងសវនាការ។ តុលាការកំណត់នៅក្នុងសាលក្រម ឬសាលដីការនូវកាលបរិច្ឆេទដែលត្រូវសម្រេចអំពីទោស។ សេចក្តីសម្រេចអំពីទោស ត្រូវតែធ្វើឡើងយ៉ាងយូរបំផុត ១ (មួយ) ឆ្នាំ ក្រោយសេចក្តីសម្រេចផ្អាក[72]។ លក្ខខណ្ឌនេះក៏ត្រូវបំពេញផងដែរ ទើបតុលាការអាចបង្គាប់ឱ្យមានផ្អាកការប្រកាសទោសបាន គឺជនជាប់ចោទត្រូវតែមានវត្តមាននៅពេលសវនាការ។ តុលាការធ្វើការបញ្ជាក់ថាជននោះមានពិរុទ្ធ តែទោសដែលត្រូវផ្តន្ទាទោសប៉ុន្មានៗនោះ តុលាការពុំ

[72]មាត្រា ១២៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

ទាន់ប្រកាសឡើយ ដោយតុលាការនឹងធ្វើការកំណត់អំពីកាលបរិច្ឆេទថ្មីដោយបញ្ជាក់អំពី រយៈពេល ថ្ងៃ ខែ ឆ្នាំ ម៉ោង និងសាលសវនាការដែលត្រូវបើកដើម្បីធ្វើការប្រកាសទោស ហើយកាលបរិច្ឆេទដែលត្រូវកំណត់ទោសនោះ មានរយៈពេលមិនឱ្យលើសពី ១ (មួយ) ឆ្នាំបន្ទាប់ពី សេចក្ដីសម្រេចផ្អាកសវនាការលើកមុនទេ។

### ២. សវនាការពិនិត្យរឿងដែលបង្អង់

សវនាការនេះ គឺជាសវនាការដែលតុលាការបើកជាថ្មីបន្ទាប់ពីសវនាការដែលមានសេចក្ដីសម្រេចផ្អាកនា ពេលលើកមុន។ នៅពេលសវនាការពិនិត្យរឿងដែលបង្អង់នេះ តុលាការសម្រេចអំពីទោស[73]។ ក្រោយពីតុលាការបង្អង់រឿងក្ដីនោះទុកតាមលក្ខខណ្ឌនៃមាត្រា ១២៤ និងមាត្រា ១២៥ រួចមក លុះដល់កាលបរិច្ឆេទដែលតុលាការបានកំណត់ទុកតាំងពីពេលដែលការប្រកាសទោសត្រូវបានផ្អាកនោះមក តុលាការធ្វើការបើកសវនាការថ្មីឡើង រួចយករឿងដែលបង្អង់ទុកនោះមកសម្រេចអំពីទោសដែលទណ្ឌិតត្រូវអនុវត្តតែម្ដង ដោយពុំធ្វើការពិភាក្សាដេញដោល ឬជំនុំជម្រះលើរឿងដដែលនោះទៀតឡើយ ព្រោះពិរុទ្ធភាពត្រូវបានរកឃើញតាំងពីសវនាការលើកដំបូងមកម្ល៉េះ។

## ផ្នែកទី២ របបពាក់កណ្ដាលសេរីភាព

របបពាក់កណ្ដាលសេរីភាព គឺជារបបមួយដែលផ្ដល់លទ្ធភាពឱ្យទណ្ឌិតអាចចេញទៅក្រៅពន្ធនាគារបានក្នុងរយៈពេលកំណត់ណាមួយដើម្បីបំពេញសកម្មភាពវិជ្ជាជីវៈ ទទួលការសិក្សា ការបណ្ដុះបណ្ដាល ពិនិត្យព្យាបាលជំងឺ ឬជួយឧបត្ថម្ភដល់សេចក្ដីត្រូវការរបស់គ្រួសារ ហើយនៅពេលដល់កាលកំណត់ទណ្ឌិតត្រូវវិលត្រឡប់មកពន្ធនាគារវិញដើម្បីអនុវត្តទោស។

### ១. លក្ខខណ្ឌនៃរបបពាក់កណ្ដាលសេរីភាព

កាលណាតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើនឹង ៦ (ប្រាំមួយ) ខែ នោះតុលាការអាចសម្រេចថា ទោសត្រូវអនុវត្តក្រោមរបបពាក់កណ្ដាលសេរីភាព ដើម្បីអនុញ្ញាតឱ្យទណ្ឌិតអាចបំពេញសកម្មភាពវិជ្ជាជីវៈ ទទួលការសិក្សា ការបណ្ដុះបណ្ដាល ពិនិត្យព្យាបាលជំងឺ ឬជួយឧបត្ថម្ភដល់សេចក្ដីត្រូវការរបស់គ្រួសារ[74]។ របបនេះអនុញ្ញាតឱ្យទណ្ឌិតបានចាកចេញពីពន្ធនាគារដើម្បីទៅបំពេញកិច្ចការវិជ្ជាជីវៈ សិក្សារៀនសូត្រ ការព្យាបាលខាងវិទ្យាសាស្ត្រ និងជួយឧបត្ថម្ភដល់សេចក្ដីត្រូវការរបស់គ្រួសារ ក៏ពិតមែនតែរបបមួយនេះអាចផ្ដល់ឱ្យចំពោះទោសដែលមានស្រាលៗតែប៉ុណ្ណោះ ពោលគឺទោសដែលមានរយៈពេលតិចជាង ឬស្មើនឹង ៦ (ប្រាំមួយ) ខែ រីឯទោសដែលមានរយៈពេលលើសពីនេះពុំអាចត្រូវយកយន្តការនេះមកអនុវត្តឡើយ។

[73]មាត្រា ១២៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[74]មាត្រា ១២៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

## ២. ចែបបទនៃរបបពាក់កណ្ដាលសេរីភាព

ទណ្ឌិតដែលស្ថិតនៅក្រោម របបពាក់កណ្ដាលសេរីភាព ត្រូវបានអនុញ្ញាតឱ្យចាកចេញពីពន្ធនាគារក្នុងរយៈពេលជាកំណត់។ តុលាការកំណត់នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនអំពីថ្ងៃ និងម៉ោងដែលទណ្ឌិតត្រូវបានអនុញ្ញាតឱ្យអវត្តមាននៅក្នុងពន្ធនាគារ ឬឱ្យចាកចេញពីពន្ធនាគារ និងទៅបំពេញកិច្ចការណាមួយដែលជាការយល់ឃើញរបស់តុលាការ[75]។ **ឧទាហរណ៍៖ ក** បានជាប់ទោសពីបទមជ្ឈឹមដោយតុលាការសម្រេចទោសឲ្យជាប់ពន្ធនាគាររយៈពេល ៤ ខែ ហើយតុលាការបានសម្រេចអនុញ្ញាតឱ្យទណ្ឌិត **ក** ទទួលបានការអនុវត្តរបបពាក់កណ្ដាលសេរីភាព ដោយព្រមអនុញ្ញាតឱ្យទណ្ឌិតចេញទៅនៅក្រៅពន្ធនាគារ សម្រាប់បន្តការរៀនសូត្រដោយហេតុថា ២ ខែទៀតត្រូវប្រលងបញ្ចប់ថ្នាក់បរិញ្ញាបត្រ តុលាការកំណត់ឱ្យទណ្ឌិតអាចនៅក្រៅពន្ធនាគារចាប់ផ្ដើមពីម៉ោង ៦ព្រឹក រហូតដល់ម៉ោង ៦ ល្ងាច រៀងរាល់ពីថ្ងៃច័ន្ទ ដល់ថ្ងៃសៅរ៍ ហើយចាប់ពីម៉ោង ៦ ល្ងាចតទៅទណ្ឌិតត្រូវមានកាតព្វកិច្ចត្រឡប់ទៅអនុវត្តទោសក្នុងពន្ធនាគារវិញ។

## ៣. ការគិតបញ្ចូលរយៈពេលនៃរបបពាក់កណ្ដាលសេរីភាពទៅក្នុងទោស

រយៈពេលនៃពាក់កណ្ដាលសេរីភាពទៅក្នុងទោស ត្រូវគិតបញ្ចូលទៅក្នុងចិរវេលានៃទោសដែលកំពុងតែអនុវត្ត[76]។ រយៈពេលដែលទណ្ឌិតនៅក្រៅពន្ធនាគារនេះ ក៏ត្រូវរាប់គិតទៅក្នុងចិរវេលានៃទោសដែលទណ្ឌិតកំពុងអនុវត្តដែរ ដោយត្រូវចាត់ទុកថា ជារយៈពេលដែលទណ្ឌិត បានអនុវត្តទោសនោះដែរ។

**ឧទាហរណ៍៖ ក** បានជាប់ទោសពីបទមជ្ឈឹមដោយតុលាការសម្រេចទោសឲ្យជាប់ពន្ធនាគាររយៈពេល ៤ ខែ ហើយតុលាការបានសម្រេចអនុញ្ញាតឱ្យទណ្ឌិត **ក** ទទួលបានការអនុវត្តរបបពាក់កណ្ដាលសេរីភាព ដោយព្រមអនុញ្ញាតឱ្យទណ្ឌិតចេញទៅនៅក្រៅពន្ធនាគារ សម្រាប់បន្តការរៀនសូត្រដោយហេតុថា ២ ខែទៀតត្រូវប្រលងបញ្ចប់ថ្នាក់បរិញ្ញាបត្រ តុលាការកំណត់ឱ្យទណ្ឌិតអាចនៅក្រៅពន្ធនាគារ ចាប់ផ្ដើមពីម៉ោង ៦ព្រឹក រហូតដល់ម៉ោង ៦ ល្ងាច រៀងរាល់ពីថ្ងៃច័ន្ទ ដល់ថ្ងៃសៅរ៍ ហើយចាប់ពីម៉ោង ៦ ល្ងាច តទៅទណ្ឌិតត្រូវមានកាតព្វកិច្ចត្រឡប់ទៅអនុវត្តទោសក្នុងពន្ធនាគារវិញ។ រយៈពេលដែលទណ្ឌិតនៅក្រៅពន្ធនាគារចាត់ទុកថាទណ្ឌិតកំពុងអនុវត្តទោស។ ដូច្នេះទណ្ឌិតត្រូវប្រើពេលតែ ៦ ខែប៉ុណ្ណោះ ក្នុងការអនុវត្តទោស បើទោះបីជា ៦ ខែ នេះគ្មានការអនុវត្តទោសពេញលេញក៏ដោយ។

**ឧទាហរណ៍៖** លោក **ង** ត្រូវតុលាការប្រកាសទោសដាក់ពន្ធនាគារ ៦ ខែ ហើយរៀបចំរយៈពេលឱ្យទណ្ឌិតនៅក្រៅពន្ធនាគារពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ចាប់ពីម៉ោង ៦ ព្រឹកដល់ម៉ោង ៦ ល្ងាច។ ទណ្ឌិតត្រូវនៅក្នុងពន្ធនាគារ

[75] មាត្រា ១២៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[76] មាត្រា ១២៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រពី ម៉ោង ៦ ល្ងាច ដល់ម៉ោង ៦ ព្រឹក។ រីឯថ្ងៃសៅរ៍ និង អាទិត្យ ទណ្ឌិតត្រូវស្ថិតក្នុងពន្ធនាគារពេញមួយថ្ងៃ។ ដូច្នេះក្នុងករណីនេះទណ្ឌិតត្រូវប្រើពេលតែ ៦ ខែប៉ុណ្ណោះ ក្នុងការអនុវត្តទោស បើទោះបីជា ៦ខែនេះគ្មានការអនុវត្តទោសពេញលេញក៏ដោយ។

### ៤. ការរៀបចំ និងការលុបចោលនៃរបបពាក់កណ្ដាលសេរីភាព

នៅគ្រប់ពេលវេលាតុលាការអាចរៀបចំរយៈពេល នៃពាក់កណ្ដាលសេរីភាព ឬ ក៏លុបចោលនូវរបបពាក់កណ្ដាលសេរីភាពតាមបណ្ដឹងរបស់ព្រះរាជអាជ្ញា។ តុលាការត្រូវបានទទួលដំណឹង នៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ[77]។ នៅក្នុងករណីនេះដែរ ប្រសិនបើទណ្ឌិតណាម្នាក់ត្រូវបានតុលាការដាក់ឱ្យស្ថិតក្រោមរបបពាក់កណ្ដាលសេរីភាព ហើយមិនព្រមបំពេញកាតព្វកិច្ចណាមួយ តុលាការអាចបន្ថែម ឬ បន្ថយរយៈពេលនៃរបបពាក់កណ្ដាលសេរីភាពនេះឡើងវិញ ឬអាចលុបចោលបានគ្រប់ពេលវេលា ប្រសិនបើមានបណ្ដឹងពីព្រះរាជអាជ្ញា ឬចៅក្រមអយ្យការដែលប្ដឹងឱ្យត្រួតពិនិត្យឡើងវិញ។

### ៥. ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត

ព្រះរាជអាជ្ញាអាចបង្គាប់ឲ្យចាប់ និងឃុំខ្លួនទណ្ឌិតដែលមិនព្រមវិលត្រលប់មកក្នុងពន្ធនាគារវិញ នៅពេលដែលផុតកំណត់រយៈពេលនៃរបបពាក់កណ្ដាលសេរីភាព[78]។ ក្នុងករណីដែលដល់រយៈពេលកំណត់នៃរបបពាក់កណ្ដាលសេរីភាពនេះហើយទណ្ឌិត មិនព្រមវិលត្រឡប់ទៅកាន់ពន្ធនាគារវិញទេ ព្រះរាជអាជ្ញាអាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួនទណ្ឌិតនោះ និងនាំខ្លួនទៅឃុំខ្លួននៅពន្ធនាគារវិញបាន នេះជាសមត្ថកិច្ចផ្ដាច់មុខរបស់ព្រះរាជអាជ្ញាក្នុងការតាមដានការអនុវត្តរបស់ទណ្ឌិត ព្រោះអង្គការអយ្យការ ជាអង្គការដែលធានាការអនុវត្តទោស ហើយនៅក្នុងការអនុវត្តយន្តការមួយនេះ ឬក្នុងករណីហេតុការណ៍ដែល បានពោលខាងលើបានកើតឡើង ព្រះរាជអាជ្ញាមានលទ្ធភាពអាចកេណ្ឌកងកម្លាំងសាធារណៈដោយផ្ទាល់ ដើម្បីជាជំនួយក្នុងការអនុវត្តរបបពាក់កណ្ដាលសេរីភាព ឬធ្វើការចាប់ខ្លួន និងបង្គាប់ឱ្យឃុំខ្លួនទណ្ឌិតដែលមិនអនុវត្តកាតព្វកិច្ចនោះ ក្នុងពន្ធនាគារវិញ។

## ផ្នែកទី៣ របបនៃការបែងចែកទោសជាប្រភាគ

ការបែងចែកទោសជាប្រភាគ គឺសំដៅទៅលើការសម្រេចរបស់តុលាការ ដែលបានអនុញ្ញាតឱ្យមានការអនុវត្តទោសជាផ្នែកដាច់ៗពីគ្នា ក្នុងរយៈពេលកំណត់មួយដែលទណ្ឌិតត្រូវអនុវត្តនៅក្នុងពន្ធនាគារខ្លះ និងចេញ

[77]មាត្រា ១៣០ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[78]មាត្រា ១៣១ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

ក្រៅពន្ធនាគារខ្លះដោយមូលហេតុភាពធ្ងន់ធ្ងរ ដែលមកពីលក្ខណៈជាគ្រួសារ ជាវិជ្ជាជីវៈ ឬជាវេជ្ជសាស្ត្រជាអាទិ៍។

## ១. លក្ខខណ្ឌនៃការបែងចែកទោសជាប្រភាគ

កាលណាតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើនឹង ១ (មួយ) ឆ្នាំ តុលាការអាចសម្រេចថាទោសនោះត្រូវអនុវត្តជាប្រភាគ ដោយមូលហេតុធ្ងន់ធ្ងរដែលមានលក្ខណៈជាគ្រួសារ ជាវេជ្ជសាស្ត្រ ជាវិជ្ជាជីវៈ ឬជាសង្គម[79]។ **ឧទាហរណ៍៖** លោក "**ក**" ត្រូវបានតុលាការប្រកាសទោសឱ្យជាប់ពន្ធនាគារ ៩ ខែ ដោយមូលហេតុជនជាប់ចោទមានជម្ងឺប្រចាំកាយ ត្រូវទទួលការព្យាបាលសម្រាកនៅមន្ទីរពេទ្យជារៀងរាល់ខែ ដោយត្រូវសម្រាកក្នុងមន្ទីរពេទ្យហោចណាស់ឱ្យបាន ១ សប្ដាហ៍ជាចាំបាច់។ ករណីនេះតុលាការអាចសម្រេចឱ្យមានការអនុវត្តនូវរបបបែងទោសជាប្រភាគចំពោះលោក "**ក**" បាន។

## ២. បែបបទនៃការបែងចែកទោសជាប្រភាគ

ប្រភាគនៃទោសនីមួយៗ មិនត្រូវតិចជាង ១ (មួយ) ខែ ទេ។ ចិរវេលាសរុបនៃការអនុវត្តទោស មិនអាចលើសពី ២ (ពីរ) ឆ្នាំ ទេ ដោយរាប់បញ្ចូលទាំងការផ្អាកការអនុវត្តទោស។ តុលាការកំណត់ក្នុងសេចក្ដីសម្រេចរបស់ខ្លួន អំពីបែបបទនៃការបែងចែកទោសជាប្រភាគ[80]។

**ឧទាហរណ៍៖** លោក "**ខ**" ត្រូវបានតុលាការប្រកាសទោសឱ្យជាប់ពន្ធនាគារ ៦ ខែ ពី បទរំលោភលើទំនុកចិត្ត។ ក៏ប៉ុន្តែ លោក "**ខ**" មានមូលហេតុត្រូវព្យាបាលជម្ងឺមហារីក នៅក្នុងមន្ទីរពេទ្យកាលម៉ែត្រជារៀងរាល់ខែ និងត្រូវសម្រាកក្នុងមន្ទីរពេទ្យយ៉ាងហោចណាស់ឱ្យបាន ១ សប្ដាហ៍ក្នុង ១ ខែ ក្នុងករណីបែបនេះ តុលាការ មានសិទ្ធិសម្រេចឱ្យមានការអនុវត្តនូវការបែងចែកទោសជា ប្រភាគបានមានន័យថា តុលាការអាចសម្រេចឱ្យជនជាប់ចោទជាប់ពន្ធនាគាររយៈពេល ៦ ខែ ក៏ប៉ុន្តែ ទោសត្រូវតែយកមកអនុវត្តជាប្រភាគ ដោយសម្រេចជាប់ពន្ធនាគារ ក្នុងរយៈពេល ១ ខែពេញហើយអនុញ្ញាតនៅក្រៅពន្ធនាគារ ១ ខែ គឺប្រភាគនៃទោសនីមួយៗ ធ្វើយ៉ាងណាមិនត្រូវតិចជាង ១ (មួយ) ខែ ទេ។ ប្រភាគនេះត្រូវបន្តរហូតដល់ អនុវត្តទោសដាក់ពន្ធនាគារចំនួន ៦ ខែ បានចប់សព្វគ្រប់ជាស្ថាពរ ពីព្រោះថាទណ្ឌិតត្រូវតែអនុវត្តទោសនៅក្នុងពន្ធនាការចំនួន ១ ខែ ហើយត្រូវស្ថិតនៅខាងក្រៅពន្ធនាគារ ចំនួន ១ ខែ បែបនេះជាសរុបមកឃើញថា ទណ្ឌិតត្រូវប្រើរយៈពេលដល់ទៅ ១២ ខែ ទើបអាចអនុវត្តទោសរបស់ខ្លួនចប់សព្វគ្រប់ពេញលេញជាស្ថាពរបានន័យថា ៦ ខែ ត្រូវស្ថិតនៅក្នុងពន្ធនាគារ និង ៦ ខែ ទៀតត្រូវស្ថិតនៅក្រៅ ពន្ធនាគារ។

---

[79]មាត្រា ១៣២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[80]មាត្រា ១៣៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

**ឧទាហរណ៍៖** លោក "ម" ត្រូវបានតុលាការប្រកាសទោសឱ្យជាប់ពន្ធនាគារ ៨ ខែ។ ក៏ប៉ុន្តែ លោក "ម" មានមូលហេតុត្រូវចិញ្ចឹមម្តាយចាស់ជរា ដោយផ្ញើរលុយទៅឱ្យម្តាយរៀងរាល់ ២ ខែម្តង ក្នុងករណីបែបនេះ តុលាការ មានសិទ្ធិសម្រេចឱ្យមានការអនុវត្តនូវការបែងចែកទោសជា ប្រភាគបានមានន័យថា តុលាការអាចសម្រេចឱ្យជនជាប់ចោទ ជាប់ពន្ធនាគាររយៈពេល ៨ ខែ ក៏ប៉ុន្តែ ទោសត្រូវតែយកមកអនុវត្តជាប្រភាគ ដោយសម្រេចជាប់ពន្ធនាគារ ក្នុង រយៈពេល ២ ខែពេញហើយអនុញ្ញាតនៅក្រៅពន្ធនាគារ ២ ខែ។ ច្បាប់បានកំណត់ថាប្រភាគនៃទោសនីមួយៗ ធ្វើយ៉ាងណាមិនត្រូវតិចជាង ១ (មួយ) ខែទេ មានន័យថា ១ (មួយ) ខែឡើង។ ដោយប្រភាគនៃទោសនីមួយៗនេះមានរយៈពេល ២ ខែ ដូច្នេះអាចអនុវត្តបាន។ ប្រភាគនៃទោសនេះត្រូវបន្តរហូតដល់ អនុវត្តទោសដាក់ពន្ធនាគារចំនួន ៨ ខែ បានចប់សព្វគ្រប់ជាស្ថាពរ ពីព្រោះថាទណ្ឌិតត្រូវតែអនុវត្តទោសនៅក្នុងពន្ធនាការចំនួន ២ ខែ ហើយត្រូវស្ថិតនៅខាងក្រៅពន្ធនាគារចំនួន ២ ខែ បែបនេះជាសរុបមកឃើញថា ទណ្ឌិតត្រូវប្រើរយៈពេលដល់ទៅ ១៦ ខែ ស្មើរនឹង ១ ឆ្នាំ ៤ ខែ ទើបអាចអនុវត្តទោសរបស់ខ្លួនចប់សព្វគ្រប់ពេញលេញ យើងឃើញថារយៈពេល ១ ឆ្នាំ ៤ ខែ គឺមិនលើសរយៈពេល ២ ឆ្នាំដូច្នេះគឺស្របតាមលក្ខខណ្ឌដែលច្បាប់បានកំណត់។

## ៣. ការកែប្រែរបបនៃការបែងចែកទោសជាប្រភាគ

នៅគ្រប់ពេលវេលា តុលាការអាចរៀបចំ បែបបទនៃការបែងចែកទោសជាប្រភាគ ឬ លុបចោលរបបនៃការបែងចែកទោសជាប្រភាគ តាមបណ្តឹងរបស់ព្រះរាជអាជ្ញា។ តុលាការ ត្រូវទទួលបណ្តឹងនៅក្នុងលក្ខខណ្ឌ ដែលមានចែង នៅក្នុងនីតិវិធីព្រហ្មទណ្ឌ[81]។ នៅគ្រប់ពេលវេលា តុលាការអាចរៀបចំបែបបទនៃការបែងចែកទោសជាប្រភាគ ឬលុបចោលនូវរបបនៃការបែងចែកទោសជាប្រភាគ ផ្អែកតាមបណ្តឹងរបស់ព្រះរាជអាជ្ញា។ តុលាការអាចបន្ថែម ឬបន្ថយរយៈពេលនៃការបែងចែកទោសជាប្រភាគទៅតាមចន្លោះនៃការកំណត់របស់ច្បាប់ ឬមួយក៏ឈប់ប្រើនូវយន្តការនៃការបែងចែកទោសជាប្រភាគ តទៅទៀតចំពោះរឿងក្តីមួយបានគ្រប់ពេល នេះប្រសិនបើជាមានការប្តឹងសុំអំពីព្រះរាជអាជ្ញា។

## ៤. ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត

ព្រះរាជអាជ្ញាអាចបង្គាប់ឲ្យចាប់ និងឃុំខ្លួនទណ្ឌិតដែលមិនព្រមវិលត្រលប់មកក្នុងពន្ធនាគារវិញ នៅពេលដែលផុតកំណត់រយៈពេលនៃការផ្អាកការអនុវត្តទោស[82]។ ដូចគ្នានឹងរបបពាក់កណ្តាលសេរីភាពដែរនៅពេលដល់រយៈពេលកំណត់ដែលត្រូវអនុវត្តន៍ទោសក្នុងពន្ធនាគារវិញហើយទណ្ឌិត មិនព្រមវិលត្រឡប់ទៅកាន់

[81]មាត្រា ១៣៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩
[82]មាត្រា ១៣៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

ពន្ធនាគារវិញទេ ព្រះរាជអាជ្ញាអាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួនទណ្ឌិតនោះ និងនាំខ្លួនទៅឃុំខ្លួននៅពន្ធនាគារវិញបាន នេះជាសមត្ថកិច្ចផ្ដាច់មុខរបស់ព្រះរាជអាជ្ញាក្នុងការតាមដានការអនុវត្តរបស់ទណ្ឌិត ព្រោះអង្គការអយ្យការ ជាអង្គការដែលធានាការអនុវត្តទោស ហើយនៅក្នុងការអនុវត្តយន្តការមួយនេះ ឬក្នុងករណីហេតុការណ៍ដែល បានពោលខាងលើបានកើតឡើង ព្រះរាជអាជ្ញាមានលទ្ធភាពអាចកេណ្ឌកងកម្លាំងសាធារណៈដោយផ្ទាល់ ដើម្បីជាជំនួយក្នុងការអនុវត្តរបបពាក់កណ្ដាលសេរីភាព ឬធ្វើការចាប់ខ្លួន និងបង្គាប់ឱ្យឃុំខ្លួនទណ្ឌិតដែលមិនអនុវត្តកាតព្វកិច្ចនោះក្នុងពន្ធនាគារវិញ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទ របបនៃការប្រកាសទោសនេះរួចមក យើងសង្កេតឃើញថា របបនៃការប្រកាសទោសនេះ គឺជារបបមួយដែលផ្តល់ផលប្រយោជន៍ជាច្រើនដល់ចៅក្រមក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់គាត់ទៅធ្វើការប្រកាសទោសទៅលើបុគ្គលម្នាក់ៗដើម្បីដាក់ឱ្យត្រូវទៅតាមស្ថានភាពជាក់ស្តែងនៃបទល្មើសនីមួយៗ ដោយមុននឹងឈានដល់ការប្រកាសទោសទៅលើបុគ្គលដែលបានប្រព្រឹត្តបទល្មើសនោះ តុលាការត្រូវធ្វើការពិចារណាយ៉ាងល្អិតល្អន់ទៅតាមស្ថានភាពជាក់ស្តែងនៃបទល្មើសនីមួយៗ គឺប្រែប្រួលទៅតាមបុគ្គលម្នាក់ៗ និងកាលៈទេសៈដែលបានប្រព្រឹត្តបទល្មើសនោះ។ ទោះជនល្មើសបានប្រព្រឹត្តិបទល្មើសដូចគ្នាក៏ពិតមែន តែទោសដែលយកទៅធ្វើការប្រកាសចំពោះបុគ្គលម្នាក់ៗ គឺមិនដូចគ្នាទេ តុលាការត្រូវធ្វើការប្រកាសទោសដោយអនុលោមតាមគោលការណ៍រួមចំនួនពីរ ដែលបានដើរតួនាទីយ៉ាងសំខាន់ គឺគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ និងគោលការណ៍ឯកត្តកម្មនៃទោស។ គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ជាការទទួលខុសត្រូវចំពោះតែអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ គឺមិនអនុញ្ញាត្តិឱ្យអ្នកដទៃទទួលទោសជំនួសនោះទេ រីឯគោលការណ៍ឯកត្តកម្មនៃទោសវិញ គឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់តុលាការលើកយកមកពិចារណាមុននឹងធ្វើការសម្រេចផ្តន្ទាទោស។ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ ក៏បានបញ្ញត្តិពីរបបពិសេសមួយចំនួនដែលផ្តល់ជាប្រយោជន៍ដល់ទណ្ឌិតផងដែរ តាមរយៈរបបនៃការព្យួរទោស និងរបបដោយឡែកផ្សេងទៀត ដែលតុលាការអាចធ្វើការប្រកាសរបបទាំងនេះចំពោះទណ្ឌិត កាលបើជននោះបានបំពេញគ្រប់លក្ខខណ្ឌដែលច្បាប់បានកំណត់។

ជាចុងក្រោយយើងអាចធ្វើការសន្និដ្ឋានបានថា របបនៃការប្រកាសទោស នេះមានលក្ខណៈពិសេសមែនទែនព្រោះរបបនេះមិនត្រឹមតែបង្កភាពងាយស្រួលដល់តុលាការក្នុងការសម្រេចសេចក្តីអំពីការប្រកាសផ្តន្ទាទោសប៉ុណ្ណោះទេ ហើយថែមទាំងផ្តល់នូវលទ្ធភាពដល់ទណ្ឌិតក្នុងការអប់រំ កែប្រែខ្លួនឯង ដើម្បីឱ្យទណ្ឌិតនោះអាចទៅរួមរស់នៅក្នុងសង្គមវិញផងដែរ។ មិនតែប៉ុណ្ណោះក្នុងរបបនៃការប្រកាសទោសនេះ ក៏ផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដល់សង្គមជាតិផងដែរ ដូចជាការជំនួសឱ្យមូលទោសដោយទោសការងារសហគមន៍ដែលត្រូវបង្គាប់ឱ្យទណ្ឌិតធ្វើការងារដើម្បីជាប្រយោជន៍ដល់សាធារណជនជំនួសឲ្យការប្រកាសអនុវត្តនូវមូលទោសវិញ។ ការប្រើនូវរបបនៃការព្យួរទោស របបពាក់កណ្តាលសេរីភាព ក៏ដូចជា ការបែងចែកទោសជាប្រភាគ ចំពោះទណ្ឌិតនេះត្បិតតែផ្តល់នូវប្រយោជន៍ដល់ទណ្ឌិតក៏មែនពិត តែមិនមែនមានន័យថាជាការបើកដៃឱ្យទណ្ឌិតនោះទៅបន្តប្រព្រឹត្តបទល្មើសទៀតនោះទេ ដើម្បីធានានូវសណ្តាប់ធ្នាប់សាធារណៈ សន្តិសុខ និងសុវត្ថិភាព នៅក្នុងសង្គម ក៏ដូចជាដើម្បីធានាភាពយុត្តិធម៌ផងនោះ ក្រមព្រហ្មទណ្ឌបានកំណត់អំពីលក្ខខណ្ឌ និងវិធានការផ្សេងៗជាច្រើនដើម្បី

ទប់ស្កាត់ ក៏ដូចជាបង្ការការប្រព្រឹត្តបទល្មើសសារជាថ្មី បើក្នុងករណីទណ្ឌិតដែលស្ថិតក្រោមរបបខាងលើនេះ ប្រព្រឹត្តបទល្មើសសារជាថ្មី ច្បាប់បានកំណត់ពីការផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរទៅលើទណ្ឌិតនោះ លើកលែងតែទណ្ឌិតជាអនីតិជន ឬជនមានវិបល្លាសស្មារតី ដែលបន្ថយនូវការដឹងខុសត្រូវប៉ុណ្ណោះ ដែលតុលាការនៅតែអាចធ្វើការពិចារណាសណ្តោសប្រណីតាមផ្លូវច្បាប់ផងដែរ គឺគោរពទៅតាមគោលការណ៍ឯកត្តកម្មនៃទោស។

# អនុសាសន៍

# អនុសាសន៍

ឆ្លងតាមការបកស្រាយខាងលើរួចមកយើងសង្កេតឃើញថា ក្រមព្រហ្មទណ្ឌមានយន្តការជាច្រើនសម្រាប់ប្រើក្នុងការប្រកាសទោសចំពោះជនដែលបានប្រព្រឹត្តបទល្មើសដែលនីតិនិពន្ធបានខិតខំបង្កើតឡើងដើម្បីឱ្យការអនុវត្តច្បាប់ព្រហ្មទណ្ឌកាន់តែមានលក្ខណៈល្អប្រសើរថែមទៀតដូចជា ការប្រកាសទោស ការព្យួរទោស ការផ្អាកការប្រកាសទោស របបពាក់កណ្តាលសេរីភាព និងការបែងចែកទោសជាប្រភាគ។ ត្បិតតែរបបទាំងនេះមានអត្ថប្រយោជន៍ច្រើនក៏ពិតមែន ប៉ុន្តែផ្នែកខ្លះនៃរបបទាំងនេះហាក់មានភាពកកស្ទះពុំទាន់អាចអនុវត្តបាននៅឡើយ ហើយផ្នែកខ្លះក៏អនុវត្តបានតែបន្តិចបន្តួចផងដែរ បើផ្អែកតាមការអនុវត្តជាក់ស្តែងនៅកម្ពុជា ជាក់ស្តែងដូចជា របបពាក់ណ្តាលសេរីភាព និងការបែងចែកទោសជាប្រភាគដែលមកដល់សព្វថ្ងៃនេះមិនទាន់ឃើញមានការអនុវត្តទាល់តែសោះ។ ដោយឡែកទោសការងារសហគមន៍ ការព្យួរទោសធម្មតា និងការព្យួរសាកល្បង ហាក់មានការអនុវត្តពុំទាន់មានភាពទូលំទូលាយនៅឡើយ ពោលគឺមានតិចតួចបំផុតនៅក្នុងការយកមកអនុវត្ត។ ក្រមព្រហ្មទណ្ឌបានកំណត់យ៉ាងជាក់លាក់អំពីលក្ខខណ្ឌក្នុងការអនុវត្ត ប៉ុន្តែបញ្ហាប្រឈមដែលធ្វើឱ្យមិនអាចយកមកអនុវត្តតាមកាលកំណត់បាន គឺបណ្តាលមកពីកង្វះខាតនូវថវិកា បច្ចេកវិទ្យានៃការតាមដានឃ្លាំមើលនៅពុំទាន់មានភាពទូលំទូលាយ ខ្វះខាតអ្នកជំនាញ ម្យ៉ាងទៀតស្ថានភាពសង្គមជាក់ស្តែងប្រជាពលរដ្ឋពលរដ្ឋខ្វះការយល់ដឹងអំពីច្បាប់ ហើយក៏អាចនិយាយបានថា របបមួយចំនួនជាយន្តការថ្មី ដូចនេះសេចក្តីណែនាំ ឬបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធទៅនឹងការអនុវត្តក៏ពុំទាន់មានដែរ ដែលជាហេតុធ្វើឱ្យចៅក្រមមិនអាចប្រើប្រាស់យុទ្ធសាស្ត្រនេះក្នុងការអនុវត្តជាក់ស្តែងបាន។ ជាចុងក្រោយយើងខ្ញុំដែលជាអ្នកសិក្សាស្រាវជ្រាវសុំអនុញ្ញាតិផ្តល់ជូននូវអនុសាសន៍មួយចំនួនដូចខាងក្រោមៈ

សុំសំណូមពរដល់ក្រសួងយុត្តិធម៌មេត្តាចាត់វិធានការបន្ថែមដល់មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ បន្តការផ្សព្វផ្សាយក្រមព្រហ្មទណ្ឌនេះ ដល់ប្រជាពលរដ្ឋឲ្យបានដឹងកាន់តែច្បាស់ពីក្រមមួយនេះ និងច្បាប់ដោយឡែកផ្សេងទៀតតាមគ្រប់វិធីសាស្ត្រ។ បង្កើនការយល់ដឹង និងជំនាញពិតប្រាកដទៅលើផ្នែកបច្ចេកវិទ្យាដែលអាចជាជំនួយក្នុងការអនុវត្តទោសតាមបរិបទសង្គមឱ្យបានជឿនលឿន និងធ្វើការបណ្តុះបណ្តាលមន្ត្រីជំនាញដែលមានសមត្ថភាពឱ្យជួយដល់ការអនុវត្តទាក់ទងនឹងរបបនៃការប្រកាសទោស ឬ ជាជំនួយក្នុងការអនុវត្តគោលការណ៍ច្បាប់ឱ្យបានគ្រប់គ្រាន់។

សុំសំណូមពរដល់ស្ថាប័នតុលាការមេត្តាស៊ើបសួរ និងរកភស្តុតាងឲ្យបានច្បាស់លាស់ជាមុនសិន មុននឹងធ្វើការជំនុំជម្រះដើម្បីជាភាពយុត្តិធម៌ដល់មហាជនក៏ដូចជាពលរដ្ឋទូទាំងប្រទេស។

សូមឱ្យប្រជាពលរដ្ឋកម្ពុជាគ្រប់រូប មេត្តាព្យាយាមសិក្សាស្វែងយល់អំពីច្បាប់ព្រហ្មទណ្ឌនេះ តាមរយៈការស្តាប់ ការអាន ការឆ្ងល់រួចសួរទៅកាន់អ្នកជំនាញផ្នែកច្បាប់ និងចូលរួមអនុវត្តនូវច្បាប់ព្រហ្មទណ្ឌឲ្យបានខ្ជាប់ខ្ជួន ដើម្បីជៀសវាងកុំឱ្យធ្លាក់ខ្លួនទៅប្រព្រឹត្តបទល្មើសដែលនាំឲ្យមានការផ្តន្ទាទោសព្រហ្មទណ្ឌពីតុលាការ និងបណ្តាលឱ្យខូចខាតនូវប្រយោជន៍របស់ខ្លួនឯង ក៏ដូចជា ក្រុមគ្រួសារ និងសង្គមជាតិទាំងមូលផងដែរ។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
- ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦
- សារាចរលេខ ០១ កយ.សរ/១៤ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ស្តីពី ការអនុវត្តបទប្បញ្ញត្តិដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ
- សារាចរលេខ ០២ កយ.សរ/១៤ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ស្តីពី ការអនុវត្តបទប្បញ្ញត្តិ នៃការព្យួរទោសសាកល្បង
- សារាចរលេខ ០៣ កយ.សរ/១៤ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ស្តីពី ការអនុវត្តបទប្បញ្ញត្តិនៃ ការអនុវត្តទោសការងារសហគមន៍
- ប្រកាសលេខ ០៩០ កយ ប្រក/២១ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ របស់ក្រសួងយុត្តិធម៌ ស្តីពី បែបបទនៃការឃ្លាំមើលតាមដាន ការត្រួតពិនិត្យ និងការបញ្ចូលទៅក្នុងសង្គមវិញនៃទណ្ឌិតដែលត្រូវបានដោះលែងដោយមានលក្ខខណ្ឌ

## ២. សៀវភៅមេរៀនច្បាប់

- សៀវភៅនីតិព្រហ្មទណ្ឌ រៀបរៀងដោយ ឯកឧត្តម ហ៊ី សោភា ឆ្នាំ២០០៦
- មេរៀននីតិព្រហ្មទណ្ឌខ្មែរ រៀបរៀងដោយសហប្រតិបត្តិការបារាំងគម្រោងទ្រទ្រង់នីតិរដ្ឋ ឆ្នាំ២០០៧

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

- **ឧបសម្ព័ន្ធទី១** រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- **ឧបសម្ព័ន្ធទី២** ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
- **ឧបសម្ព័ន្ធទី៣** ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦
- **ឧបសម្ព័ន្ធទី៤** សារាចរលេខ ០១ កយ.សរ/១៤ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ស្ដីពី ការអនុវត្តបទប្បញ្ញតិដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ
- **ឧបសម្ព័ន្ធទី៥** សារាចរលេខ ០២ កយ.សរ/១៤ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ស្ដីពី ការអនុវត្តបទប្បញ្ញតិ នៃការព្យួរទោសសាកល្បង
- **ឧបសម្ព័ន្ធទី៦** សារាចរលេខ ០៣ កយ.សរ/១៤ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ស្ដីពី ការអនុវត្តបទប្បញ្ញតិនៃ ការអនុវត្តទោសការងារសហគមន៍
- **ឧបសម្ព័ន្ធទី៧** ប្រកាសលេខ ០៩០ កយ ប្រក/២១ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ របស់ក្រសួងយុត្តិធម៌ ស្ដីពី បែប បទនៃការឃ្លាំមើលតាមដាន ការត្រួតពិនិត្យ និងការបញ្ចូលទៅក្នុងសង្គមវិញនៃទណ្ឌិតដែលត្រូវបានដោះលែងដោយមានលក្ខខណ្ឌ
- **ឧបសម្ព័ន្ធទី៨** សាលក្រមព្រហ្មទណ្ឌ សម្រេចអំពីមូលទោស (ដាក់ពន្ធនាគារ)
- **ឧបសម្ព័ន្ធទី៩** សាលក្រមព្រហ្មទណ្ឌ សម្រេចអំពីមូលទោស (អនីតិជន)
- **ឧបសម្ព័ន្ធទី១០** សាលក្រមព្រហ្មទណ្ឌ សម្រេចអំពីទោសបន្ថែម
- **ឧបសម្ព័ន្ធទី១១** សាលក្រមព្រហ្មទណ្ឌ សម្រេចអំពីការព្យួរទោសធម្មតា
- **ឧបសម្ព័ន្ធទី១២** សាលក្រមព្រហ្មទណ្ឌ សម្រេចអំពីការព្យួរទោសសាកល្បង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

**ឧបសម្ព័ន្ធទី៧**

លេខ : ០៥០.កយ.ប្រក/២២

# ប្រកាស
## ស្តីពី
## បែបបទនៃការឃ្លាំមើលតាមដាន ការត្រួតពិនិត្យ និងការបញ្ចូលទៅក្នុងសង្គមវិញ នៃទណ្ឌិតដែលត្រូវបានដោះលែងដោយមានលក្ខខណ្ឌ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៦/០០៩ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីយុត្តិធម៌អនីតិជន
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងយុត្តិធម៌

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ កំណត់អំពីបែបបទនៃការឃ្លាំមើលតាមដាន ការត្រួតពិនិត្យ និងការបញ្ចូលទៅក្នុងសង្គមវិញនៃទណ្ឌិតដែលត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ក្នុងគោលបំណងដើម្បីធានាការអនុវត្តការដោះលែងដោយមានលក្ខខណ្ឌឱ្យមានប្រសិទ្ធភាព សំដៅធ្វើសមាហរណកម្មទណ្ឌិតនោះឱ្យចូលទៅរួមរស់នៅក្នុងសង្គមវិញ។

**ប្រការ២.-**

ការដោះលែងដោយមានលក្ខខណ្ឌ គឺជាសមត្ថកិច្ចរបស់ប្រធានសាលាដំបូងនៃទីកន្លែងឃុំខ្លួនទណ្ឌិត។ ប្រធានសាលាដំបូងសម្រេចអំពីការដោះលែងដោយមានលក្ខខណ្ឌ តាមដីកាសម្រេច ដោយមានសំអាងហេតុ បន្ទាប់ពីទទួលបានយោបល់ពីគណៈកម្មការជាតិដោះលែងដោយមានលក្ខខណ្ឌ ស្របតាមមាត្រា៥១៤ មាត្រា៥១៥ និងមាត្រា៥១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ប្រធានសាលាដំបូង មិនជាប់ជំពាក់នឹងយោបល់របស់គណៈកម្មការជាតិនោះទេ។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការដោះលែងដោយមានលក្ខខណ្ឌ ព្រមទាំងការបញ្ចប់ការដោះលែងដោយមានលក្ខខណ្ឌ មានចែងចាប់ពីមាត្រា ៥១២ ដល់មាត្រា ៥២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**ប្រការ៣.-**

នៅក្នុងដីកាសម្រេចដោះលែងដោយមានលក្ខខណ្ឌ ប្រធានសាលាដំបូងត្រូវកំណត់អំពីបែបបទនៃការអនុវត្ត និងរយៈពេលនៃការសាកល្បងដែលមិនអាចលើសពីថិរវេលានៃទោសដែលនៅសល់មិនទាន់បានទទួលរងឡើយ។

ប្រធានសាលាដំបូងសម្រេចដោះលែងទណ្ឌិត ដោយមានភ្ជាប់លក្ខខណ្ឌជាកាតព្វកិច្ចមួយ ឬច្រើនដូចខាងក្រោម ៖

- បំពេញសកម្មភាពខាងវិជ្ជាជីវៈ។
- ទទួលការបង្ហាត់បង្រៀន ឬទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ។
- រស់នៅក្នុងទីកន្លែងណាមួយជាក់លាក់។
- ទទួលឱ្យពេទ្យធ្វើការពិនិត្យ ឬការព្យាបាល។
- បញ្ជាក់អំពីការចូលរួមចំណែកក្នុងការចិញ្ចឹមបីបាច់គ្រួសារ។
- ធ្វើការជួសជុលការខូចខាតដែលបណ្តាលមកពីបទល្មើស តាមលទ្ធភាពនៃធនធានរបស់ខ្លួន។
- បញ្ជាក់អំពីការបានបង់ប្រាក់ជូនរដ្ឋបន្ទាប់ពីការផ្តន្ទាទោស តាមលទ្ធភាពធនធានរបស់ខ្លួន។
- មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈ ឬសង្គមដែលសម្រួលដល់ការប្រព្រឹត្តបទល្មើស។ ក្នុងករណីនេះ តុលាការត្រូវបញ្ជាក់អំពីសកម្មភាពដែលហាមឃាត់។
- មិនត្រូវមានវត្តមាននៅទីកន្លែងមួយចំនួនដែលត្រូវបានហាមឃាត់។ ក្នុងករណីនេះ តុលាការត្រូវបញ្ជាក់អំពីទីកន្លែងដែលត្រូវបានហាមឃាត់។
- មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ពិសេស ចារី សហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ឬជនរងគ្រោះនៃបទល្មើស។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីបុគ្គលដែលមិនត្រូវសេពគប់ជាមួយ។

- មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។

ក្រៅពីការអនុវត្តកាតព្វកិច្ចខាងលើ ទណ្ឌិតអាចត្រូវដាក់ឱ្យស្ថិតក្រោមវិធានការត្រួតពិនិត្យរបស់អាជ្ញាធរមានសមត្ថកិច្ច ដោយត្រូវគោរពកាតព្វកិច្ចមួយឬច្រើន ដូចខាងក្រោម៖

- ត្រូវគោរពតាមដីកាកោះរបស់ព្រះរាជអាជ្ញា ឬការកោះហៅរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ។
- ត្រូវមកទទួលនូវការពិនិត្យមើលរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ។
- ត្រូវប្រគល់ដល់ព្រះរាជអាជ្ញា ឬដល់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ នូវគ្រប់ឯកសារសម្រាប់ធ្វើការផ្ទៀងផ្ទាត់លើការបញ្ចូលឱ្យទៅរួមរស់នៅក្នុងសង្គមវិញ។
- ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្ដូរអាសយដ្ឋានរបស់ខ្លួន។
- ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្ដូរមុខរបររបស់ខ្លួន។
- ត្រូវមានការអនុញ្ញាតពីព្រះរាជអាជ្ញា មុនពេលធ្វើដំណើរទៅបរទេស។

ក្នុងករណីទណ្ឌិតមិនអនុវត្តតាមដីកាសម្រេចដោះលែងដោយមានលក្ខខណ្ឌ ប្រធានសាលាដំបូងអាចដកហូតដីកាសម្រេចនោះ និងអាចបង្គាប់ឱ្យចាប់ខ្លួនទណ្ឌិតនោះមកអនុវត្តទោសដែលនៅសេសសល់។

**ប្រការ៤ .**

ព្រះរាជអាជ្ញានៃសាលាដំបូងដែលបានចេញដីកាសម្រេចដោះលែងដោយមានលក្ខខណ្ឌ ប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួនតាមច្បាប់ ដើម្បីធានាដល់ការអនុវត្តដីកាសម្រេចដោះលែងដោយមានលក្ខខណ្ឌ ព្រមទាំងអាចចាត់វិធានការចាំបាច់នានា ដើម្បីឃ្លាំមើល តាមដាន និងត្រួតពិនិត្យការអនុវត្តដីកាសម្រេចនោះ។ ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចដែនដីពាក់ព័ន្ធ ត្រូវផ្ដល់កិច្ចសហការចាំបាច់នានា ដើម្បីធានាដល់ការអនុវត្តដីកាសម្រេចដោះលែងដោយមានលក្ខខណ្ឌ។

ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ច ត្រូវដឹកនាំសម្របសម្រួលអាជ្ញាធរដែនដី និងមន្ត្រីនគរបាលយុត្តិធម៌ ក្នុងការអនុវត្តដីកាសម្រេចដោះលែងដោយមានលក្ខខណ្ឌ ឱ្យមានប្រសិទ្ធភាព។

ក្នុងករណីចាំបាច់ ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ច អាចចាត់តាំងបុគ្គល ឬអង្គភាពនៅមូលដ្ឋាននៃទីកន្លែងដែលទណ្ឌិតនឹងទៅរស់នៅ ឬទៅបំពេញការងារ ឬទៅបំពេញកាតព្វកិច្ច ដើម្បីឃ្លាំមើល តាមដាន និងត្រួតពិនិត្យការអនុវត្តកាតព្វកិច្ចរបស់ទណ្ឌិតនោះ។

បុគ្គលដែលអាចត្រូវបានចាត់តាំង រួមមាន មន្ត្រីនគរបាលយុត្តិធម៌ នគរបាល កងរាជអាវុធហត្ថ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ មេភូមិ មន្ត្រីសង្គមកិច្ច និងមន្ត្រីទទួលបន្ទុកអប់រំនិងស្ដារនីតិសម្បទា។

**ប្រការ៥ .**

បុគ្គលដែលត្រូវបានចាត់តាំងដោយព្រះរាជអាជ្ញាដូចមានកំណត់ក្នុងប្រការ៤ ត្រូវបំពេញកាតព្វកិច្ចដូចខាងក្រោម៖

- គ្រប់គ្រង និងតាមដានការបំពេញកាតព្វកិច្ចរបស់ទណ្ឌិត
- ណែនាំទណ្ឌិតដែលត្រូវបានដោះលែង អំពីកាតព្វកិច្ចដែលត្រូវអនុវត្តដូចមានកំណត់ក្នុងដីកាសម្រេចដោះលែងដោយមានលក្ខខណ្ឌ

- អប់រំទណ្ឌិតនោះឱ្យយកចិត្តទុកដាក់ កែប្រែ និងកសាងខ្លួនដើម្បីធ្វើសមាហរណកម្មចូលទៅរួមរស់នៅក្នុងសង្គមវិញ
- រាយការណ៍ ឬធ្វើរបាយការណ៍អំពីសកម្មភាពរបស់ទណ្ឌិតដែលត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ជូនដល់ព្រះរាជអាជ្ញា។

**ប្រការ៦ .-**

គណៈកម្មការជាតិដោះលែងដោយមានលក្ខខណ្ឌ ត្រូវបានប្រគល់ភារកិច្ច ដើម្បីសហការជាមួយស្ថាប័នសាធារណៈ ស្ថាប័នឯកជន អង្គការមិនមែនរដ្ឋាភិបាល ឬស្ថាប័នពាក់ព័ន្ធផ្សេងទៀត សំដៅជួយដល់ការធ្វើសមាហរណកម្មទណ្ឌិតដែលត្រូវបានដោះលែងដោយមានលក្ខខណ្ឌឱ្យចូលទៅរួមរស់នៅក្នុងសង្គមវិញ។

**ប្រការ៧ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គ្រប់អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការ អគ្គាធិការដ្ឋានកិច្ចការតុលាការ និងប្រធានគ្រប់អង្គភាពចំណុះក្រសួងយុត្តិធម៌ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៧កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

កើត រិទ្ធ

កន្លែងទទួល៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល
- សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
- សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត
- ដូចប្រការ៧
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ ១៦៥៥
ចុះថ្ងៃទី ១២ ខែមេសា ឆ្នាំ ២០១៦
សំណុំរឿងជំនុំជម្រះលេខ១៥១៣
ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦
សាលក្រមលេខ ៥៦៣ ក្រ២ "រ"
ចុះថ្ងៃទី២១ ខែ ធ្នូ ឆ្នាំ ២០១៦

**តាមនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ២០១៦ វេលាម៉ោង ៨ និង ៣០ នាទី ព្រឹក ដោយមានសមាសភាព ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ ប្រធានក្រុមប្រឹក្សា
លោក ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ចៅក្រមប្រឹក្សា
លោក ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១៦៥៥ ចុះថ្ងៃទី ១២ ខែមេសា ឆ្នាំ ២០១៦ ដែលមានជនជាប់ចោទ ៖

១. ឈ្មោះ ភេទប្រុស អាយុ ២៦ ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌រៀន ថ្នាក់ទី៩ មុខរបរនៅផ្ទះ ទីកន្លែងកំណើតសង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក ក្រុងភ្នំពេញ មានទីលំនៅបច្ចុប្បន្នផ្ទះជួល ាជធានីភ្នំពេញ ឪពុកឈ្មោះ "រស់" ម្តាយឈ្មោះ "រស់" ប្រពន្ធឈ្មោះ ានកូន ១ នាក់ ទោសពីមុន គ្មាន ។

លោក មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
ឃាត់ខ្លួនថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១៦
ឃុំខ្លួនថ្ងៃទី ១៣ ខែមេសា ឆ្នាំ ២០១៦

២.ឈ្មោះ ភេទប្រុស អាយុ ៣២ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌រៀនថ្នាក់ទី៥ មុខរបរតេម៉្មូតូឌុប ទីកន្លែងកំណើតភូមិពោធិ៍ ឃុំតានី ស្រុកអង្គរជ័យ ខេត្តកំពត មានទីលំនៅបច្ចុប្បន្ន ផ្ទះជួល សង្កាត់ទឹក ាជធានីភ្នំពេញ ឪពុកឈ្មោះ ម្តាយឈ្មោះ ប្រពន្ធឈ្មោះ មានកូន ០១នាក់ ទោសពីមុនគ្មាន ។

លោក មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
ឃាត់ខ្លួនថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១៦
ឃុំខ្លួនថ្ងៃទី ១៣ ខែមេសា ឆ្នាំ ២០១៦

៣.ឈ្មោះ ហៅ គួក ភេទប្រុស អាយុ ១៨ឆ្នាំ សញ្ជាតិខ្មែរ សាសនា ព្រះពុទ្ធ កម្រិតវប្បធម៌រៀនថ្នាក់ទី៨ មុខរបរគ្មាន ទីកន្លែងកំណើតនៅ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្ន ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ ម្តាយឈ្មោះ · នៅលីវ ទោសពីមុនគ្មាន។

លោក មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ឃាត់ខ្លួនថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១៦

ឃុំខ្លួនថ្ងៃទី ១៣ ខែមេសា ឆ្នាំ ២០១៦

ពីបទ **ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចផ្ទះលេខ១៣៦ ផ្លូវលំ ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៧ មាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

ជនរងគ្រោះឈ្មោះ ភេទប្រុស អាយុ ៤៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ មន្ត្រីគយ មានទីលំនៅផ្ទះលេខ១៣៦ ផ្លូវលំ ភូមិផ្សារទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ២៨៥០ អ.យ.ព ចុះថ្ងៃទី ១៤ ខែតុលា ឆ្នាំ ២០១៦ របស់ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៣៧២៤ ជ.ជ ចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០១៦ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៦ ជនរងគ្រោះឈ្មោះ បានយកមេសោពណ៌ខ្មៅ ទៅចាក់ទ្វារជណ្តើរឡើងទៅលើផ្ទះថ្មល នៅចំណុចផ្ទះលេខ១៣៦ ផ្លូវលំ ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ រួចក៏ចូលទៅដេកលង់លក់ជាមួយក្រុមគ្រួសារ។ លុះដល់ម៉ោងប្រហែល ០៣ និង ៣០ នាទី រំលងអាធ្រាត ក៏មានជនជាប់ចោទចំនួនបីនាក់មានឈ្មោះ ហៅ គួក ភេទ ប្រុស ឈ្មោះ ភេទ ប្រុស និងឈ្មោ ភេទ ប្រុស បានជិះម៉ូតូ មួយគ្រឿង មកឈប់មុខផ្ទះជនរងគ្រោះ។ ដោយឃើញសភាពស្ងាត់ឈ្មោះ គួក និងឈ្មោះ ស្ងាបានដើរចូលទៅដោយបានយកម្ជុលខ្វាស់ទៅឆ្កិះសោទ្វារឱ្យបើក បន្ទាប់មកជនសង្ស័យទាំងពីរ នាក់បានដើរទៅជាន់ទីពីរ។ ពេលកំពុងតែដើរឡើងទៅ ស្រាប់តែមានអ្នកជិតខាងឃើញក៏ស្រែកថា ចោរៗភ្លាមនោះជនរងគ្រោះក៏បើកទ្វារផ្ទះចេញមកឃើញទ្វារជណ្តើរចំហរ ហើយមេសោរបូត ក៏ផ្អើលដល់ប្រជាពលរដ្ឋ រួចចាប់ខ្លួនជនជាប់ចោទទាំងបីនាក់បាន ហើយប្រគល់ឱ្យសមត្ថកិច្ចប៉ុស្តិ៍នគរបាលទឹកថ្លាតែម្តង។

## ចាពេលសួរចម្លើយ

ជនជាប់ចោទឈ្មោះ បានឆ្លើយថា : កាលពីយប់ថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១៦ វេលាម៉ោង១និង៣០នាទីរំលងអាធ្រាត្រ ខ្លួន និង ឈ្មោះ នៅកន្លែងបាញ់ត្រីបានឲ្យឈ្មោះ ឌុបម៉ូតូជូនខ្លួនទៅទារលុយបងប្អូននៅជិតទឹកថ្លា ពេលជិះដល់ក្រោយវត្តទឹកថ្លា ស្រាប់តែឃើញផ្ទះមួយ មានទុកកង់ ខ្លួនបានដើរចូលទៅ ជាមួយឈ្មោ ក៏បានម្ជុលខ្វាស់ឆ្កិះ សោរទ្វារដើរចូលទៅក្នុងផ្ទះបំណងយកកង់តែមិនបានយកក៏ត្រូវបានម្ចាស់គេទាន់ស្រែកថាចោរៗសមត្ថកិច្ច

មកដល់ក៏ឃាត់ពួកខ្លួនតែម្តង ។ ចំណែកឈ្មោះ          នៅឈរចាំម៉ូតូខាងក្រៅ ។

ជនជាប់ចោទឈ្មោះ          បានឆ្លើយថា : ខ្លួនសុំបដិសេធ ដោយខ្លួនមិនបាន សមគំនិតក្នុងការចូលលួចទេ យប់នោះឈ្មោះ          និងឈ្មោះ          ហៅខ្លួនជាអ្នកគាំ ម៉ូតូឌុបឲ្យខ្លួនឌុបទៅដោយឲ្យខ្លួនចំនួន១០០០០(មួយម៉ឺន)រៀល ដោយប្រាប់ខ្លួនថាទៅទារលុយម្នួន ដោយខ្លួនមិនបានឮពួកគេនិយាយថាទៅលួចទេ ពេលខ្លួនឌុបទៅដល់ខ្លួនបានឈប់ម៉ូតូពួកគេ ទាំង២នាក់បាន ចុះពីលើម៉ូតូដើរសំដៅផ្ទះមួយ ហើយខ្លួនបាននៅឈរចាំចម្ងាយ២០ម៉ែត្រពីពួកគេ ហើយខ្លួនឃើញឈ្មោះ          លូកដៃចូលក្នុងក្រង់ទ្វារផ្ទះសោរឬអត់ខ្លួនអត់បានដឹងទេ ហើយខ្លួនឃើញឈ្មោះ          និងឈ្មោះ          ដើរចូលទៅ មួយសន្ទុះក៏ក្រុមសមត្ថកិច្ចចាប់ខ្លួនបាន ហើយខ្លួនក៏មិន ទាន់បានលុយពីពួកគេឡើយ។

ជនជាប់ចោទឈ្មោះ          បានឆ្លើយថា : កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ វេលាម៉ោង ប្រហែល ២លែងអាក្រាក្រ ខ្លួនបានទៅលេងហ្គេមបាញ់ត្រីនៅសង្កាត់ទឹកល្អក់៣ ជួបជាមួយឈ្មោះ          ហៅស្វា ក៏បានបបួលខ្លួនទៅលួចគេនៅម៉ុំទឹកថ្លាហើយក៏បាននាំគ្នាជិះម៉ូតូឌុបរបស់ឈ្មោះ សុជាតិ ពេលដល់ម្តុំក្រោយផ្សារទឹកថ្លាឈ្មោះ          ហៅស្វា បានឲ្យម៉ូតូឈប់ហើយឈ្មោះ          និង ខ្លួន បានដើរចូលទៅផ្ទះមួយទ្វារបិទជិត ឃើញមានកង់មួយបំណាច់ លួចយកទៅលក់បានលុយចែកគ្នា ហើយឈ្មោះ          បានលូកដៃទៅក្នុងទ្វារផ្ទះសោរទ្វារបើក នាំគ្នាដើរចូលទៅ ក៏ក្រុមម្ចាស់ផ្ទះគេស្រែក ថា ចោរៗ ក៏ក្រុម ចាប់ខ្លួនតែម្តងៗ ចំណែកឈ្មោះ សុជាតិ គ្រាន់តែជាម៉ូតូឌុបឈរ ចាំម៉ូតូមិនបាន ចូលទៅ ជាមួយទេ។

តាមអំណានចម្លើយរបស់ជនរងគ្រោះឈ្មោះ          បានឆ្លើយនៅចំពោះមុខចៅក្រមស៊ើបសួរថា កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ប្រហែលម៉ោង៨ទៀបភ្លឺពេលនោះ ខ្លួនឮសំលេងស្រែកថាចោរៗ នៅល្វែងខាងលើផ្ទះដែលខ្លួនបានសង់ជាបន្ទប់ ជួលឲ្យគេខ្លួនក៏បានបើក ទ្វារខាងក្រោយផ្ទះ ហើយឃើញសមត្ថកិច្ចកំពង់ប្រតិបត្តិការដោយកំពុង ភ្ជង់ជនសង្ស័យម្នាក់ដែលនៅពួនក្រោមជណ្តើរ ហើយសមត្ថកិច្ចក៏បានស្រែកឲ្យរាចេញមកហើយក៏ចាប់បានម្នាក់ ពេលនោះសមត្ថកិច្ចក៏បានឡើងទៅជាន់ខាងលើចាប់បានម្នាក់ទៀត ពេលនោះខ្លួនក៏បានតាមមើលសមត្ថកិច្ចបណ្តើរ ជនសង្ស័យទាំងពីរមកខាងក្រៅ ហើយក៏បានឃើញម្នាក់ទៀតដែលសមត្ថកិច្ច ឃាត់បានសរុបគឺមានជនល្មើស៣នាក់។ កន្លងមកអ្នកដែលនៅផ្ទះជួលជាន់លើ តែងតែបាត់បង់ទូរទូរទស្សន៍ កុំព្យុះទ័រ ម៉ូតូ គឺតែងតែគាស់សោរទ្វារបន្ទប់ចូលយកអីវ៉ាន់។ នៅថ្ងៃកើតហេតុនោះគឺជនសង្ស័យគាស់សោរទ្វារខាងមុខដើម្បីឡើងទៅជាន់ខាងលើ តែឡើងទៅជាន់ខាងលើមិនទាន់បានធ្វើអ្វីទេ សាក្សីបានឃើញហើយស្រែក រក់នាំគ្នាចុះមកក្រោមតែក្រុមសមត្ថកិច្ចខ្ទប់ហើយធ្វើការឃាត់ខ្លួនតែម្តង ខ្លួនបានមើលឃើញសកម្មភាពនេះតាមការមេកំសុវត្ថិភាព។ ខ្លួនសំណូមពរឲ្យផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និងមិនទាមទារសំណងជម្ងឺចិត្តអ្វីទេ ។

តាមអំណានចម្លើយរបស់សាក្សីឈ្មោះ          បានស្បថរួចហើយ បានឆ្លើយថា កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ វេលាម៉ោងជិត៨ ទៀបភ្លឺ ពេលនោះពេលនោះខ្លួនទើប ចេញពីធ្វើការហើយត្រឡប់មកផ្ទះជួលក៏ឡើងទៅលើជាន់ទី៣ អង្គុយលេងជាមួយមិត្តភក្តិ នៅជាន់នោះ ក្រោះបន្ទប់

ខ្លួននៅជាន់ទី២ភ្លេចយកសោរពុំមានអ្វីចូលក៏ត្រូវអង្គុយលេងចាំមិត្តភក្តិយកសោរមក ពេលនោះ ខ្លួនក៏បានឃើញមនុស្សប្រុសបីនាក់ ជិះម៉ូតូមកឈប់នៅមុខផ្ទះជួល ហើយហើយបានឃើញមនុស្ស ប្រុស២នាក់បានឡើងមកជាន់ទី២ ខ្លួនក៏សង្ស័យព្រោះថាអ្នកជួលផ្ទះនេះសុទ្ធតែជាអ្នកធ្វើការ និងសិស្ស តែ២នាក់នោះគឺមិនមែន ស្រាប់តែពេលនោះខ្លួនបានឃើញប៉ូលីសជិះល្បាតពីរម៉ូតូខ្លួនក៏ស្រែកថា ចោរៗ សមត្ថកិច្ចក៏បានឡើងមកជាន់លើធ្វើការឃាត់ខ្លួនបានទាំង២នាក់ ដែលឡើងមកជាន់ទី២នោះ និងម្នាក់ទៀតដែលនៅចាំនៅក្រៅ សរុបបានបីនាក់ ។ ខ្លួនបានឃើញពីនាក់ដែលឡើងមកជាន់ទី២ នោះ ធឹះសោរបន្ទប់គេ ដែលម្ចាស់បន្ទប់បានទៅស្រុកកំណើតចូលឆ្នាំអស់ ។ ពួកគេមិនទាន់ធ្លិះបានសម្រេចទេ ដោយពេលនោះខ្លួនឃើញប៉ូលីសល្បាតមកឈប់ សួរម្នាក់ទៀតដែលនៅចាំខាង ក្រៅភ្លាមខ្លួនក៏ស្រែកភ្លាមតែម្តង ។

តាមអំណាចកំណត់ហេតុទទួលវត្ថុចាប់យកលេខ៨២៨ វ.អ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ មាន៖ ១. មេសោរចិនចំនួន១

២. ទួរស៊ើវីដៃចំនួន១ (ពណ៌ខ្មៅបែកអេក្រង់ចាស់)

៣. ម៉ូតូចំនួន១គ្រឿង ម៉ាកសង់សេ១០០ ពណ៌ខ្មៅសេរី៩៧ ពាក់ស្លាកលេខ ខ៣៣៥២ ក.ណ ១ (មិនប្រក្រតី) ។

តាមអំណាចរបាយការណ៍សំយោគលេខ០៨៣/១៦ របក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៦ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខថា៖ ជនសង្ស័យចំនួន៣នាក់ ដែលឃាត់ខ្លួនបាន មាន ឈ្មោ ឈ្មោះ ឈ្មោះ ពិតជាបានប្រព្រឹត្តអំពើប៉ុនប៉ងលួច កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល ៣ និង៣០នាទី រំលងអាធ្រាត្រ នៅចំណុចផ្ទះលេខ១៣៦ ផ្លូវលំ ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រាកដមែន។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានសួរដេញដោលជនជាប់ចោទទាំង៣ ឃើញថាជនជាប់ចោទ ឈ្មោះ បានឆ្លើយសារភាពថាខ្លួនពិតជាបានប៉ុនប៉ងធ្វើ សកម្មភាពលួច ប្រព្រឹត្តនៅនៅចំណុចផ្ទះលេខ១៣៦ ផ្លូវលំ ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែន សុខ រាជធានីភ្នំពេញ ប្រាកដមែន ។ហើយឈ្មោះ វេនា និងឈ្មោ បានពិភាក្សាគ្នាដើររកលុយ ចំណែកឈ្មោះ ជាអ្នករត់ម៉ូតូឌុប នាពេលសវនាការបានឆ្លើយបដិសេធថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ តែខ្លួនបានឌុប ឈ្មោះ និងឈ្មោះ ដែលចម្លើយនេះស្របជាមួយភស្តុតាង ដែលឈ្មោ និងឈ្មោះ ចូលធ្វើសកម្មភាព ឈ្មោះ បានឈប់ម៉ូតូចម្ងាយ២០ម៉ែត្រ រីឯ ឈ្មោះ ក៏បានឆ្លើយសារភាពដូចឈ្មោះ ដែរ ចម្លើយទាំងបី គឺមានភាពស៊ីចង្វាក់គ្នាជាមួយ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយសាក្សី តែការធ្វើសកម្មភាពរបស់ជនទាំងបី គឺមិនបានសម្រេច ដូច្នេះតំណាងអយ្យការនៅតែតម្កល់ការចោទប្រកាន់ តាមដីកាសន្និដ្ឋានស្ថាពរ លេខ ២៨៥០ អ.យ.ព ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ២០១៦ ទុកដដែល សុំឱ្យតុលាការ សម្រេច ទៅតាមច្បាប់ ។

**មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា** ក្នុងពេលសវនាការកូនក្តីខ្លួនឈ្មោះ និងឈ្មោះ បានឆ្លើយសារភាពជូន តុលាការដោយបាន ដឹងពីកំហុសរបស់ខ្លួនហើយ ដូចនេះខ្លួនសុំឲ្យតុលាការជួយបន្ធូរបន្ថយទោសដល់កូនក្តីខ្លួន។ ចំពោះកូនក្តីខ្លួនឈ្មោះ បានឆ្លើយថាខ្លួនមិនបានចូលរួមប្រព្រឹត្តទេ ហើយចម្លើយនេះដូចចម្លើយនៅ សមត្ថកិច្ច និងចម្លើយនៅចៅក្រមស៊ើបសួរ ថាខ្លួនគ្រាន់តែឌុបជូនឈ្មោះ និងឈ្មោះ ទៅយកលុយប្អូនដោយទទួលតម្លៃចំនួន១០០០០(មួយម៉ឺន)រៀល ហើយអ្នកទាំងពីរបាន ឲ្យខ្លួនឈប់នៅរងចាំ ដោយមិនបានដឹងថាអ្នកទាំងពីរចូលធ្វើសកម្មភាព ផ្តិះសោរទ្វារបំណាងចូលលួច សម្ភារៈរបស់គេទេ។ ដូច្នេះហើយខ្លួនសុំឲ្យតុលាការសម្រេចឲ្យឈ្មោះ បានរួចផុតពី បទចោទប្រកាន់ ។

## ជនជាប់ចោទឆ្លើយសម្តីចុងក្រោយ

ជនជាប់ចោទឈ្មោះ បានឆ្លើយថា ៖ សុំឲ្យតុលាការមេត្តាជួយ សម្រាលទោស ដល់ខ្លួនផង ខ្លួនដឹងកំហុសហើយ ។

ជនជាប់ចោទឈ្មោះ បាននិយាយសម្តីចុងក្រោយថា ៖ សុំឲ្យតុលាការសម្រាលទោសខ្លួនដឹងកំហុសហើយ ។

ជនជាប់ចោទឈ្មោះ បាននិយាយសម្តីចុងក្រោយថា ៖ សុំឲ្យតុលាការលើកលែងចោទ ប្រកាន់ ។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនរងគ្រោះ
ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ
ក្រោយពីបានពិនិត្យភស្តុតាង
ក្រោយពីបានពិនិត្យ ពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>សំអាងហេតុ</u>

១. កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល៣ និង៣០ នាទី រំលងអាធ្រាត្រ ជនជាប់ចោទឈ្មោះ ហៅ ស្នា, ឈ្មោះ និងឈ្មោះ ពិតជាបានផ្តើមធ្វើសកម្មភាពប៉ុនប៉ងលួចទ្រព្យសម្បត្តិ នៅផ្ទះលេខ១៣៦ ផ្លូវលំ ភូមិផ្សារទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប៉ុន្តែមានអ្នកជិតខាងឃើញក៏ស្រែកថាចោរភ្លាមនោះជនរងគ្រោះក៏ភ្ញាក់ពី ដំណេកក៏បើកទ្វារចេញមកមើលឃើញ ទ្វារជណ្តើរចំហរក៏ ផ្អើលដល់ប្រជាពលរដ្ឋ នោឡោឡ ដល់ សមត្ថកិច្ចកំពុងដើរល្បាតមកដល់កន្លែងកើតហេតុក៏បានអន្តរាគមន៍ទៅឯលើផ្ទះចាប់បានជនជាប់ចោទចំនួន២នាក់ឈ្មោះ និងឈ្មោះ ចំណែកឈ្មោះ ចាប់ខ្លួនបាននៅខាង

ក្រោមកំពុងមើលម៉ូតូរងចាំអ្នកទាំងពីរយួចបង្ហស់សំណុំរឿងបញ្ជូនមកតុលាការតែម្តង ប្រាកដមែន ។

២. ជនជាប់ចោទឈ្មោះ                និងឈ្មោះ                បានឆ្លើយសារភាពថាពួកខ្លួនពិតជាបានប៉ុនប៉ងធ្វើសកម្មភាពលួចប្រាកដមែន ដែលចម្លើយសារភាពនេះ ស្របទៅនឹងចម្លើយរបស់ជនរងគ្រោះ និងសាក្សី បានឆ្លើយនៅគ្រប់ដំណាក់កាលនីតិវិធី ស្របទៅនឹងរបាយការណ៍ សំយោគរបស់មន្ត្រី នគរបាលយុត្តិធម៌ ហើយក៏ស្របទៅនឹងភស្តុតាង ជាឯកសារផ្សេងៗទៀតដែល មាននៅក្នុងសំណុំរឿង ផងដែរ ។

៣. ទោះបីជាតែនៅពេលសវនាការជនជាប់ចោទឈ្មោះ                បានឆ្លើយបដិសេធថាខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេប៉ុន្តែចម្លើយនេះគ្រាន់តែជាការដោះសារប៉ុណ្ណោះព្រោះថាតាម ចម្លើយរបស់ជនរងគ្រោះ និងចម្លើយរបស់សាក្សីបានបញ្ជាក់ថាជនជាប់ចោទពិតជាបានប៉ុនប៉ងធ្វើសកម្មភាពលួចទ្រព្យរបស់អ្នកដទៃ នៅយប់ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៦ ដែលស្របទៅ នឹងរបាយការណ៍សំយោគ ប្រាកដមែន។

៤. ជនជាប់ចោទឈ្មោះ                ឈ្មោះ                និងឈ្មោះ                ជានីតិជនដែលពុំមានភស្តុតាង ណាមួយបញ្ជាក់ថា មានបញ្ហាខាងស្មារតីឡើយ ដូច្នេះជនជាប់ចោទពិតជាមានការយល់ដឹងពីផល វិបាក ដែលកើតចេញពីអំពើប្រព្រឹត្តរបស់ខ្លួន ។

៥. សកម្មភាពប្រព្រឹត្តរបស់ជនជាប់ចោទ បានបញ្ជាក់យ៉ាងច្បាស់ពីចេតនាទុច្ចរិតក្នុងការចាប់ផ្តើមប្រព្រឹត្តសកម្មភាពយកទ្រព្យសម្បត្តិរបស់អ្នកដទៃមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ប៉ុន្តែត្រូវរអាក់ខានមិនបានសម្រេចដោយ សារតែកម្លាំងនគរបាលមកពាំងប្រាកដមែន។

៦.អំពើប្រព្រឹត្តរបស់ជនជាប់ចោទ បានធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយសណ្តាប់សាធារណៈ សន្តិសុខសង្គម និងទ្រព្យសម្បត្តិរបស់បុគ្គលឯកជនដែលច្បាប់ការពារ ។

៧. មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ                ឈ្មោ                និងឈ្មោះ                ពីបទ **ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅ ចំណុចផ្ទះលេខ១៣៦ ផ្លូវលំ ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១១ ខែមេសា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមាន ចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៧ មាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៨.ជនជាប់ចោទជាជនក្រីក្រ និងមានកម្រិតវប្បធម៌ទាប ។

៩.វត្ថុចាប់យកតម្កល់បម្រុងសមាន៖

ក. មេសោរចិនចំនួន១

ខ. ទូរស័ព្ទដៃចំនួន១ (ពណ៌ខ្មៅបែកអេក្រង់ចាស់)

គ. ម៉ូតូចំនួន១គ្រឿង ម៉ាកសង់សេ១០០ ពណ៌ខ្មៅសេរី៩៧ ពាក់ស្លាកលេខ ខ៣៣៥២ ក.ណ១ (មិនប្រក្រតី)

១០. ជនជាប់ឈ្មោះ                ត្រូវបានឃុំខ្លួនថ្ងៃទី១៣ ខែមេសា ឆ្នាំ ២០១៦ ។

១១. ជនជាប់ចោទឈ្មោះ                ត្រូវបានឃុំខ្លួនថ្ងៃ១៣ ខែមេសា ឆ្នាំ ២០១៦ ។

១២. ជនជាប់ចោទឈ្មោះ                ត្រូវបានឃុំខ្លួនថ្ងៃទ១៣ ខែមេសា ឆ្នាំ ២០១៦ ។

## ហេតុដូច្នេះសម្រេច

១. ផ្ដន្ទាទោស ៖

ក. ឈ្មោះ ហៅស្វា ភេទប្រុស អាយុ ២៦ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៤ (បួន)ឆ្នាំ

ខ. ឈ្មោះ ហៅតូក ភេទប្រុស សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៤ (បួន)ឆ្នាំ

គ. ឈ្មោះ ភេទប្រុស អាយុ ៣៧ឆ្នាំសញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់៤ (បួន)ឆ្នាំ

ពីបទ **ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុច ផ្ទះលេខ១៣៦ ផ្លូវលំ ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១៦។

តាមមាត្រា ២៧ មាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២. វត្ថុចាប់យកត្រូវរឹបអូសតាមមាត្រា៦២, មាត្រា៦៣ នៃក្រមព្រហ្មទណ្ឌគឺ៖

ក. មេសោរចិនចំនួន១

ខ. ទូរស័ព្ទដៃចំនួន១ (ពណ៌ខ្មៅបែកអេក្រង់ចាស់)

គ. ម៉ូតូចំនួន១គ្រឿង ម៉ាកសង់សេ១០០ ពណ៌ខ្មៅសេរី៩៧ ពាក់ស្លាកលេខ ខ៣៣៥២ ក.ណ ១ (មិនប្រក្រតី)។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០១៦ ចំពោះមុខជនជាប់ចោទ ចំពោះមុខមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទនិងប្រកាសជាសាធារណៈនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៦។

បើកសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **តំណាងអយ្យការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

បានចម្លងត្រឹមត្រូវ...តាមច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៦

**ក្រឡាបញ្ជី**

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

**ឧបសម្ព័ន្ធទី៩**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ ៣៨៩៥
ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦

សំណុំរឿងជំនុំជម្រះ
លេខ ៨០៣០
ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦

សាលក្រមព្រហ្មទណ្ឌ
លេខ ១១ "ក្រ៤រ"
ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧
វេលាម៉ោង ០៨ព្រឹក ដោយមានសមាសភាព៖

**<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>**

លោក អនុប្រធានសាលាដំបូងរាជធានីភ្នំពេញជាប្រធានក្រុមប្រឹក្សា
លោក ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា
លោក ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

**<u>តំណាងអយ្យការ</u>**

លោក ព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៨៩៥ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ដែលមានជនជាប់ចោទ:

ឈ្មោះ ភេទស្រី អាយុ ១៦ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ ស្ត្រីរកស៊ីផ្លូវភេទ ទីកន្លែងកំណើតនៅសង្កាត់បឹងព្រលិត ខណ្ឌ៧មករា ក្រុងភ្នំពេញ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ មិនចេះអក្សរ មានទីលំនៅមុនពេលចាប់ខ្លួ ៣០០ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ ឪពុកឈ្មោះ "ស" ម្ដាយឈ្មោះ នៅរស់ ជានិតិជន។

ឃាត់ខ្លួន នៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦។

ឃុំខ្លួន នៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៦។

ដោយមានលោក ជាមេធាវីការពារសិទ្ធិ។

ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្ទះលេខ ១៨១E₀ ផ្លូវលេខ ១២៨ ភូមិ ០៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ តាមមាត្រា ៣៥៣ , ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

ជនរងគ្រោះនិងជាដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ភេទប្រុស អាយុ ២៩ឆ្នាំ មានអាសយដ្ឋាននៅផ្ទះលេ ភូមិ ០៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ។

## អង្គហេតុ

កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ វេលាម៉ោងប្រហែល ០៣:១០នាទី ទៀបភ្លឺ នៅចំណុចផ្ទះលេខ ១៨១E₀ ផ្លូវលេខ ១៦៨ ភូមិ ០៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ មានករណីលួចមានស្ថានទម្ងន់ទោស មួយបានកើតឡើង ដែលបង្កដោយជនជាប់ចោទឈ្មោះ បានកាត់សោរទ្វាផ្ទះ លួចយកសម្ភារៈរបស់ជនរងគ្រោះឈ្មោះ ពេលកំពុងធ្វើសកម្មភាពនោះ ស្រាប់តែប្រពន្ធរបស់ជនរងគ្រោះភ្ញាក់ដឹងខ្លួនទាន់ ក៏ស្រែកចោរឡើង ហើយឈ្មោះ រត់ចុះមកក្រោម ក៏ត្រូវប្រជាជនចាប់ខ្លួនប្រគល់ឲ្យសមត្ថកិច្ចតែម្តង។

បានឃើញ របាយការណ៍សំយោគលេខ ៨១/១៦ រ.ប.ក ចុះថ្ងៃទី ១៨ សីហា ឆ្នាំ ២០១៦ របស់អធិការដ្ឋានខណ្ឌ៧មករា នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៣១៦៨ អ.យ.ធ ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ៨១២០ "ជ" ច.ជ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៦ របស់ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ។

## ដំណើរសវនាការ

ជនជាប់ចោទឈ្មោះ បានឆ្លើយថា: កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ វេលាម៉ោងប្រហែល ០៣:១០នាទី ទៀបភ្លឺ ខ្លួនបានជិះម៉ូតូឌុបមកឈប់នៅមុខផ្ទះលេខ ១៨១E₀ ផ្លូវលេខ ១៦៨ ភូមិ ០៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ហើយខ្លួនក៏ចូលទៅកាត់សោរទ្វាផ្ទះរបស់គេ លួចយកបានលេបថបចំនួន ០១គ្រឿង និងទូរស័ព្ទចំនួន ០២គ្រឿង ពេលកំពុងធ្វើសកម្មភាពនោះ ស្រាប់តែម្ចាស់គេភ្ញាក់ដឹងខ្លួនទាន់ ក៏ស្រែកចោរឡើង ហើយខ្លួនរត់ចុះមកក្រោម ក៏ត្រូវប្រជាជនឃាត់ខ្លួនប្រគល់ឲ្យសមត្ថកិច្ចតែម្តង។ ខ្លួនប្រព្រឹត្តតែម្នាក់ឯងទេ គ្មានបក្ខពួកឡើយ។

តាមអំណានចម្លើយជនរងគ្រោះនិងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ នៅចំពោះមុខចៅក្រមស៊ើបសួរថា: កាលពីថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៦ ពេលយប់ ក្រុមគ្រួសារខ្លួនបានចាក់សោរផ្ទះចូលដេក លុះដល់ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ វេលាម៉ោងប្រហែល ០៣:១០នាទី ទៀបភ្លឺ ស្រាប់តែប្រពន្ធខ្លួនបានស្រែកចោរឡើងថាមានចោរចូលលួចយកសម្ភារៈក្នុងផ្ទះ ពេលនោះជនសង្ស័យក៏រត់ចុះមកក្រោម ហើយត្រូវប្រជាជនឃាត់ខ្លួនប្រគល់ឲ្យសមត្ថកិច្ចតែម្តង។ ចំពោះសម្ភារៈដែលមានចោរលួចមានទូរស័ព្ទដៃ ០២គ្រឿង ម៉ាកសាំស៊ុង ចំនួន ០១គ្រឿង និងអាយហ្វូនចំនួន ០១គ្រឿង , ឡេបថបចំនួន ០១គ្រឿង និងខ្សែកច្បាក់ចំនួន ០១ខ្សែ តម្លៃចំនួន ១៥០ (មួយរយហាសិប)ដុល្លារអាមេរិក ហើយខ្លួនទទួលបានទូរស័ព្ទដៃ និងឡេបថប មកប្រើប្រាស់វិញហើយ តែខ្សែករកមិនឃើញ។ សំណូមពរសុំឲ្យតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់ និងសុំទាមទារថ្លៃខ្សែកដែលបាត់បង់ចំនួន ១៥០ (មួយរយហាសិប)ដុល្លារអាមេរិក។

តាមអំណានចម្លើយសាក្សីឈ្មោះ នៅចំពោះមុខចៅក្រមស៊ើបសួរថា: កាលពីថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៦ ពេលយប់ ក្រុមគ្រួសារខ្លួនបានចាក់សោរផ្ទះចូលដេក លុះដល់ថ្ងៃទី ១៣

ខែ សីហា ឆ្នាំ ២០១៦ វេលាម៉ោងប្រហែល ០៣:១០នាទី ទៀបភ្លឺ ស្រាប់តែខ្លួនឃើញមានចោរចូលលួចយកសម្ភារៈក្នុងផ្ទះ ខ្លួនក៏ស្រែកឆោឡោថាមានចោរចូលលួចយកសម្ភារៈក្នុងផ្ទះ ពេលនោះជនសង្ស័យក៏រត់ចុះមកក្រោម ក៏ត្រូវប្រជាជនឃាត់ខ្លួនប្រគល់ឲ្យសមត្ថកិច្ចតែម្តង។

តាមអំណានចម្លើយសាក្សីឈ្មោះ នៅចំពោះមុខចៅក្រមស៊ើបសួរថា: កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ វេលាម៉ោងប្រហែល ០៣:១០នាទី ទៀបភ្លឺ ពេលខ្លួនកំពុងដេក ស្រាប់តែឮសម្លេងស្រែកឆោឡោថាមានចោរគាស់ផ្ទះលួចយកសម្ភារៈ ខ្លួនក៏ក្រោកឡើងឃើញមានមនុស្សស្រីម្នាក់កំពុងកាន់ទូរសព្ទដៃរបស់ប្អូនស្រីខ្លួន ហើយឃើញតៀបលេបថបជាប់ក្លៀក ខ្លួនស្ទុះទៅចាប់ជននោះ តែជនសង្ស័យក៏រត់ចុះមកក្រោម ក៏ត្រូវប្រជាជនឃាត់ខ្លួនប្រគល់ឲ្យសមត្ថកិច្ចតែម្តង។

តាមអំណានកំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី ១៣ សីហា ឆ្នាំ ២០១៦ របស់អធិការដ្ឋានខណ្ឌ៧មករា បានបញ្ជាក់ថា: បានដំណើរការធ្វើកំណត់ហេតុចាប់យកវត្ថុតាងពីឈ្មោះ ភេទស្រី អាយុ ១៦ឆ្នាំ រួមមានកន្ត្រៃសម្រាប់កាត់ដែកចំនួន ០១ដើម មានដងពណ៌បៃតង និងស្នាប់ដៃជ័រ ពណ៌ខ្មៅ , ផ្លែឈើសម្រាប់អាដែកចំនួន ០១ដើម , កូនកន្ត្រៃដងជ័រ ពណ៌ខៀវ ចំនួន ០១ , កូនកន្ត្រៃដែកចំនួន ០១ , មេសោរម៉ាកស្វឡេច ពណ៌មាស កាត់ដាច់ ចំនួន ០១ , ទូរសព្ទដៃម៉ាក ខេមហ្វូន ចំនួន ០១គ្រឿង , ទូរសព្ទដៃ ០២គ្រឿង សាំសុង ចំនួន ០១គ្រឿង និងអាយហ្វូនចំនួន ០១គ្រឿង និងឡេបថបចំនួន ០១គ្រឿង។

តាមអំណានរបាយការណ៍សំយោគលេខ ៨១/១៦ រ.ប.ក ចុះថ្ងៃទី ១៤ សីហា ឆ្នាំ ២០១៦ របស់អធិការដ្ឋានខណ្ឌ៧មករា បានបញ្ជាក់ថា: យោងតាមរបាយការណ៍លេខ ០៧/២០១៦ រ.ប.ក ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ , ពាក្យបណ្តឹង ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ , កំណត់ហេតុបណ្តឹង ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ របស់ឈ្មោះ , កំណត់ហេតុស្តាប់ការបំភ្លឺរបស់កសិណសាក្សី ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ របស់សាក្សីឈ្មោះ និងឈ្មោះ , កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ របស់ឈ្មោះ , កំណត់ហេតុប្រគល់ និងទទួលជនសង្ស័យ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ , កំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ , កំណត់ហេតុឃាត់ខ្លួនពីបទល្មើសជាក់ស្តែង ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ , កំណត់ហេតុសរុបនៃការឃាត់ខ្លួនជនសង្ស័យ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ , ពាក្យស្នើសុំសម្ភារៈ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ , កំណត់ហេតុប្រគល់សម្ភារៈ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ , រូបថតប្រគល់សម្ភារៈឲ្យជនរងគ្រោះ និងរូបថតជនសង្ស័យ សន្និដ្ឋានថា ជនសង្ស័យឈ្មោះ ពិតជាបានប្រព្រឹត្តអំពើ លួចមានស្ថានទម្ងន់ទោស (គាស់ទម្លុះទម្លាយ) យកសម្ភារៈរបស់ជនរងគ្រោះ នៅចំណុចផ្ទះលេខ ១៨១E₀ ផ្លូវលេខ ១២៨ ភូមិ ០៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ វេលាម៉ោង ០៣:១០នាទី ទៀបភ្លឺ ប្រាកដមែន។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថាសូមតម្កល់ការចោទប្រកាន់ទុកជាបានការដដែល និងប្តឹងសុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា សុំឲ្យតុលាការសម្រេចបន្ធូរបន្ថយទោសដល់កូនក្តីខ្លួន។

## សម្តីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោះ បាននិយាយសម្តីចុងក្រោយថា: សុំឲ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួន។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាងនានា

ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១.កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ វេលាម៉ោងប្រហែល ០៣:១០នាទី ទៀបភ្លឺ នៅចំណុចផ្ទះលេខ ១៨១E₀ ផ្លូវលេខ ១២៨ ភូមិ ០៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ មានករណីលួចមានស្ថានទម្ងន់ទោស មួយបានកើតឡើង ដែលបង្កដោយជនជាប់ចោទឈ្មោះ បានកាត់សោរទ្វាផ្ទះ លួចយកសម្ភារៈរបស់ជនរងគ្រោះឈ្មោះ ពេលកំពុងធ្វើសកម្មភាពនោះ ស្រាប់តែប្រពន្ធរបស់ជនរងគ្រោះភ្ញាក់ដឹងខ្លួនទាន់ ក៏ស្រែកចោរឡើង ហើយឈ្មោះ រត់ចុះមកក្រោម ក៏ត្រូវប្រជាជនចាប់ខ្លួនប្រគល់ឲ្យសមត្ថកិច្ច ប្រាកដមែន។

២.នាពេលចុះប្រតិបត្តិការឃាត់ខ្លួនជនជាប់ចោទ សមត្ថកិច្ចដកហូតបានកន្ត្រៃសម្រាប់កាត់ដែកចំនួន ០១ដើម មានដងពណ៌បៃតង និងស្លាប់ដៃជ័រ ពណ៌ខ្មៅ , ផ្លែរណាសម្រាប់អាដែកចំនួន ០១ដើម , កូនកន្ត្រៃដងជ័រ ពណ៌ខៀវ ចំនួន ០១ , កូនកន្ត្រៃដែកចំនួន ០១ , មេសោរម៉ាកសូឡេចពណ៌មាស កាត់ដាច់ ចំនួន ០១ , ទូរសព្ទដៃម៉ាក ខេមហ្វូន ចំនួន ០១គ្រឿង , ទូរសព្ទដៃ ០២គ្រឿង សាំសុង ចំនួន ០១គ្រឿង , អាយហ្វូនចំនួន ០១គ្រឿង និងឡេបថបចំនួន ០១គ្រឿង មានដូចក្នុងកំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី ១៣ សីហា ឆ្នាំ ២០១៦ របស់អធិការដ្ឋានខណ្ឌ៧មករា។

៣.តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ មានភាពស៊ីចង្វាក់ទាំងស្រុងជាមួយ:

ក.ពាក្យបណ្តឹង ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦

ខ.កំណត់ហេតុបណ្តឹង ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦

គ.កំណត់ហេតុស្តាប់ការបំភ្លឺរបស់កសិណសាក្សី ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦

ឃ.កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦

ង.កំណត់ហេតុប្រគល់ និងទទួលជនសង្ស័យ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦

ច.កំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦

ឆ.កំណត់ហេតុឃាត់ខ្លួនពិបទល្មើសជាក់ស្តែង ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦

ជ.កំណត់ហេតុសរុបនៃការឃាត់ខ្លួនជនសង្ស័យ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦

ឈ.របាយការណ៍លេខ ០៧/២០១៦ រ.ប.ក ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦

ញ.របាយការណ៍សំយោគលេខ ៨១/១៦ រ.ប.ក ចុះថ្ងៃទី ១៤ សីហា ឆ្នាំ ២០១៦ របស់មន្ត្រីនគរបាលយុត្តិធម៌ ដែលអាចឲ្យជឿបានថាជនជាប់ចោទឈ្មោះ ពិតជាបានប្រព្រឹត្តអំពើ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្ទះលេខ ១៨១E₀ ផ្លូវលេខ ១២៨ ភូមិ ០៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ ប្រាកដមែន។

៤.ជនជាប់ចោទឈ្មោះ ភេទស្រី អាយុ ១៦ឆ្នាំ ជាអនីតិជន ដែលពុំមានភស្តុតាងណាមួយបញ្ជាក់ថា មានបញ្ហាខាងស្មារតីឡើយ ដូច្នេះជនជាប់ចោទពិតជាមានស្មារតីយល់ដឹងពីផលវិបាក ដែលកើតចេញពីអំពើប្រព្រឹត្តរបស់ខ្លួន ដោយដឹងយ៉ាងច្បាស់ថាពុំមានសិទ្ធិណាមួយតាមច្បាប់ក្នុងការប្រព្រឹត្តអំពើទុច្ចរិត ប៉ុន្តែនៅតែប្រព្រឹត្តដោយចេតនាទុច្ចរិត ដែលច្បាប់បានកំណត់ថាជាបទល្មើសព្រហ្មទណ្ឌនិងត្រូវផ្តន្ទាទោស តែដោយជនជាប់ចោទជាអនីតិជន គប្បីពិចារណាទៅលើមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

៥.សកម្មភាពប្រព្រឹត្តរបស់ជនជាប់ចោទបានបញ្ជាក់យ៉ាងច្បាស់ពីចេតនាទុច្ចរិតក្នុងការលួចយកទ្រព្យសម្បត្តិអ្នកដទៃ មកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនប្រាកដមែន។

៦.អំពើប្រព្រឹត្តរបស់ជនជាប់ចោទ បានធ្វើឲ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ សន្តិសុខសង្គម និងទ្រព្យសម្បត្តិរបស់បុគ្គលឯកជន ដែលច្បាប់បានហាមឃាត់។

៧.សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ មានមូលដ្ឋានគ្រប់គ្រាន់ ដើម្បីបញ្ជាក់អំពីតម្រុយពិរុទ្ធភាពរបស់ជនជាប់ចោទ ដែលតុលាការគប្បីពិចារណា និងសម្រេច។

៨.សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ សុំឲ្យតុលាការបន្ធូរបន្ថយទោសដល់កូនក្តីនោះ គប្បីតុលាការពិចារណា។

៩.មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ ភេទស្រី អាយុ ១៦ឆ្នាំ ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្ទះលេខ ១៨១E₀ ផ្លូវលេខ ១២៨ ភូមិ ០៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ តាមមាត្រា ៣៥៣ , ៣៥៧ , ១៦០ នៃក្រមព្រហ្មទណ្ឌ។

១០.វត្ថុចាប់យក មានដូចក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ១០៣៧ វ.ត ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៦ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ គឺទូរសព្ទដៃចំនួន ០១គ្រឿង ម៉ាកខេមហ្វូន ពណ៌ទឹកប្រាក់ (ចាស់ , ខូច) , កន្ត្រៃសម្រាប់កាត់ដែកចំនួន ០១ដើម , ផ្លែរណាចំនួន ០១ , កូនកន្ត្រៃចំនួន ០២ និងមេសោរស្ទៀកោកាត់ដាច់ចំនួន ០១ គប្បីសម្រេចរឹបអូស តាមមាត្រា ៦២ , ៦៣ នៃក្រមព្រហ្មទណ្ឌ។

១១.ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ បានទទួលទូរសព្ទដៃ ០២គ្រឿង ម៉ាកសាំសុង ចំនួន ០១គ្រឿង និងអាហ្វូនចំនួន ០១គ្រឿង , ឡេបថបចំនួន ០១គ្រឿង វិញហើយ តាមកំណត់ហេតុប្រគល់ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលមិត្តភាព គប្បីតុលាការពុំលើកមកពិចារណា។

១២.ដើមបណ្ដឹងរដ្ឋប្បវេណីបានប្ដឹងទាមទារថ្លៃខ្សែកដែលបាត់បង់ចំនួន ១៨០ (មួយរយប៉ែតសិប)ដុល្លាអាមេរិក គប្បីតុលាការសម្រេចតាមការជាក់ស្ដែង។

១៣.សំដីចុងក្រោយរបស់ជនជាប់ចោទ បានសុំឲ្យតុលាការបន្ធូរបន្ថយទោស គប្បីតុលាការពិចារណា។

## <u>ហេតុដូច្នេះសម្រេច</u>

១-ផ្ដន្ទាទោសឈ្មោះ ភេទស្រី អាយុ ១៦ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០២ (ពីរ)ឆ្នាំ

ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្ទះលេខ ១៨១E₀ ផ្លូវលេខ ១២៨ ភូមិ ០៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ តាមមាត្រា ៣៥៣ , ៣៥៧ , ១៦០ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឲ្យជនជាប់ចោទឈ្មោះ រួមទាំងអាណាព្យាបាលសងសំណងការខូចខាតចំនួន ១៧០ (មួយរយចិតសិប)ដុល្លាអាមេរិក ទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ

៣-វត្ថុចាប់យក ដែលត្រូវរឹបអូស តាមមាត្រា ៦២ , ៦៣ នៃក្រមព្រហ្មទណ្ឌ គឺទូរសព្ទដៃចំនួន ០១គ្រឿង ម៉ាកខេមហ្វូន ពណ៌ទឹកប្រាក់ (ចាស់ , ខូច) , កន្ត្រៃសម្រាប់កាត់ដែកចំនួន ០១ដើម , ថ្លេរណាចំនួន ០១ , កូនត្រៃចំនួន ០២ និងមេសោរស្ទៀចកាត់ដាច់ចំនួន ០១។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៧ ចំពោះមុខជនជាប់ចោទ , មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ , កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី។

បើកសិទ្ធិប្ដឹងទាស់ ឬប្ដឹងឧទ្ធរណ៍ តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៧

**ក្រឡាបញ្ជី**

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

**ឧបសម្ព័ន្ធទី១០**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

លេខ ៥៥៣ "ណក្រ៦"

ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២

-សំណុំរឿងព្រហ្មទណ្ឌលេខ ៣៧៨១

ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២១

-សំណុំរឿងស៊ើបសួរលេខ ២៨៤៤

ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១

-សំណុំរឿងជំនុំជម្រះលេខ ៨២៦

ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ០៩ និង០០ នាទីព្រឹក នៅសាលសវនាការទី១ ជាន់ទី១ នៃសាលាដំបូងរាជធានីភ្នំពេញ ដោយមានសមាសភាពជំនុំជម្រះ ដូចខាងក្រោម ៖

**<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>**

លោក ប្រធានក្រុមប្រឹក្សាជំនុំជម្រះនៃសាលាដំបូងរាជធានីភ្នំពេញ

លោកស្រី ចៅក្រមប្រឹក្សាជំនុំជម្រះនៃសាលាដំបូងរាជធានីភ្នំពេញ

លោក ចៅក្រមប្រឹក្សាជំនុំជម្រះនៃសាលាដំបូងរាជធានីភ្នំពេញ

**<u>តំណាងអយ្យការ</u>**

លោក ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៧៨១ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានជនជាប់ចោទ ៖

១-ឈ្មោះ KENT WIJAYA ភេទប្រុស អាយុ៤៤ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី កាន់លិខិតឆ្លងដែនលេខ X៧៣៣៦៥៤ មុខរបរ អ្នកជំនួញ ទីកន្លែងកំណើតប្រទេសឥណ្ឌូនេស៊ី ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅអាផាតមិន បឹងទន្លេសាប ស្ថិតនៅផ្ទះលេខ១៣ ផ្លូវ៧០ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ HOK WIJAYA "រស់" ម្ដាយឈ្មោះ LIE YINGYING "រស់" ប្រពន្ធឈ្មោះ WENA មានកូន ០២នាក់ ជាតិជន ។

ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន។ (ក្នុងឃុំ)

បច្ចុប្បន្នកំពុងឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ (ម១) តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦៥៤៧ "ជ១" ដ.ឃ.ដ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

២-ឈ្មោះ RUDI SUPARNO ភេទប្រុស អាយុ៤២ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី មុខរបរ គណនេយ្យករ កាន់លិខិតឆ្លងដែនលេខ C៩៥២០៧៥៤ ទីកន្លែងកំណើតMEDAN ប្រទេសឥណ្ឌូនេស៊ី ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះលេខ៣៤ ផ្លូវលេខ១៥ ភូមិបឹងឈូក សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ YUAN CANG XI "រស់" ម្ដាយឈ្មោះ DEN QIAN JU "រស់" ប្រពន្ធឈ្មោះ HARUMI COSASI មានកូន ០២នាក់ ជាតិជន។

ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន។ (ក្នុងឃុំ)

បច្ចុប្បន្នកំពុងឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ (ម១) តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦៥៤៣ "ជ១" ដ.ឃ.ដ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

២៥. ការអនុវត្តទោសបន្ថែម ផ្អែកតាមបញ្ញត្តិមាត្រា ២៥៥ ចំណុចទី៤ នៃក្រមព្រហ្មទណ្ឌ បានចែងអំពី "ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ឆ្នាំយ៉ាងច្រើន"។ តុលាការការយល់ឃើញថា តាមបញ្ញត្តិមាត្រាខាងលើនេះ គឺស្របទៅនឹងលិខិតលេខ ២៣៥៥ ល.ស ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ របស់អគ្គស្នងការ នៃស្នងការដ្ឋាននគរបាលជាតិ ដែលសំណើសុំគោលការណ៍បញ្ជូនជនជាតិឥណ្ឌូនេស៊ីចំនួន ០៥ នាក់ មាន ៖ ១-ឈ្មោះ KENT WIJAYA ភេទប្រុស ជនជាតិឥណ្ឌូនេស៊ី ២-ឈ្មោះ RUDI SUPARNO ភេទប្រុស ជនជាតិឥណ្ឌូនេស៊ី ៣-ឈ្មោះ HENDRA CAHYADI ភេទប្រុស ជនជាតិឥណ្ឌូនេស៊ី ៤-ឈ្មោះ RUDY GUNAWAN ភេទប្រុស ជនជាតិឥណ្ឌូនេស៊ី៥-ឈ្មោះ RODIH CANDIAWAN ភេទប្រុស ជនជាតិឥណ្ឌូនេស៊ី ទៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដើម្បីធ្វើការបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា ក្រោយពីអនុវត្តទោសរួចរាល់។ គប្បីតុលាការពិចារណា និងសម្រេចតាមនីតិវិធីច្បាប់។

២៦. ជនរងគ្រោះទាំងពីរ ពុំបានចូលតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខតុលាការ ដើម្បីទាមទារសំណងរដ្ឋប្បវេណី ឬសំណងជម្ងឺចិត្តពីជនជាប់ចោទទេ ។ ហេតុនេះ តុលាការមិនពិចារណាសម្រេចអំពីសំណងរដ្ឋប្បវេណី ឬសំណងជម្ងឺចិត្តនោះទេ។

២៧. គ្រឿងញៀនដែលមានក្នុងកំណត់ហេតុខូលវត្ថុចាប់យក(២) លេខ ១៦០៩ វ.វ.ត ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២១ របស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ត្រូវបានតុលាការសម្រេចរឹបអូស និងប្រគល់ជូនគណៈកម្មការបំផ្លាញគ្រឿងញៀន នៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធីរួចហើយ តាមរយៈសាលក្រមព្រហ្មទណ្ឌមុនអង្គសេចក្តីលេខ ៣៧ "ណក្រ៦" ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ។ ហេតុនេះតុលាការមិនលើកយកមកសម្រេចម្តងទៀតទេ។

## <u>ហេតុដូច្នេះ សម្រេច</u>

**១/-កែប្រែបទចោទប្រកាន់លើជនជាប់ចោទ ៖**

១.១-ឈ្មោះ KENT WIJAYA ភេទប្រុស អាយុ៤៩ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី

១.២-ឈ្មោះ RUDI SUPARNO ភេទប្រុស អាយុ៤២ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី

១.៣-ឈ្មោះ HENDRA CAHYADI ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី

១.៤-ឈ្មោះ RUDY GUNAWAN ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី

១.៥-ឈ្មោះ RODIH CANDIAWAN ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី

ដែលមានអត្តសញ្ញាណដូចខាងលើ ពីបទ ៖ បង្ខាំងមនុស្សដោយខុសច្បាប់ធ្វើទារុណកម្ម ដើម្បីជំរិតទារប្រាក់ ប្រព្រឹត្តនៅចំណុច អាផាតមិន បឹងទន្លេសាប ស្ថិតនៅផ្ទះលេខ១៣ ផ្លូវ៧០ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ និងចំណុច SKY TREE APARTMENT ស្ថិតនៅផ្លូវលេខ១០៥ សង្កាត់ទួលសង្កែ១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ និងថ្ងៃទី៣០ ខែសីហា និងថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥៤ នៃក្រមព្រហ្មទណ្ឌ មកបទ ចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់ តាមបញ្ញត្តិមាត្រា ២៥៣ នៃក្រមព្រហ្មទណ្ឌ វិញ។

១.៦-កែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ PENG HUA ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី ដែលមានអត្តសញ្ញាណដូចខាងលើ ពីបទ៖ បង្ខាំងមនុស្សដោយខុសច្បាប់ធ្វើទារុណកម្មដើម្បីជំរិតទារប្រាក់ ប្រព្រឹត្តនៅចំណុចសណ្ឋាគារផាលេស ស្ថិតនៅបណ្តោយផ្លូវព្រះស៊ីសុវត្ថិ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ និងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥៤ នៃក្រមព្រហ្មទណ្ឌ មកបទ ចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់ តាមបញ្ញត្តិមាត្រា ២៥៣ នៃក្រមព្រហ្មទណ្ឌ វិញ។

១.៧-កែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ គង់ វស្សី ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ ដែលមានអត្តសញ្ញាណដូចខាងលើ ពីបទ ៖ សមគំនិតក្នុងអំពើបង្ខាំងមនុស្សដោយខុសច្បាប់ធ្វើទារុណកម្មដើម្បីជំរិតទារប្រាក់ ប្រព្រឹត្តនៅចំណុច SKY TREE APARTMENT ស្ថិតនៅផ្លូវលេខ១០៥ សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ និងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ និងមាត្រា ២៥៤ នៃក្រមព្រហ្មទណ្ឌ មកបទ សមគំនិតក្នុងអំពើចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់ តាមបញ្ញត្តិមាត្រា ២៩ និងមាត្រា ២៥៣ នៃក្រមព្រហ្មទណ្ឌ វិញ។

**២./-ឲ្យជនជាប់ចោទ ៖**

២.១-ឈ្មោះ KENT WIJAYA ភេទប្រុស អាយុ៤៥ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី

២.២-ឈ្មោះ RUDI SUPARNO ភេទប្រុស អាយុ៤២ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី

រួចខ្លួនពីបទចោទប្រកាន់ ពីបទ ៖ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច អាផាតមិនបឹងទម្លេសាប ស្ថិតនៅផ្ទះលេខ១៣ ផ្លូវលេខ៧០ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**៣./-ផ្តន្ទាទោសជនជាប់ចោទ ៖**

៣.១-ឈ្មោះ KENT WIJAYA ភេទប្រុស អាយុ៤៥ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី មានអត្តសញ្ញាណដូចខាងលើ

៣.២-ឈ្មោះ RUDI SUPARNO ភេទប្រុស អាយុ៤២ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី មានអត្តសញ្ញាណដូចខាងលើ

ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់ **០១ ឆ្នាំ ០២ ខែ (មួយឆ្នាំ ពីរខែ)**

ពីបទ ៖ ចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់ ប្រព្រឹត្តនៅចំណុច អាផាតមិន បឹងទម្លេសាប ស្ថិតនៅផ្ទះលេខ ១៣ ផ្លូវ៧០ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ និងចំណុច SKY TREE APARTMENT ស្ថិតនៅផ្លូវលេខ១០៥ សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ និងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥៣ នៃក្រមព្រហ្មទណ្ឌ។

៣.៣-ឈ្មោះ PENG HUA ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិចិន មានអត្តសញ្ញាណដូចខាងលើ

ដាក់ពន្ធនាគារ កំណត់ **២ ឆ្នាំ (ពីរឆ្នាំ)**

ពីបទ ៖ ចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់ ប្រព្រឹត្តនៅចំណុច សណ្ឋាគារផាលេស ស្ថិតនៅបណ្តោយផ្លូវព្រះស៊ីសុវត្ថិ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ និងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥៣ នៃក្រមព្រហ្មទណ្ឌ។

៣.៤-ឈ្មោះ HENDRA CAHYADI ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី មានអត្តសញ្ញាណដូចខាងលើ

៣.៥-ឈ្មោះ RUDY GUNAWAN ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី មានអត្តសញ្ញាណដូចខាងលើ

៣.៦-ឈ្មោះ RODIH CANDIAWAN ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី មានអត្តសញ្ញាណដូចខាងលើ

ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់ **២ឆ្នាំ ០៦ខែ (ពីរឆ្នាំ ប្រាំមួយខែ)**

ពីបទ ៖ ចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់ និងបទ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច អាផាតមិន បឹងទម្លេសាប ស្ថិតនៅផ្ទះលេខ១៣ ផ្លូវ៧០ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ និងចំណុច SKY TREE APARTMENT ស្ថិតនៅផ្លូវលេខ១០៥ សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ និងថ្ងៃទី៣០ ខែសីហា និងថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥៣ នៃក្រមព្រហ្មទណ្ឌ និងតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣.៧-ឈ្មោះ គង់ វស្សី ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ មានអត្តសញ្ញាណដូចខាងលើ

ដាក់ពន្ធនាគារ កំណត់ ០១ ឆ្នាំ (មួយឆ្នាំ) តែទោសនេះអនុវត្តក្នុងពន្ធនាគាររយៈពេល ២ ខែ ១៤ ថ្ងៃ (ពីរខែដប់បួនថ្ងៃ) ទោសសល់ពីនេះត្រូវព្យួរធម្មតា

ពីបទ ៖ សមគំនិតក្នុងអំពើចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់ ប្រព្រឹត្តនៅចំណុច SKY TREE APARTMENT ស្ថិតនៅផ្លូវលេខ១០៥ សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ និងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ និងមាត្រា ២៥៣ នៃក្រមព្រហ្មទណ្ឌ។

៣.៨-ឈ្មោះ ZHENG YINGFEI ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិចិន កាន់លិខិតឆ្លងដែនលេខ E៣២៥១៤៣១៨។ (គេចខ្លួន)

ដាក់ពន្ធនាគារកំណត់ ២៧ឆ្នាំ (ម្ភៃប្រាំពីរឆ្នាំ) និងទោសពិន័យជាប្រាក់ចំនួន ៨០,០០០,០០០៛ (ប៉ែតសិបលានរៀល)

ពីបទ ៖ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច អាផាតមិន បឹងទំពុនសាប ស្ថិតនៅផ្ទះលេខ ១៣ ផ្លូវលេខ៧០ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៤./ រឹបអូសវត្ថុចាប់យក ដែលជាមធ្យោបាយសម្រាប់ការប្រព្រឹត្តបទល្មើស តាមបញ្ញត្តិមាត្រា ៦២ និងបញ្ញត្តិមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ នូវ ៖

៤.១-ទូរស័ព្ទម៉ាក IPHONE ពណ៌ស (បែកអេក្រង់) ចំនួន ០១ គ្រឿង (មិនដំណើរការ)។

៤.២-ទូរស័ព្ទម៉ាក VIVO ពណ៌ខៀវ ចំនួន ០១ គ្រឿង (មិនដំណើរការ)

៤.៣-ទូរស័ព្ទម៉ាក IPHONE ពណ៌ទឹកមាស ចំនួន ០១ គ្រឿង (មិនដំណើរការ)

៤.៤-ទូរស័ព្ទម៉ាក IPHONE ពណ៌ខ្មៅ ចំនួន ០១ គ្រឿង (មិនដំណើរការ)។

៤.៥-ទូរស័ព្ទដៃម៉ាក HUAWEI ពណ៌ទឹកប្រាក់ ចំនួន ០១ គ្រឿង (មិនដំណើរការ)

៤.៦-ទូរស័ព្ទម៉ាក OPPO ពណ៌ខ្មៅ ចំនួន ០១ គ្រឿង (មិនដំណើរការ)

៤.៧-ទូរស័ព្ទម៉ាក IPHONE ពណ៌ខ្មៅ ចំនួន ០១ គ្រឿង (មិនដំណើរការ)

៤.៨-ទូរស័ព្ទម៉ាក REDMI ពណ៌ស ចំនួន ០១ គ្រឿង (មិនដំណើរការ)

៤.៩-ឧបករណ៍ប្រើប្រាស់សារធាតុញៀនមួយ ចំនួន

៤.១០-ជញ្ជីងថ្លឹងម៉ាក PERFECT ចំនួន ០១ គ្រឿង

៤.១១-ស្លាប់ដៃ ចំនួន ០១

៤.១២-ឧបករណ៍ប្រើប្រាស់សារធាតុញៀន មួយចំនួន

៤.១៣-ឡោះច្រវ៉ាក់ ចំនួន ០១

៤.១៤-ម៉ាស៊ីន ម៉ូនីទ័រ ចំនួន ០១។

៤.១៥-ទូរស័ព្ទម៉ាក IPHONE 12 PRO MAX ពណ៌ប្រផេះ ចំនួន ០១ គ្រឿង

៤.១៦-ទូរស័ព្ទម៉ាក IPHONE 12 PRO MAX ពណ៌ខៀវ ចំនួន ០១ គ្រឿង

៤.១៧-កុំព្យូទ័រលើតុ ចំនួន ០២ គ្រឿង

៤.១៨-កុំព្យូទ័រយួរដៃ ចំនួន ០១ គ្រឿង

៥./ ប្រគល់វត្ថុចាប់យកឱ្យទៅម្ចាស់ដើមវិញ តាមបញ្ញត្តិមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នូវ ៖

**-វត្ថុតាងដែលដកហូត ពីឈ្មោះ គង់ ស្មើ មាន ៖**

៥.១-ទូរស័ព្ទម៉ាក REALME ពណ៌ខៀវ ចំនួន ០១ គ្រឿង (មិនដំណើរការ)។

**-វត្ថុតាងដែលដកហូត ពីឈ្មោះ** RODIH CANDIAWAN **រួមមាន ៖**

៥.២-លិខិតឆ្លងដែនឥណ្ឌូនេស៊ី លេខ A4810187 ចំនួន ០១

៥.៣-បណ្ណចាក់វ៉ាក់សាំងកូវីដ ១៩ ចំនួន ០១

៥.៤-កាបូបដៃពណ៌ត្នោត ចំនួន ០១

៥.៥-អត្តសញ្ញាណបណ្ណឥណ្ឌូនេស៊ី ចំនួន ០១

៥.៦-បណ្ណបើកបរឥណ្ឌូនេស៊ី ចំនួន ០២

៥.៧-កាតផ្សេងៗ ចំនួន ០២

៥.៨-ប្រាក់ឥណ្ឌូនេស៊ីចំនួន ១០០០ (មួយពាន់)

៥.៩-ប្រាក់ដុល្លារអាមេរិច ១ (មួយ) ដុល្លារ។

**-វត្ថុតាងដែលដកហូតពីឈ្មោះ** HENDRA CAHYADI **រួមមាន ៖**

៥.១០-សៀវភៅការងារជនបរទេស ចំនួន ០១

៥.១១-អត្តសញ្ញាណបណ្ណឥណ្ឌូនេស៊ី ចំនួន ០១

៥.១២-បណ្ណចាក់វ៉ាក់សាំងកូវីដ ១៩ ចំនួន ០១

៥.១៣-លិខិតឆ្លងដែនឥណ្ឌូនេស៊ី លេខ C0578170 ចំនួន ០១

៥.១៤-កាត VISA ABA ចំនួន ០១

**-វត្ថុតាងដែលដកហូតពីឈ្មោះ** RUDY GUNAWAN **រួមមាន ៖**

៥.១៥-បណ្ណចាក់វ៉ាក់សាំងកូវីដ ១៩ ចំនួន ០១

៥.១៦-សៀវភៅការងារជនបរទេស ចំនួន ០១

៥.១៧-លិខិតឆ្លងដែនឥណ្ឌូនេស៊ី ចំនួន ០២

**-វត្ថុតាងដែលដកហូតពីឈ្មោះ** KENT WIJAYA **រួមមាន ៖**

៥.១៨-កាតរបស់ក្រុមហ៊ុន វីអូអេចឡូជីស្ទិក & ត្រេនស្ព័តឯ.ក ចំនួន ០១

៥.១៩-កាតធនាគារ ចំនួន ១២

៥.២០-ប័ណ្ណចាក់វ៉ាក់សាំងកូវីដ ១៩ ចំនួន ០១

៥.២១-អត្តសញ្ញាណបណ្ណឥណ្ឌូនេស៊ី ចំនួន ០១

៥.២២-បណ្ណបើកបរខ្មែរ ចំនួន ០១

៥.២៣-សៀវភៅការងារជនបរទេស ចំនួន ០១

៥.២៤-បណ្ណសម្គាល់យានយន្ត ផ្លាកលេខ ភ្នំពេញ 2AG -9985 (ថតចម្លង)

៥.២៥-បណ្ណសម្គាល់យានយន្ត ផ្លាកលេខ ភ្នំពេញ 2BI -5538 (ថតចម្លង)

៥.២៦-កាបូបដៃបុរសម៉ាក TOUGH ពណ៌ខ្មៅ ចំនួន ០១

៥.២៧-កាបូបដៃម៉ាក LV ពណ៌ខ្មៅ ចំនួន ០១

៥.២៨-សៀវភៅធនាគារ ចំនួន ០៣ ក្បាល

៥.២៩-លិខិតបញ្ជាក់ទីលំនៅរបស់ឈ្មោះ KENT WIJAYA ចំនួន ០១ សន្លឹក

**-វត្ថុតាងដែលដកហូតពីឈ្មោះ** RUDI SUPARNO **រួមមាន ៖**

៥.៣០-កាតធនាគារ ABA ចំនួន ០១

៥.៣១-កាតធនាគារ MAY BANK ចំនួន ០១

៥.៣២-កាតធនាគារ CIMB NIAGA ចំនួន ០១

៥.៣៣-សៀវភៅការងារជនបរទេស ចំនួន ០២

៥.៣៤-អត្តសញ្ញាណបណ្ណឥណ្ឌូនេស៊ី ចំនួន ០១

៥.៣៥-កាតផ្សេងៗ ចំនួន ០២

៥.៣៦-លិខិតឆ្លងដែនឥណ្ឌូនេស៊ី លេខ C1520754 ចំនួន ០១

**-វត្ថុតាងដែលឆែកឆេរបាននៅ** SKY TREE APARTMENT **រួមមាន ៖**

៥.៣៧-កិច្ចសន្យាជួលខុនដូទន្លេសាប ០១ ច្បាប់

៥.៣៨-ឯកសារ មួយចំនួន។

៦-/ ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ ZHENG YINGFEI ភេទប្រុស ជនជាតិចិន និងជនជាប់ចោទឈ្មោះ PENG HUA ភេទប្រុស ជនជាតិចិន ដើម្បីយកមកអនុវត្តទោសតាមអំណាចសាលក្រមនេះ និងធ្វើការឃុំខ្លួនតាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**៧-/ អនុវត្តទោសបន្ថែមលើជនជាប់ចោទ ៖**

៧.១-ឈ្មោះ KENT WIJAYA ភេទប្រុស អាយុ៥៥ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី

៧.២-ឈ្មោះ RUDI SUPARNO ភេទប្រុស អាយុ៥២ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី

៧.៣-ឈ្មោះ HENDRA CAHYADI ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី

៧.៤-ឈ្មោះ RUDY GUNAWAN ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី

៧.៥-ឈ្មោះ RODIH CANDIAWAN ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី

ការហាមឃាត់មិនឱ្យជនបរទេសចំពោះការចូល និងស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់រយៈពេល **៥ឆ្នាំ (ប្រាំឆ្នាំ)** ក្រោយអនុវត្តទោសចប់ តាមបញ្ញត្តិមាត្រា ២៥៥ ចំណុចទី៤ នៃក្រមព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២

-ចំពោះមុខជនជាប់ចោទ ៖ ១.ឈ្មោះ KENT WIJAYA, ២.ឈ្មោះ RUDI SUPARNO, ៣.ឈ្មោះ HENDRA CAHYADI, ៤.ឈ្មោះ RUDY GUNAWAN, ៥.ឈ្មោះ RODIH CANDIAWAN និងចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ៖ ១.មេធាវី ២.មេធាវី , ៣.មេធាវី ៤.មេធាវី , ៥.មេធាវី ។

-កំបាំងមុខជនជាប់ចោទឈ្មោះ ជនជាប់ចោទឈ្មោះ ZHENG YINGFEI និងជនជាប់ចោទឈ្មោះ PENG HUA។

-កំបាំងមុខជនរងគ្រោះឈ្មោះ ជីមមី (Mr.JIMMY), ជនរងគ្រោះឈ្មោះ ថូមមី ធី ជែមេឡាង (TOMMY T JEMERLANG)។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
| --- | --- | --- | --- |
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

---

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃសុក្រ ១៤កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

**ឧបសម្ព័ន្ធទី១១**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

**សាលក្រមព្រហ្មទណ្ឌ**
**លេខ: ៣២០៩ "វ"**
**ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០**
**-សំណុំរឿងព្រហ្មទណ្ឌលេខ: ៣៥២១**
**ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨**
**-សំណុំរឿងជំនុំជម្រះផ្ទាល់លេខ: ៣៩១៥**
**ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨**

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង២ និង ៣០ នាទី នៅសាលសវនាការទី៤ ដោយមានសមាសភាព ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះផ្ទាល់លើសំណុំរឿងព្រហ្មទណ្ឌលេខ: ៣៥២១ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ ដែលមានជនជាប់ចោទដូចខាងក្រោមនេះ៖

១.ឈ្មោះ [redacted] ភេទប្រុស អាយុ៥១ឆ្នាំ សញ្ជាតិខ្មែរ មុខរបរគ្រូពេទ្យ សាសនា ព្រះពុទ្ធ ទីកន្លែងកំណើត នៅភូមិអង្គតាសោម ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ:១៧៥៤ ផ្លូវលេខ៦២ ក្រុមទី៤ ភូមិផ្សារតូច សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] "ស្លាប់" ប្រពន្ធឈ្មោះ [redacted] មានកូន០៣នាក់ ទោសពីមុនគ្មាន ។ (**ក្រៅឃុំ**)

-លោកមេធាវី [redacted] អត្តលេខ០៨៧ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទមានការិយាល័យផ្ទះលេខ ២១១០B ផ្លូវជាតិលេខ៥ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

២.ឈ្មោះ [redacted] ភេទស្រី អាយុ៣៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ មេផ្ទះ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅសង្កាត់លេខ១ ក្រុងភ្នំពេញ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ:១៧៥៤ ផ្លូវលេខ៦២ ក្រុមទី៤ ភូមិផ្សារតូច សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ប្តីឈ្មោះ [redacted] ទោសពីមុនគ្មាន ។ (**ក្រៅឃុំ**)

ជាប់ចោទពីបទ: **ប្តឹងបរិហាបង្កាច់កេរ្តិ៍** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងតាមមាត្រា ៣១១ និងឲ្យផ្តន្ទាទោសតាមមាត្រា ៣១២ នៃក្រមព្រហ្មទណ្ឌ ។

-ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ៣៧ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅផ្ទះលេខ:៧០០ ផ្លូវលេខ៥៨ ភូមិផ្សារតូច សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

-លោកមេធាវី [redacted] និងលោកមេធាវី [redacted] ជាមេធាវីការពារក្តី និងជាតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី។

**<u>អង្គហេតុនៃរឿងមានដូចតទៅ៖</u>**

កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧ ឈ្មោះ និងប្រពន្ធ បានប្តឹងពីឈ្មោះ មកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ពីករណី បំភាន់មន្ត្រីសុរិយោដីក្នុងពេលបំពេញបេសកកម្ម និង បំភាន់អាជ្ញាធរយកដីរបស់ជនរងគ្រោះទៅចុះបញ្ជីសុរិយោដីធ្វើជាកម្មសិទ្ធរបស់ខ្លួន តែត្រូវបានតំណាងអយ្យការសម្រេច តម្កល់រឿងទុកឥតចាត់ការ តាមដីកាលេខ:០៣១ អ.យ.ឃ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨។ បន្ទាប់មកឈ្មោះ ចេង ច័ន្ទដារ៉ា និងប្រពន្ធបានប្តឹងឧទ្ធរណ៍នឹងដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការនេះ ហើយមហាអយ្យការអមសាលាឧទ្ធរណ៍ពិនិត្យ លើសំណុំរឿងនេះហើយក៏បានចេញសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការលេខ: ០៧៦ សត.ប្រក.០១៨ ចុះថ្ងៃទី០៤ ខែ ឧសភា ឆ្នាំ២០១៨ ដែលមានខ្លឹមសារតម្កល់តាមដីកាសម្រេចរបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកជា បានការដដែល។ យោងតាមដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ ឈ្មោះ ផ្លុង សុន្ទួន បានដាក់ពាក្យបណ្តឹងចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ ប្តឹងពីឈ្មោះ ឈ្មោះ និងប្រពន្ធឈ្មោះ ពីបទ: បរិហាបង្កាច់កេរ្តិ៍ មកអយ្យការអមសាលាដំបូងរាជធានី ភ្នំពេញ ហើយត្រូវបានតំណាងអយ្យការសម្រេចបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់តាមដីកាលេខ: ០៩១ អ.យ.ស ចុះថ្ងៃទី២៦ ខែ តុលា ឆ្នាំ២០១៨ តែម្តង។

**-បានឃើញ** ដីកាតម្កល់រឿងទុកឥតចាត់ការលេខ: ០៣១ អ.យ.ឃ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ របស់តំណាង អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

**-បានឃើញ** សេចក្តីសម្រេចតម្កល់ដីកាតម្កល់រឿងទុកឥតចាត់ការលេខ: ០៧៦ សត.ប្រក.០១៨ ចុះថ្ងៃទី០៤ ខែ ឧសភា ឆ្នាំ២០១៨ របស់មហាអយ្យការអមសាលាឧទ្ធរណ៍។

**-បានឃើញ** ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ:០៩១អ.យ.ស ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ របស់អយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ បានឆ្លើយថា កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧ ខ្លួនពិតជាបានប្តឹងឈ្មោះ ភេទប្រុស រស់នៅផ្ទះលេខ:៧០០ ផ្លូវលេខ៥៨ ស្ថិតនៅភូមិផ្សារតូច សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវពិតមែន ក្នុងគោលបំណងទាមទារដីរបស់ខ្លួនមកវិញតែប៉ុណ្ណោះ មិនមានបំណងបរិហាបង្កាច់កេរ្តិ៍នោះទេ ហើយប្រពន្ធខ្លួនក៏មិន បានចូលរួមប្តឹងជាមួយខ្លួននោះដែរ។ បន្ទាប់ពីខ្លួនបានដាក់ពាក្យបណ្តឹងនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញរួចមក ស្រាប់តែតំណាងអយ្យការបានសម្រេចតម្កល់សំណុំរឿងទុកឥតចាត់ការ តាមដីកាសម្រេចលេខ ០៣១ អ.យ.ឃ ចុះថ្ងៃទី ០៨ ខែមករា ឆ្នាំ២០១៨ ដោយសាររឿងនេះជារឿងពិត ខ្លួនមិនសុខចិត្តនឹងដីកាសម្រេចនេះក៏បានប្តឹងឧទ្ធរណ៍នឹងដីកា សម្រេចតម្កល់រឿងទុកឥតចាត់ការនេះទៅសាលាឧទ្ធរណ៍ទៀត។ បន្ទាប់ពីមហាអយ្យការអមសាលឧទ្ធរណ៍បានពិនិត្យលើ សំណុំរឿងបណ្តឹងឧទ្ធរណ៍រួចហើយ ស្រាប់តែមហាអយ្យការអមសាលាឧទ្ធរណ៍បានសម្រេចតម្កល់សំណុំរឿងនេះទុកឥត ចាត់ការទៀត តាមដីកាសម្រេចរបស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។ គោលដែលខ្លួនប្តឹងនេះ គ្រាន់តែចង់បានដី របស់ខ្លួនមកវិញតែប៉ុណ្ណោះ មិនមានចេតនាប្តឹងបរិហាបង្កាច់កេរ្តិ៍ លើឈ្មោះ នោះទេ។

-សាក្សីឈ្មោះ បានឆ្លើយថា ខ្លួនដឹងថាឈ្មោះ ចេង ច័ន្ទដារ៉ា បានប្តឹងពីឈ្មោះ ដោយសារតែ ឈ្មោះ បានធ្វើផ្ទះនៅលើដីរបស់គាត់ដោយគាត់ចូលទៅមើលដីគាត់ឈ្មោះ មិនឱ្យគាត់ចូលទៅមើល ដីរបស់គាត់ឡើយ។ នៅពេលដែលតុលាការតម្កល់ពាក្យបណ្តឹងរបស់ឈ្មោះ ចេង ច័ន្ទដារ៉ា នៅសាលាដំបូងរាជធានីភ្នំពេញ និងទាំងនៅសាលាឧទ្ធរណ៍ភ្នំពេញនោះខ្លួនមិនបានដឹងឡើយ។

-ឈ្មោះ បានឆ្លើយថា ខ្លួនជាបងប្រុសបង្កើតរបស់ឈ្មោះ ផ្លុង សុខ្ខន ការដែលខ្លួនមកធ្វើជាសាក្សីនេះដោយសារតែឃើញមានភាពអយុត្តិធម៌ចំពោះឈ្មោះ ចេង ច័ន្ទដារ៉ា ដែលត្រូវបានឈ្មោះ ផ្លុង សុខ្ខន បានធ្វើការបំភាន់យកដីរបស់ឈ្មោះ ចេង ច័ន្ទដារ៉ា ធ្វើការសាងសង់ផ្ទះរួចធ្វើឯកសារជាកម្មសិទ្ធិរបស់ខ្លួនរហូតមកដល់សព្វថ្ងៃនេះ។ ចំពោះពាក្យបណ្ដឹងរបស់ឈ្មោះ ចេង ច័ន្ទដារ៉ា ដែលបានប្ដឹងនៅសាលាដំបូងរាជធានីភ្នំពេញ ហើយត្រូវបានតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញធ្វើការតម្កល់ទុកឥតចាត់ការ និងនៅមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញធ្វើការតម្កល់ទុក យ៉ាងណានោះខ្លួនមិនបានដឹងរឿងឡើយ។

-សាក្សីឈ្មោះ បានឆ្លើយថា ខ្លួនត្រូវជាប់សាច់ញាតិជាមួយជនជាប់ចោទដែលខ្លួនមកធ្វើជាសាក្សីនេះដោយសារតែឃើញមានភាពអយុត្តិធម៌ចំពោះឈ្មោះ ចេង ច័ន្ទដារ៉ា ដែលត្រូវបានឈ្មោះ ផ្លុង សុខ្ខន បានធ្វើការបំភាន់យកដីរបស់ឈ្មោះ ចេង ច័ន្ទដារ៉ា ធ្វើការសាងសង់ផ្ទះរួចធ្វើឯកសារជាកម្មសិទ្ធិរបស់ខ្លួនគ្រប់គ្រងរហូតមកដល់សព្វថ្ងៃនេះ។ ចំពោះពាក្យបណ្ដឹងរបស់ឈ្មោះ ចេង ច័ន្ទដារ៉ា ដែលបានប្ដឹងនៅសាលាដំបូងរាជធានីភ្នំពេញ ហើយត្រូវបានតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញធ្វើការតម្កល់ទុកឥតចាត់ការ និងនៅមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញធ្វើការតម្កល់ទុក យ៉ាងណានោះខ្លួនមិនបានដឹងរឿងឡើយ។

-តាមអំណានពាក្យបណ្ដឹងចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ របស់ឈ្មោះ ថា សុំប្ដឹងឈ្មោះ ភាំ និងប្រពន្ធឈ្មោះ ពីបទ កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧។ យោងតាមដីកាតម្កល់រឿងទុកឥតចាត់ការលេខ: ០៣១ អ.យ.ឃ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងយោងសេចក្ដីសម្រេចតម្កល់ដីកាតម្កល់រឿងទុកឥតចាត់ការលេខ:០៧៦ សត.ប្រក.០១៨ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៨ របស់មហាអយ្យការអមសាលាឧទ្ធរណ៍។ តបតាមកម្មវត្ថុខាងលើខ្លួនសូមជម្រាបជូនលោកព្រះរាជអាជ្ញាមេត្តាជ្រាបថា កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧ ឈ្មោះ និងប្រពន្ធឈ្មោះ បានដាក់ពាក្យបណ្ដឹងប្ដឹងខ្លួនពីបទ បំភាន់មន្ត្រីសុរិយោដីក្នុងពេលបំពេញបេសកកម្ម និងបំភាន់អាជ្ញាធរយកដីរបស់ជនរងគ្រោះទៅចុះបញ្ជីសុរិយោដីធ្វើជាកម្មសិទ្ធរបស់ខ្លួន មកកាន់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។ ក្រោយពីអយ្យការធ្វើការស៊ើបអង្កេតកោះហៅគូភាគីដែលពាក់ព័ន្ធទាំងអស់មកសាកសួរ ឆ្លើយបំភ្លឺរួចមកឃើញថា ខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់របស់ឈ្មោះ និងប្រពន្ធឈ្មោះ ឡើយ រួចតំណាងអយ្យការក៏បានចេញដីកាតម្កល់រឿងទុកឥតចាត់ការលេខ: ០៣១ អ.យ.ឃ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨។ លុះក្រោយមកឈ្មោះ និងប្រពន្ធឈ្មោះ បានប្ដឹងឧទ្ធរណ៍និងដីការម្កល់រឿងទុកឥតចាត់ការលេខ: ០៣១ អ.យ.ឃ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ហើយក៏ត្រូវបានមហាអយ្យការអមសាលាឧទ្ធរណ៍ចេញសេចក្ដីសម្រេចតម្កល់ដីកាតម្កល់រឿងទុកឥតចាត់ការលេខ: ០៧៦ សត.ប្រក.០១៨ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៨ ដែលមានខ្លឹមសារតម្កល់តាមដីកានេះទុកជាបានការដដែលទៀត។ ហេតុដូច្នេះទង្វើរបស់ឈ្មោះ និងប្រពន្ធឈ្មោះ នេះមានចេតនាទុច្ចរិតធ្វើឲ្យប៉ះពាល់ដល់កិត្តិយស និងសេចក្ដីថ្លៃថ្នូរ របស់ខ្លួនក្នុងសង្គមជាខ្លាំងក្នុងនាមខ្លួនជាប្រជាពលរដ្ឋស្លូតត្រង់ម្នាក់។ ក្នុងរឿងនេះខ្លួនស័ណ្ឋមពរ៖

១.ចោទប្រកាន់លើឈ្មោះ និងប្រពន្ធឈ្មោះ ទៅតាមច្បាប់។

២.ទាមទារសំណងការខូចខាត ជម្ងឺចិត្តចំនួន ២០០០០(ពីរម៉ឺន)ដុល្លាអាមេរិក។

៣.សេវាមេធាវីចំនួន ៤០០០ (បួនពាន់) ដុល្លាអាមេរិក ។

-អំណានដីកាតម្កល់រឿងទុកឥតចាត់ការលេខ: ០៣១ អ.យ.ឃ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ថា សម្រេចតម្កល់សំណុំរឿងព្រហ្មទណ្ឌលេខ៤៩៩២ ចុះថ្ងៃទី ០៩ ខែមករា ឆ្នាំ២០១៨ ទុក

តតចាត់ការតទៅ ។

-អំណានសេចក្តីសម្រេចតម្កល់ដីកាតម្កល់រឿងទុកឥតចាត់ការលេខ:០៧៦សត.ប្រក.០១៨ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៨ របស់មហាអយ្យការអមសាលាឧទ្ធរណ៍ថា តម្កល់ដីកាតម្កល់រឿងទុកឥតចាត់ការលេខ០៣១ អ.យ.ឃ ចុះថ្ងៃទី ០៨ ខែមករា ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។

លោក ជាមេធាវីការពារសិទ្ធិនិងជាតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានសិក្សាសំណុំរឿងនិងបានស្តាប់ការសាកសួរដេញដោលលើជនជាប់ចោទ និងសាក្សីឃើញថា តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ បានឆ្លើយសារភាពថា ខ្លួនពិតជាបានប្តឹងពីកូនក្តីរបស់ខ្លួនពីបទបំភាន់សុរិយោដីមកសាលាដំបូងរាជធានីភ្នំពេញមែន ហើយត្រូវបានតំណាងអយ្យការអមសាលាដំបូងរាជធានីធ្វើការតម្កល់រឿងទុកឥតចាត់ការ។ បន្ទាប់មកឈ្មោះ បានបន្តប្តឹងទៅមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញដែលសំណុំរឿងនេះក៏ត្រូវបានមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញបានសម្រេចតម្កល់ដីកាតម្កល់រឿងទុកឥតចាត់ការលេខ:០៣១អ.យ.ឃ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល នេះបញ្ជាក់ឱ្យឃើញថា ការប្តឹងរបស់ឈ្មោះ ទាំងពីរសាលាមកលើកូនក្តីរបស់ខ្លួនមិនមានភស្តុតាងអ្វីមកដាក់បន្ទុកលើកូនក្តីខ្លួនឡើយ។ ម្យ៉ាងតាមចម្លើយសាក្សីរបស់ជនជាប់ចោទ មិនបានដឹងពីសំណុំរឿងដែលជនជាប់ចោទប្តឹងពីកូនក្តីរបស់ខ្លួនឡើយ ហើយក៏មិនបានដឹងពីសំណុំរឿងរបស់ជនចាប់ចោទ ដែលត្រូវបានតំណាងអយ្យការធ្វើការតម្កល់ទុកឥតចាត់ការទាំងពីរសាលានោះឡើយ។ ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារ និងជាតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងនេះខ្លួនប្តឹងទាមទារដូចក្នុងពាក្យបណ្តឹង ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ ពីជនជាប់ចោទដដែល។

*•សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ•*

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ,សាក្សី និងអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអំណានឯកសារផ្សេងៗមានក្នុងសំណុំរឿងឃើញថា ពិតជាមានអំពើ **បរិហាបង្កាច់កេរ៍** ប្រាកដមែន ដូច្នេះតំណាងអយ្យការសុំតម្កល់ការប្តឹងចោទ តាមដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់រលេខ: ០៩១ អ.យ.ស ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ ទុកដដែល និងសុំឱ្យតុលាការពិចារណាសម្រេចតាមច្បាប់ ។

លោក ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនបានដាក់ពាក្យប្តឹងឈ្មោះ ផ្លុង សុខ្លន ដោយសារតែឈ្មោះនេះបានលួចធ្វើកម្មសិទ្ធិលើដីរបស់កូនក្តីខ្លួនរួចបានធ្វើផ្ទះនៅលើដីរបស់កូនក្តីខ្លួនដែលបានបុកត្រឹះរួចគ្រប់គ្រងរហូតមកដល់បច្ចុប្បន្ន ហើយកូនក្តីរបស់ខ្លួនឈ្មោះ តែម្នាក់គត់ធ្វើការដាក់ពាក្យបណ្តឹងទៅលើឈ្មោះ មកសាលាដំបូងរាជធានីភ្នំពេញ ពីបទ បំភាន់មន្ត្រីសុរិយោដីក្នុងពេលបំពេញបេសកម្មនិងបំភាន់អាជ្ញាធរយកដីរបស់កូនក្តីខ្លួនទៅចុះបញ្ជីធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ហើយតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញមិនបានធ្វើការស្រាវជ្រាវរកតាមពាក្យបណ្តឹងរបស់ខ្លួនក្តីខ្លួននោះទេ ក៏បានតម្កល់សំណុំរឿងទុកឥតចាត់ការតែម្តងទើបធ្វើកូនក្តីរបស់ខ្លួនមិនអស់ចិត្តក៏បានបន្តប្តឹងពីដីកាតម្កល់រឿងទុកឥតចាត់ការរបស់សាលាដំបូងរាជធានីភ្នំពេញទៅមហាអយ្យការអមសាលាឧទ្ធរណ៍ ដើម្បីជួយរកយុត្តិធម៌ឱ្យ តែត្រូវបានមហាអយ្យការអមសាលាឧទ្ធរណ៍ធ្វើការតម្កល់ដីកាតម្កល់រឿងទុកឥតចាត់ការលេខ:០៣១ អ.យ.ឃ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែលទៀត។ ចំណែកឯឈ្មោះ ដែលត្រូវជាប្រពន្ធរបស់ឈ្មោះ នោះ គាត់នៅឯក្រៅប្រទេសមិនបានដឹងរឿងអ្វីទេ ហើយការដាក់ពាក្យបណ្តឹងនេះមានតែឈ្មោះ ម្នាក់គត់មិនមានស្វាមីមេង ឬក៏ឈ្មោះ ក្នុងការចូលរួមប្តឹងក្នុងសំណុំរឿងនេះឡើយ។ បើយើងពិនិត្យលើសំណុំ

រឿងនេះក៏ដូចជាពាក្យបណ្ដឹងរបស់ឈ្មោះ ដែលប្ដឹងពីឈ្មោះ តែជាបងប្អូនគ្នា ដែលទាក់ទងជម្លោះកម្មសិទ្ធិដីធ្លី ដូច្នេះហើយ ខ្ញុំសុំឱ្យតុលាការពិចារណាសម្រេចឱ្យកូនក្ដីរបស់ខ្ញុំទាំងពីរនាក់គឺឈ្មោះ ចេង ច័ន្ទដារ៉ា និងប្រពន្ធឈ្មោះ បានរួចផុតពីបទចោទប្រកាន់ក្នុងរឿងនេះតាមផ្លូវច្បាប់។

*•សំដីចុងក្រោយរបស់ជនជាប់ចោទ•*

-ជនជាប់ចោទឈ្មោះ បាននិយាយសម្ដីចុងក្រោយបង្ហាញថា ខ្ញុំសុំឱ្យតុលាការលើកលែងចោទប្រកាន់។

-ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់ចម្លើយសាក្សី

-ក្រោយពីបានស្ដាប់អំណានពាក្យបណ្ដឹង ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨

-ក្រោយពីបានស្ដាប់អំណានឯកសារមានក្នុងសំណុំរឿង

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋាន របស់មេធាវីការពារសិទ្ធិនិងតំណាងឱ្យដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋាន របស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា ដែលមានក្នុងសំណុំរឿង

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## **សំអាងហេតុ**

១.កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧ ឈ្មោះ បានប្ដឹងពីឈ្មោះ ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ មកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ពីករណី បំភាន់មន្ត្រីសុរិយោដីក្នុងពេលបំពេញបេសកកម្ម និងបំភាន់អាជ្ញាធរយកដីរបស់ជនរងគ្រោះទៅចុះបញ្ជីសុរិយោដីធ្វើជាកម្មសិទ្ធរបស់ខ្លួន តែត្រូវបានតំណាងអយ្យការសម្រេចតម្កល់រឿងទុកឥតចាត់ការ តាមដីកាលេខ: ០៣១ អ.យ.ឃ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ បន្ទាប់មកឈ្មោះ បានប្ដឹងដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញទៅមហាអយ្យការអមសាលាឧទ្ធរណ៍ពិនិត្យលើសំណុំរឿងនេះក៏បានចេញសេចក្ដីសម្រេចតម្កល់រឿងទុកឥតចាត់ការលេខ: ០៧៦ សត.ប្រក.០១៨ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៨ ដែលមានខ្លឹមសារតម្កល់តាមដីកាសម្រេចរបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។ យោងតាមដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញនិងមហាអយ្យការអមសាលាឧទ្ធរណ៍ ទើបឈ្មោះ បានដាក់ពាក្យបណ្ដឹង ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ ប្ដឹងពីឈ្មោះ និងប្រពន្ធឈ្មោះ ពីបទ: **បរិហាបង្កាច់កេរ្ដិ៍** មកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ហើយត្រូវបានតំណាងអយ្យការសម្រេច តាមដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ: ០៩១ អ.យ.ស ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ តែម្ដង។

២.ជនជាប់ចោទឈ្មោះ និងឈ្មោះ ត្រូវបានតំណាងអយ្យការចោទប្រកាន់ពីបទ **បរិហាបង្កាច់កេរ្ដិ៍** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ៣១១ និងមាត្រា ៣១២ នៃក្រមព្រហ្មទណ្ឌ តាមដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ: ០៩១ អ.យ.ស ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨។

៣.ជនជាប់ចោទឈ្មោះ បានឆ្លើយសារភាពថា ខ្ញុំពិតជាបានដាក់ពាក្យប្ដឹងឈ្មោះ ពីករណី បំភាន់មន្ត្រីសុរិយោដីក្នុងពេលបំពេញបេសកកម្ម និងបំភាន់អាជ្ញាធរយកដីរបស់ជនរងគ្រោះទៅចុះបញ្ជីសុរិយោដីធ្វើ

ជាកម្មសិទ្ធិរបស់ខ្លួន មកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ តែត្រូវបានតំណាងអយ្យការសម្រេចតម្កល់រឿងទុកឥតចាត់ការ ហើយខ្លួនបានប្តឹងពីដីកាសម្រេចរបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញទៅសាលាឧទ្ធរណ៍ហើយត្រូវបានមហាអយ្យការអមសាលាឧទ្ធរណ៍សម្រេចតម្កល់រឿងទុកឥតចាត់ការតាមដីកាលេខ: ០៧៦ សត.ប្រក.០១៨ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៨ ដោយឡែកប្រពន្ធរបស់ខ្លួនមិនបានចូលរួមប្តឹងជាមួយខ្លួនទេ ព្រោះថាខ្លួនប្តឹងដើម្បីការពារផលប្រយោជន៍និងសិទ្ធិរបស់ខ្លួនតែប៉ុណ្ណោះ។ ចម្លើយនេះជាចម្លើយសារភាពស៊ីសង្វាក់ជាមួយចម្លើយរបស់ជនជាប់ចោទពីមុខនិងពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងភស្តុតាងដែលមានក្នុងសំណុំរឿង ដែលអាចឱ្យតុលាការជឿបាន។

៤.តាមចម្លើយរបស់សាក្សីទាំងអស់នេះបានបញ្ជាក់ថា ពួកគេគ្រាន់បានដឹងថា ឈ្មោះ បានធ្វើការបំភាន់យកដីរបស់ឈ្មោះ ធ្វើការសាងសង់ផ្ទះរួចធ្វើឯកសារជាកម្មសិទ្ធិរបស់ខ្លួនរហូតមកដល់សព្វថ្ងៃនេះ។ ចំពោះការប្តឹងផ្តល់គ្នាពួកខ្លួនមិនបានដឹងទេ។

៥.តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ ដូចជាពាក្យបណ្តឹងបានឱ្យឃើញថា កាលពីអំឡុងឆ្នាំ២០១៧ជនជាប់ចោទរូបនេះពិតជាបានប្តឹងឈ្មោះ ពីករណីបំភាន់មន្ត្រីសុរិយោដីក្នុងពេលបំពេញបេសកកម្ម និងបំភាន់អាជ្ញាធរយកដីរបស់ជនរងគ្រោះទៅចុះបញ្ជីសុរិយោដីធ្វើជាកម្មសិទ្ធិរបស់ខ្លួន មកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញហើយត្រូវបានតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញបានតម្កល់ទុកឥតចាត់ការ ហើយបានជនជាប់ចោទរូបនេះបានប្តឹងនឹងដីកាសម្រេចរបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទៅសាលាឧទ្ធរណ៍ត្រូវបានមហាអយ្យការអមសាលាឧទ្ធរណ៍សម្រេចតម្កល់ទុកឥតចាត់ការដដែលនេះសបញ្ជាក់ឱ្យឃើញថា សកម្មភាពរបស់ជនជាប់ចោទរូបនេះត្រូវបានច្បាប់កំណត់ថា ជាអំពើ **បរិហាបង្កាច់កេរ៍** ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងតាមមាត្រា៣១១ និងឲ្យផ្តន្ទាទោសតាមមាត្រា៣១២ នៃក្រមព្រហ្មទណ្ឌ។ ចំណែកឈ្មោះ នេះមិនបានប្តឹងឈ្មោះ ពីករណីបំភាន់មន្ត្រីសុរិយោដីក្នុងពេលបំពេញបេសកកម្ម និងបំភាន់អាជ្ញាធរយកដីរបស់ជនរងគ្រោះទៅចុះបញ្ជីសុរិយោដីធ្វើជាកម្មសិទ្ធិរបស់ខ្លួននោះទេ ដែលបញ្ជាក់ថា ឈ្មោះ មិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះឡើយ។

៦.សកម្មភាពទាក់ទងនឹងបទ: **បរិហាបង្កាច់កេរ៍** ត្រូវបានហាមឃាត់ដោយច្បាប់ ដូច្នេះជនជាប់ចោទឈ្មោះ បានដឹងរួចហើយថា សកម្មភាពដែលខ្លួនបានប្រព្រឹត្តនោះគឺជាអំពើខុសច្បាប់ ប៉ុន្តែជនជាប់ចោទរូបនេះនៅតែប្រព្រឹត្តដដែលគឺបញ្ជាក់យ៉ាងច្បាស់ថា ជនជាប់ចោទរូបនេះពិតជាមានចេតនាទុច្ចរិតក្នុងការប្រព្រឹត្តនូវអំពើ **បរិហាបង្កាច់កេរ៍** ដែលច្បាប់បានបញ្ញត្តិថាជាបទល្មើសនិងត្រូវផ្តន្ទាទោស។

៧.ជនជាប់ចោទឈ្មោះ ជានីតិជន មានសតិគ្រប់គ្រាន់ មិនវិបល្លាសស្មារតី មានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួនដែលបានប្រព្រឹត្តកន្លងមក។

៨.អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ បានធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយសណ្តាប់សាធារណៈ និងប៉ះពាល់ដល់កេរ៍ឈ្មោះ សេចក្តីថ្លៃថ្នូរ របស់ជនរងគ្រោះ ។

៩.មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ៥១ឆ្នាំ សញ្ជាតិខ្មែរ មានសាវតារជាតិខាងលើ ពីបទ: **បរិហាបង្កាច់កេរ៍** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងតាមមាត្រា ៣១១ និងឲ្យផ្តន្ទាទោសតាមមាត្រា ៣១២ នៃក្រមព្រហ្មទណ្ឌ ។

១០.គ្មានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើឈ្មោះ ភេទស្រី អាយុ៣៩ឆ្នាំ សញ្ជាតិខ្មែរ មានសាវតារជាតិខាងលើ ពីបទ **បរិហាបង្កាច់កេរ៍** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងតាមមាត្រា ៣១១ និងឲ្យផ្តន្ទាទោសតាមមាត្រា ៣១២ នៃក្រមព្រហ្មទណ្ឌ។ ដូច្នេះតុលាការគប្បីសម្រេចឱ្យឈ្មោះ

រួចផុតពីបទចោទប្រកាន់។

១១.ដើមបណ្តឹងរដ្ឋប្បវេណីបានប្តឹងទាមទារសំណងការខូចខាត ជម្ងឺចិត្តជាទឹកប្រាក់ចំនួន ២០០០០(ពីរម៉ឺនដុល្លារអាមេរិក និងថ្លៃសេវាមេធាវីចំនួន ៤០០០ (បួនពាន់ដុល្លារអាមេរិក)នោះ តុលាការគប្បីពិចារណាតាមការជាក់ស្តែង ។

**ហេតុដូច្នេះសម្រេច**

១.ឱ្យឈ្មោះ ភេទស្រី អាយុ៣៥ឆ្នាំ សញ្ជាតិខ្មែរ មានសាវតារជាតិខាងលើ **រួចផុតបទចោទប្រកាន់** ពីបទ **បរិហារបង្កាច់កេរ្តិ៍** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងតាមមាត្រា ៣១១ និងឱ្យផ្តន្ទាទោសតាមមាត្រា ៣១២ នៃក្រមព្រហ្មទណ្ឌ។

២.ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ៥១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានសាវតារជាតិខាងលើ ដាក់ពន្ធនាគារកំណត់រយៈពេល ៦ ( **ប្រាំមួយ** )**ខែ** តែទោសនេះត្រូវព្យួរទាំងស្រុង ពីបទ **បរិហារបង្កាច់កេរ្តិ៍**ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងតាមមាត្រា ៣១១ និងឱ្យផ្តន្ទាទោសតាមមាត្រា **៣១២** នៃក្រមព្រហ្មទណ្ឌ។

៣.ឲ្យឈ្មោះ សងសំណងជម្ងឺចិត្តនិងថ្លៃសេវាមេធាវីជាទឹកប្រាក់ចំនួន **១.០០០.០០០(មួយលាន)រៀល** ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ។ ច្រានចោលការទាមទារលើសពីនេះ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ **រ៉ា** ,កំបាំងមុខជនជាប់ចោទឈ្មោះ និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ ។ ទុកសិទ្ធិប្តឹងឱ្យប្តឹងទាស់ ឬ ប្តឹងឧទ្ធរណ៍តាមច្បាប់កំណត់។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា៖

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"
ថ្ងៃ ពុធ ១០ រោច ខែ អាសាឍ ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ,ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០
**ក្រឡាបញ្ជីសវនាការ**

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**

**ឧបសម្ព័ន្ធទី១២**

## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

-លេខ ៥០៩ "ព"ក្រ៨
ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២
-សំណុំរឿងព្រហ្មទណ្ឌលេខ៤៦១១
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១
-សំណុំរឿងស៊ើបសួរលេខ៣៥០៩
ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១
-សំណុំរឿងជំនុំជម្រះលេខ២៣៦
ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២២

### នាមនាមប្រជារាស្ត្រខ្មែរ
### សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការសាធារណៈ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ០២ និង៣០ នាទីរសៀល នៅសាលសវនាការទី៩ ដោយមានសមាសភាព៖

### ក្រុមប្រឹក្សាជំនុំជម្រះ

-លោកចៅក្រម ជាប្រធានក្រុមប្រឹក្សា

-លោកអនុប្រធាន ជាចៅក្រមប្រឹក្សា

-លោកស្រីចៅក្រម ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

-លោក ជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

-លោក ជាក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៤៦១១ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ៖
ឈ្មោះ ភេទប្រុស កើតឆ្នាំ២០០៤ ជនជាតិខ្មែរ មុខរបរជាងពិដាន នៅលីវ ឪពុកឈ្មោះ
"រស់" ម្តាយឈ្មោះ ជាអនីតិជន ទោសពីមុន "គ្មាន"។ (ក្នុងឃុំ)
ទីកន្លែងកំណើត: ភូមិស្រីសន្ធរ ឃុំបារាយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។
អាសយដ្ឋានបច្ចុប្បន្ន: ស្នាក់នៅបន្ទប់ជួល ភូមិសេរីពិល សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។
ឃាត់ខ្លួននៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២១។
ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៧៧០៦ "ឃ" ដ.ឃ.ដ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១។ (មខ)
ដោយមានលោក ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។
ដោយមានលោក ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

ជាប់ចោទពីបទ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្លូវលំ ភូមិជម្ពូវ័ន សង្កាត់ចោមចៅ៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

### អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង១៤ និង៥៥នាទី ការិយាល័យអន្តរាគមន៍(ក៨) នៃមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន បានចុះបង្ក្រាបជាក់ស្តែងករណីរក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចផ្លូវលំ ភូមិជម្ពូវ័ន សង្កាត់ចោមចៅ៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឃាត់ខ្លួនជនជាប់ចោទឈ្មោះ ភេទប្រុស កើតឆ្នាំ២០០៤ ដកហូតបានម្សៅក្រាមពណ៌សថ្លាសង្ស័យជា សារធាតុញៀនប្រភេទមេតំហ្វេតាមីនចំនួន០២កញ្ចប់ ដែលមានទម្ងន់ ០,៤០ក្រាម ហើយបាននាំខ្លួនមកកាន់មន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន ដើម្បីធ្វើការសាកសួរ។ ក្រោយពីធ្វើការសាកសួរទទួលបានលទ្ធផលថាថ្នាំញៀនទាំងនោះ គឺជនជាប់ចោទបានទិញពីអ្នកលក់មិនស្គាល់ឈ្មោះ នៅម្តុំសាលា

ផ្លូវថ្ម បំណងយកមកទុកប្រើប្រាស់។ ក្រោយពីធ្វើការសាកសួររួចសមត្ថកិច្ចបានធ្វើការឃាត់ខ្លួនជនជាប់ចោទខាងលើ និងដកហូតវត្ថុតាង រួចកសាងសំណុំរឿងបញ្ជូនមកអយ្យការសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធី។

-បានឃើញ របាយការណ៍លេខ ៦៧៤ រ.ប.ក ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ របស់មន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៤៦៧៧ អ.យ.ទ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១។

-បានឃើញ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ៣៧ "ច" ដ.ដ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២។

## នាពេលសវនាការ

ជនជាប់ចោទឈ្មោះ បានឆ្លើយថា នៅថ្ងៃកើតហេតុ ខ្លួនបានហៅជាស់អែបជិះទៅទិញគ្រឿងញៀន នៅផ្លូវថ្ម ដោយខ្លួនបានទិញពីមនុស្សប្រុសមិនស្គាល់ឈ្មោះ ចំនួនពីរកញ្ចប់តូច ដោយក្នុងមួយកញ្ចប់ តម្លៃ២០.០០០ (ពីរម៉ឺន)រៀល។ ក្រោយមកត្រូវសមត្ថកិច្ចចុះមកឃាត់ខ្លួនតែម្តង។ ខ្លួនបានទិញថ្នាំញៀនក្នុងគោលបំណងយកមកប្រើប្រាស់ផ្ទាល់ខ្លួនប៉ុណ្ណោះ។ សមត្ថកិច្ចដកហូតថ្នាំញៀនពីខ្លួនបានចំនួន០២កញ្ចប់។

ក្រឡាបញ្ជីអានកំណត់ហេតុទទួលវត្ថុចាប់យក (១) លេខ ២០០៤ រ.វ.ត ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ រួមមាន៖[1]

-ស្រោមសំបុត្រពិទជិតពណ៌លឿងទុំចំនួន០១ សរសេរថាក្រាមពណ៌សថ្លាទម្ងន់ ០,៤០ (សូន្យក្បៀសសែសិប) ក្រាម ដោយមានស្នាមផ្តិតម្រាមដៃជនជាប់ចោទឈ្មោះ និងចុះហត្ថលេខារបស់មន្ត្រីនគរបាលយុត្តិធម៌។

ក្រឡាបញ្ជីអានលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ៣៣៩៧៦ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ របស់មន្ទីរពិសោធន៍ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ឃើញថា៖[2] សំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅថ្លា ឈ្មោះ មេតំហ្វេតាមីន របស់ឈ្មោះ មៀន ស្រៀន ដែលមានកម្រិតភាពសុទ្ធ៧៥.៦៩%នៃទម្ងន់សរុប វាស្ថិតនៅក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា។

## សេចក្តីសន្និដ្ឋានចុងក្រោយរបស់តំណាងអយ្យការ

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន តាមចម្លើយសារភាពរបស់ជនជាប់ចោទ និងភស្តុតាងដែលសមត្ថកិច្ចបានដកហូត ឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន ហេតុនេះ តំណាងអយ្យការនៅតែរក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ៤៦៧៧ អ.យ.ទ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ទុកជាបានការដដែល និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

## សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

លោកមេធាវី ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីរបស់ខ្លួនជាអនីតិជន ប្រកបរបរស្របច្បាប់ និងពុំធ្លាប់មានទោសពីមុនមកទេ ដោយសារកម្រិតវប្បធម៌ទាប រៀនបានត្រឹមថ្នាក់ទី២ គាត់ងាយនឹងទទួលរងគ្រោះក្នុងការប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនជាទីបំផុត។ ក្រោយពីបានពិភាក្សាដេញដោលក្នុងពេលសវនាការ និងឯកសារភស្តុតាងក្នុងសំណុំរឿងឃើញថា កូនក្តីរបស់ខ្លួន គឺបានប្រព្រឹត្តតែ បទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដូចមានចែងក្នុងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន តែប៉ុណ្ណោះ ហើយគាត់ពុំបានប្រព្រឹត្ត បទរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ដូចមានចែងក្នុងមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នោះឡើយ។ ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ សូមស្នើសុំក្រុមប្រឹក្សាជំនុំជម្រះ មេត្តាឱ្យកូនក្តីខ្លួនរួចផុតពីបទចោទ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន។ ម្យ៉ាងវិញទៀត រហូតមកដល់ពេលនេះ កូនក្តីខ្លួនត្រូវបាន

(1) [illegible]

(2) [illegible]

ខ្លួនបណ្ដោះអាសន្នអស់រយៈពេលលើសពី៦ខែហើយ ដូច្នេះខ្លួនសូមស្នើក្រុមប្រឹក្សាជំនុំជម្រះដោះលែងកូនក្ដីខ្លួនឱ្យបានត្រឡប់ទៅផ្ទះវិញ។

**សំដីចុងក្រោយរបស់ជនជាប់ចោទ**

ជនជាប់ចោទឈ្មោះ  បានសំណូមពរសុំតុលាការ ជួយបន្ធូរបន្ថយទោសដល់ខ្លួនផង។

-ក្រោយពីបានស្ដាប់ចម្លើយសារភាពរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារភស្ដុតាងនានា។

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

**សាលាដំបូងរាជធានីភ្នំពេញ**

**យល់ឃើញថា**[3]

ក. តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៣៧ "ថ" ជ.ឋ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបញ្ជូនទៅជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ៤៦១១ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ ដែលមានជនជាប់ចោទឈ្មោះ  ភេទប្រុស កើតឆ្នាំ២០០៤ ពីបទរក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្លូវលំ ភូមិជម្ពូវ័ន សង្កាត់ចោមចៅ៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។[4]

ខ. អង្គហេតុកើតឡើងនៅចំណុចផ្លូវលំ ភូមិជម្ពូវ័ន សង្កាត់ចោមចៅ៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ហេតុនេះជាសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌនៃសាលាដំបូងរាជធានីភ្នំពេញ។[5]

គ. អង្គហេតុកើតឡើងកាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ បើគិតរហូតមកដល់ពេលនេះ មិនទាន់ផុតអាជ្ញាយុកាលនៃបទល្មើសទេ។[6]

ឃ. តាមរបាយការណ៍សំយោគលេខ ៦៧៤ រ.ប.ក ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ របស់មន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន នៃក្រសួងមហាផ្ទៃ បានធ្វើការសន្និដ្ឋានថា ជនជាប់ចោទឈ្មោះ មៀន ស្រៀន ពិតជាបាន ជួញដូរដោយខុសច្បាប់នូវសារធាតុញៀនប្រាកដមែន។[7]

ង. តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ មៀន ស្រៀន បានឆ្លើយសារភាពថា ខ្លួនពិតជាបានទិញថ្នាំញៀនពីមនុស្សប្រុសមិនស្គាល់ឈ្មោះ ចំនួនពីរកញ្ចប់តូច ដោយក្នុងមួយកញ្ចប់ តម្លៃ២០.០០០ (ពីរម៉ឺន)រៀល។ ក្រោយមកសមត្ថកិច្ចចុះមកឃាត់ខ្លួនតែម្ដង។ ខ្លួនបានទិញថ្នាំញៀនក្នុងគោលបំណងយកមកប្រើប្រាស់ផ្ទាល់ខ្លួនប៉ុណ្ណោះ សមត្ថកិច្ចដកហូតថ្នាំញៀនពីខ្លួនបានចំនួន០២កញ្ចប់។

ច. សកម្មភាពរបស់ជនជាប់ចោទឈ្មោះ  ដែលបានទិញថ្នាំញៀនពីជនមិនស្គាល់ឈ្មោះ យកមកទុកក្នុងគោលបំណងយកមកប្រើប្រាស់ បង្ហាញពីចេតនាទុច្ចរិតក្នុងការរក្សាទុកដោយខុសច្បាប់នូវគ្រឿងញៀន។

ឆ. តាមកំណត់ហេតុទទួលវត្ថុចាប់យក (១) លេខ ២០០៤ វ.វ.ត ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ រួមមាន៖[8]

---

(3). មាត្រា[illegible] មាត្រា[illegible] និងមាត្រា[illegible] នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

(4). មាត្រា[illegible] នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

(5). មាត្រា[illegible] នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

(6). មាត្រា[illegible] និង[illegible] នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

(7). [illegible]

(8). [illegible]

-ស្រោមសំបុត្របិទជិតពណ៌លឿងទុំចំនួន០១ មានសរសេរថា ក្រាមពណ៌សផ្កាទម្ងន់ ០,៤០ (សូន្យក្បៀសសែសិប) ក្រាម បើផ្អែកតាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ៣៣៩៧៦ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ របស់មន្ទីរពិសោធន៍ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បញ្ជាក់ឱ្យឃើញថា ជាគ្រឿងញៀនប្រភេទមេតំហ្វេតាមីន ស្ថិតនៅក្នុងតារាងទី២ មាត្រា៥ នៃតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មានកម្រិតភាពសុទ្ធចំនួន ៧៥.៦៨% (ចិតសិបប្រាំក្បៀសហុកសិបប្រាំបួនភាគរយ) នៃទម្ងន់សរុប ហេតុនេះមានបរិមាណសារធាតុញៀនសុទ្ធមានចំនួន $\frac{០.៤០g \times ៧៥.៦៨}{១០០} = ០,៣០g$ (សូន្យក្បៀសសាមសិបមួយ)ក្រាម។

ជ. តាមចម្លើយសារភាពរបស់ជនជាប់ចោទខាងលើ តាំងពីនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ រហូតដល់ដំណាក់កាលជំនុំជម្រះ និងរបាយការណ៍របស់សមត្ថកិច្ច ព្រមទាំងភស្តុតាងផ្សេងៗទៀតដែលដកហូតបានដោយមន្ត្រីនគរបាលយុត្តិធម៌ មានភាពស៊ីសង្វាក់គ្នាបង្ហាញឱ្យឃើញថាជនជាប់ចោទឈ្មោះ មៀន ស្រៀន ពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ប្រាកដមែន។

ឈ. អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ ដែលបានទិញគ្រឿងញៀនពីជនមិនស្គាល់ឈ្មោះ យកមកទុក ហើយត្រូវបានសមត្ថកិច្ចធ្វើការឃាត់ខ្លួន និងឆែកឆេររកឃើញថ្នាំញៀនប្រភេទមេតំហ្វេតាមីនដែលមានបរិមាណសារធាតុញៀនសុទ្ធចំនួន ០,៣០g (សូន្យក្បៀសសាមសិប)ក្រាម ក្រោយពីធ្វើការឃាត់ខ្លួនសមត្ថកិច្ចបានធ្វើតេស្តទឹកនោមស្វែងរកសារធាតុញៀន លើជនជាប់ចោទឈ្មោះ មៀន ស្រៀន លទ្ធផលវិជ្ជមាន បើផ្អែកតាមធាតុផ្សំនុក្កូលស្របទៅនឹងបទ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ជាបទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ១ និងកថាខណ្ឌ៤ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-មាត្រា៤០ កថាខណ្ឌ១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ការកាន់កាប់ ការលាក់ទុក សន្និធិ និងសកម្មភាពប្រហាក់ប្រហែលផ្សេងទៀតដោយខុសច្បាប់នូវសារធាតុញៀន គឺជាអំពើរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន។

-មាត្រា៤០ កថាខណ្ឌ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន បានចែងថា បទរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ដែលស្ថិតនៅក្នុងតារាងទី១ និងតារាងទី២ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ៤.០០០.០០០(បួនលាន)រៀល ទៅ១០.០០០.០០០ (ដប់លាន)រៀល។

-មាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ជនណាប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី១ និងតារាងទី២ តាមគ្រប់រូបភាព និងធ្លាប់ត្រូវបានទទួលរងនូវវិធានការព្យាបាលដោយបង្ខំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ៦(ប្រាំមួយ)ខែ និងអាចត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១០០.០០០(មួយសែន)រៀល ទៅ១.០០០.០០០(មួយលាន)រៀល។

ញ. ជនជាប់ចោទឈ្មោះ ភេទប្រុស កើតឆ្នាំ២០០៤ ជាអនីតិជន មានស្មារតីល្អ មានការយល់ដឹងខុសត្រូវច្បាស់លាស់ ហើយក៏ពុំមានសញ្ញាណណាមួយបញ្ជាក់ថា ជននេះមានវិបល្លាសស្មារតីអ្វីដែរ។

ដ. អំពើដែលជនជាប់ចោទ បានប្រព្រឹត្តធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម ជាពិសេសធ្វើឱ្យប៉ះពាល់ដល់សុខភាពបុគ្គល ជាអំពើផ្ទុយច្បាប់ តម្រូវអោយផ្តន្ទាទោស។

ឋ. កំណត់ហេតុទទួលវត្ថុចាប់យក (១) លេខ ២០០៤ រ.វ.ត ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ រួមមាន ស្រោមសំបុត្របិទជិតពណ៌លឿងទុំចំនួន០១ សរសេរថាក្រាមពណ៌សផ្កាទម្ងន់០,៤០(សូន្យក្បៀសសែសិប)ក្រាម មានបរិមាណសារធាតុញៀនសុទ្ធទម្ងន់ ០,៣០g (សូន្យក្បៀសសាមសិប)ក្រាម ជាវត្ថុតាងនៃការប្រព្រឹត្តបទល្មើស គប្បីតុលាការសម្រេច រឹបអូសបំផ្លាញចោល ផ្អែកតាមមាត្រា៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ. តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន នៅតែរក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ៤៦៧៧ អ.យ.ម ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ទុកជាបានការដដែល និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ការស្នើសុំនេះតុលាការនឹងលើកយកមកពិចារណា។

ឃ. លោក រស់ ឧត្តម ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋាន ដោយសូមស្នើសុំក្រុមប្រឹក្សាជំនុំជម្រះមេត្តាឱ្យកូនក្តីរបស់ខ្លួនរួចផុតពីបទចោទ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងស្នើសុំក្រុមប្រឹក្សាជំនុំជម្រះដោះលែងកូនក្តីរបស់ខ្លួន ការស្នើសុំនេះតុលាការនឹងលើកយកធ្វើការពិចារណា។

ង. ជនជាប់ចោទឈ្មោះ បានសំណូមពរឱ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ការស្នើសុំនេះតុលាការនឹងលើកយកមកធ្វើការពិចារណា។

មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ភេទប្រុស កើតឆ្នាំ២០០៤ ពីបទ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្លូវលំ ភូមិជម្ពូវ័ន សង្កាត់ចោមចៅ៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ១ និងកថាខណ្ឌ៤ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**ហេតុដូច្នេះ សម្រេច**

១.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ ភេទប្រុស កើតឆ្នាំ២០០៤ (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន ២ (ពីរ)ឆ្នាំ តែត្រូវអនុវត្តទោសក្នុងពន្ធនាគាររយៈពេលចំនួន ១០ (ដប់)ខែ ទោសសល់ពីនេះត្រូវព្យួរសាកល្បងរយៈពេល ២ (ពីរ)ឆ្នាំ។

ពីបទ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្លូវលំ ភូមិជម្ពូវ័ន សង្កាត់ចោមចៅ៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ១ និងកថាខណ្ឌ៤ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។[9]

២.ក្នុងរយៈពេល២(ពីរ)ឆ្នាំ នៃការព្យួរទោសសាកល្បងនេះ ទណ្ឌិតឈ្មោះ ត្រូវគោរពនូវកាតព្វកិច្ចមួយចំនួនដូចតទៅ:[10]

ក.ទណ្ឌិតត្រូវចូលបង្ហាញខ្លួនតាមការកោះហៅរបស់ព្រះរាជអាជ្ញា ឬ គ្រប់បុគ្គលដែលព្រះរាជអាជ្ញាបានផ្តល់អំណាចឱ្យ។

ខ.ទណ្ឌិតមិនត្រូវសេពគប់រាល់បុគ្គលដែលពាក់ព័ន្ធនឹងគ្រឿងញៀននោះទេ។

គ.ទណ្ឌិតមិនត្រូវសេពគប់កន្លែងលក់គ្រឿងស្រវឹង។

ឃ.ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរអាសយដ្ឋានរស់នៅរបស់ខ្លួន។

៣.វត្ថុចាប់យកមាននៅក្នុងកំណត់ហេតុលេខ (១) លេខ ២០០៤ វ.រ.ត ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ រួមមាន ក្រាមពណ៌សថ្លាទម្ងន់ 0,៤0 (សូន្យក្បៀសសែសិប)ក្រាម មានបរិមាណសារធាតុញៀនសុទ្ធទម្ងន់ 0,៣០៤ (សូន្យក្បៀសសាមសិប)ក្រាម ត្រូវរឹបអូសបំផ្លាញចោល។[11]

សាលក្រមនេះជំនុំជម្រះជាអសាធារណៈនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង០២ និង៣០ នាទីរសៀល ចំពោះមុខជនជាប់ចោទឈ្មោះ និងប្រកាសជាអសាធារណៈនៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង ៩ព្រឹក។[12]

---

(9) [illegible]

(10) [illegible]

(11) [illegible]

(12) [illegible]

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។[13]

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| លោក យស វាសនា | លោក រស់ ពិសិដ្ឋ | លោកស្រី សៀង ចរិយា | លោក ម៉ៅ ស៊ុណា |

**បានឃើញ**

ថ្ងៃពុធ ១៥កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃពុធ ១៥កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

(13) [illegible]